# ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education Youth and Sport


**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education


# និក្ខេបបទ

# ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រង
# នៅសាលាមត្តេយ្យសិក្សាធនធានក្នុងខេត្តស្វាយរៀង

# THE SITUATION OF LEADERSHIP AND MANAGEMENT
# AT RESOURCE KINDERGARTEN SCHOOL
# IN SVAY RIENG PROVINCE


**ដោយ**/BY

**ញ៉ឹក កិត្យា**/NHOEK KETYA


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល**
**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០២១-២០២៣**

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education


# និក្ខេបបទ

# ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រង
# នៅសាលាមត្តេយ្យសិក្សាធនធានក្នុងខេត្តស្វាយរៀង

## THE SITUATION OF LEADERSHIP AND MANAGEMENT
## AT RESOURCE KINDERGARTEN SCHOOL
## IN SVAY RIENG PROVINCE


ដោយ/BY

ញឹក កិត្យា/NHOEK KETYA


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល
ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២១-២០២៣


គ្រូណែនាំគោល៖ បណ្ឌិត សៀង សុវណ្ណា

គ្រូណែនាំរង៖ បណ្ឌិត ឆៀ សុផន

# សេចក្ដីអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានក្នុងខេត្តស្វាយរៀង**» សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់ខ្ញុំបាទ ទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្ដីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះ ពិតជាត្រូវបានស្រាវជ្រាវ និងចងក្រងដោយខ្ញុំបាទប្រាកដមែន។

ថ្ងៃសុក្រ ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៣

**ហត្ថលេខា**



**ញ៉ឹក ភិត្យា**

# លិខិតបញ្ជាក់

**បណ្ឌិត សៀង សុវណ្ណា** ជាគ្រូណែនាំគោល

**បណ្ឌិត ឆៀ សុផន** ជាគ្រូណែនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **ញ៉ឹក ភិត្យា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវស្តីពី «**ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានក្នុងខេត្តស្វាយរៀង**» ប្រាកដមែន។

ថ្ងៃសុក្រ ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៣

**បណ្ឌិត ឆៀ សុផន**

សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យ

ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**បណ្ឌិត សៀង សុវណ្ណា**

នាយកវិទ្យាស្ថានជាតិអប់រំ

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៦៤៧៣ **អយក.ខុទន**

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**យោង៖** - បទប្បញ្ញត្តិស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
- ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា ២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំផ្លូវកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ក្រសួង អយក | ប្រធាន |
| ២-ឯកឧត្តម | អ៊ុង បូរាត | ក្រសួង អយក | អនុប្រធាន |
| ៣-ឯកឧត្តម | ណាង សេងហាក់ | ក្រសួង អយក | សមាជិក |
| ៤-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរ.ភ្នំពេញ | សមាជិក |
| ៧-លោកបណ្ឌិត | នូវ វ៉ៅ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈួក ច័ន្ទឆាយា | នាយកដ្ឋានបវ. | សមាជិក |
| ១២-លោកបណ្ឌិត | នី វដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរ.ហិ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

លេខ ៤៥០១ អយក.វិចក

(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**យោង៖** - បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំដូរកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២. លោកស្រីបណ្ឌិត បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | អនុប្រធាន |
| ៣. លោកបណ្ឌិត កាន់ ពុទ្ធី | នា.បឋមសិក្សា អយក. | សមាជិក |
| ៤. លោក ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. លោកស្រី សាំង សុចិន្តា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦. លោកបណ្ឌិត មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ៧. លោកបណ្ឌិត អៃ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ៨. ឯកឧត្តមបណ្ឌិត ប៉ិច សៀង | វិ.បច្ចេកវិទ្យាកំពង់ឈើទាល | សមាជិក |
| ៩.លោកបណ្ឌិត លី គឹមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១០.លោក ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១.លោក លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២. លោកបណ្ឌិត អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣. លោកស្រី នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤. លោកស្រី បណ្ឌិត ឡឹយ សុខគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥. លោកបណ្ឌិត អ៊ឹម គឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦. លោកបណ្ឌិត ទី សុផល | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧. លោកបណ្ឌិត គួយ សុគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨. លោកបណ្ឌិត សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩. លោកបណ្ឌិត ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០. លោកបណ្ឌិត សឿង សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១. លោក ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | |
|---|---|---|
| ២២. លោកបណ្ឌិត សោភទ្រា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣. លោក ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤. លោក ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

លោក និងលោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិត នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរ.ហិ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

# សេចក្ដីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទសូមគោរពថ្លែងនូវការដឹងគុណដល់លោកឪពុក **ញ៉ឹក ឈុនឆាត** និងអ្នកម្ដាយ **ទុយ សុទ្ធា** ដែលលោកទាំងពីរបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន និងជំរុញលើកទឹកចិត្ត ខ្ញុំឱ្យសិក្សារៀនសូត្ររហូតមកដល់សព្វថ្ងៃនេះ។ ខ្ញុំបាទ ក៏សូមគោរពថ្លែងនូវការដឹងគុណ និងអរគុណផង ដែរ ដល់អ្នកម្ដាយមីងទាំងពីរ គឺម្ដាយមីង **ទុយ សោភា** និងម្ដាយមីង **ទុយ សុភាព** ដែលលោកទាំង ពីរបានទំនុកបម្រុងកន្លែងស្នាក់នៅ អាហារ ថវិកា និងការលើកទឹកចិត្ត ក្នុងរយៈពេលដែលខ្ញុំបាទសិក្សា រៀនសូត្រនៅរាជធានីភ្នំពេញ។

ខ្ញុំបាទ សូមគោរពថ្លែងអំណរគុណយ៉ាងក្រៃលែងដល់ក្រសួងអប់រំ យុវជន និងកីឡា និងវិទ្យាស្ថាន ជាតិអប់រំ ដែលបានផ្ដល់អាហារូបករណ៍ដល់រូបខ្ញុំបាទ សម្រាប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែក គ្រប់គ្រងអប់រំ ជំនាន់ទី១០ រយៈពេល២ឆ្នាំ នៅវិទ្យាស្ថានជាតិអប់រំ។

ខ្ញុំបាទ សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់**បណ្ឌិត សៀន សុវណ្ណា** នាយកវិទ្យា ស្ថានជាតិអប់រំ គណៈកម្មការគ្រប់គ្រងការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៃ វិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោក/លោកស្រីសាស្ត្រាចារ្យទាំងអស់ ដែលបានចំណាយពេលវេលាដ៏មាន តម្លៃ ដើម្បីផ្ទេរចំណេះដឹង បំណិន ឥរិយាបថ បទពិសោធន៍ និងមេរៀនជីវិតល្អៗជាច្រើន ពិសេសលើផ្នែក ដឹកនាំ និងគ្រប់គ្រង ការរៀបចំ និងធ្វើផែនការក្នុងវិស័យអប់រំ មកដល់ខ្ញុំបាទផ្ទាល់ និងមិត្តរួមជំនាន់ដទៃ ទៀតដូចៗគ្នា។

ម្យ៉ាងវិញទៀត ខ្ញុំបាទសូមគោរពថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្វាយរៀង ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកទាំង៦ នៅក្នុងខេត្តស្វាយរៀង ដែលមានសាលាមត្តេយ្យសិក្សាធនធាន និងគណៈគ្រប់គ្រងសាលាមត្តេយ្យសិក្សាធនធានទាំង៦ ដែល បានជួយសហការ សម្របសម្រួល ព្រមទាំងចំណាយពេលចូលរួមផ្ដល់ទិន្នន័យសម្រាប់ការស្រាវជ្រាវនេះ ធ្វើឱ្យការសិក្សាស្រាវជ្រាវសម្រេចបានលទ្ធផលល្អប្រសើរ និងទាន់ពេលវេលា។

បន្ទាប់មក ខ្ញុំបាទ សូមគោរពថ្លែងអំណរគុណជាអនេកប្បការដល់**បណ្ឌិត សៀង សុវណ្ណា** ជាគ្រូណែនាំគោល ដែលបានដឹកនាំក្នុងដំណើរការសរសេរនិក្ខេបបទ ពន្យល់ណែនាំលើខ្លឹមសាររួម បង្ហាញជាផែនទីគំនិត ក្រើនរំលឹក លើកទឹកចិត្ត ផ្តល់ជាឯកសារ និងចំណេះដឹងល្អៗ ព្រមទាំងបទពិសោធន៍នានាជំរុញដល់លទ្ធផលនៃការសរសេរនិក្ខេបបទស្តីពី **«ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានក្នុងខេត្តស្វាយរៀង»** របស់ខ្ញុំបាទ ឱ្យទទួលបានជោគជ័យ និងជានាបាននូវគុណភាពនៃការបណ្តុះបណ្តាល។ ខ្ញុំបាទ ក៏សូមគោរពថ្លែងអំណរគុណផងដែរដល់**បណ្ឌិត ឆៀ សុផន** ជាគ្រូណែនាំរង ដែលតែងតែផ្តល់កិច្ចគាំទ្រ ចំណេះដឹង ចែករំលែកបទពិសោធន៍ និងពន្យល់ណែនាំចំណុចគន្លឹះល្អៗ ក្នុងការសរសេរនិក្ខេបបទ ដល់ខ្ញុំបាទ រហូតដល់សម្រេចបានលទ្ធផលល្អប្រសើរ។

មួយវិញទៀត ខ្ញុំបាទសូមថ្លែងនូវការដឹងគុណចំពោះឧត្តមភរិយា **ហ៊ុន សុវណ្ណថាវី** និងកូនប្រុស កូនស្រីទាំងពីរជាទីស្រឡាញ់របស់ខ្ញុំគឺកូនប្រុស**ហេង ឧឡ្ហិការណ៍** និងកូនស្រី**ហេង ទេវីសារ** ដែលបានផ្តល់ពេលវេលា ថវិកា និងផ្តល់កម្លាំងចិត្ត ឱ្យខ្ញុំបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ រហូតបានសរសេរបញ្ចប់និក្ខេបបទ ហើយការពារទទួលបានជោគជ័យ និងសូមអរគុណមិត្តទាំងអស់ ដែលតែងតែផ្តល់ការលើកទឹកចិត្ត ចែករំលែកចំណេះដឹង បទពិសោធន៍ និងព័ត៌មានល្អៗដល់ខ្ញុំបាទ។

ជាទីបញ្ចប់ ខ្ញុំបាទ សូមប្រសិទ្ធពរជ័យ ជូនចំពោះឯកឧត្តម លោក/លោកស្រីសាស្ត្រាចារ្យ លោក/លោកស្រី អ្នកនាងកញ្ញា និងមិត្តរួមជំនាន់ទាំងអស់ សូមទទួលបាននូវព្រះពុទ្ធពរទាំង៤ប្រការ គឺ **អាយុ វណ្ណៈ សុខៈ និងពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**!

# មូលន័យសង្ខេប

គោលបំណងនៃការសិក្សាស្រាវជ្រាវគឺដើម្បីរកឱ្យឃើញពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជានក្នុងខេត្តស្វាយរៀង និងរកឱ្យឃើញពីបញ្ហាប្រឈមនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជានទាំងនោះ។ សំណួរស្រាវជ្រាវមានចំនួនពីរ ត្រូវបានលើកឡើង។ ដើម្បីសម្រេចបាននូវគោលបំណងនេះ អ្នកសិក្សាស្រាវជ្រាវបានធ្វើការស្ទង់មតិតាមរយៈកម្រងសំណួរបំពេញ និងសម្ភាសន៍ដែលជាវិធីសាស្ត្រចម្រុះ (បរិមាណវិស័យ និងគុណវិស័យ) ក្នុងការប្រមូលទិន្នន័យ។ អ្នកចូលរួមឆ្លើយសរុប៤៤នាក់ ត្រូវបានជ្រើសរើសដោយមិនចៃដន្យចេញពីសាលាមត្តេយ្យសិក្សាធនជានចំនួន៦ ក្នុងនោះគណៈគ្រប់គ្រងសាលារៀន៦នាក់ គ្រូបង្រៀន៣២នាក់ និងគណៈកម្មការគ្រប់គ្រងសាលារៀន៦នាក់។ ដើម្បីសិក្សាប្រធានបទនេះបានជោគជ័យ អ្នកស្រាវជ្រាវបានធ្វើការវិភាគទិន្នន័យដោយប្រើកម្មវិធី Excel និងបកស្រាយតាមក្រាហ្វ។

លទ្ធផលបានបង្ហាញឱ្យឃើញថា ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជានក្នុងខេត្តស្វាយរៀង ក្នុងក្របខ័ណ្ឌទូទាំងខេត្តពុំទាន់បានល្អនៅឡើយទេ ពោលគឺស្ថិតក្រោមស្តង់ដាសាលារៀនគម្រូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដោយលទ្ធផលជារួមតម្លៃមធ្យម (Mean) គឺ២.៣២ គម្លាតស្តង់ដា (SD) គឺ0.0៨ ក្នុងនោះស្តង់ដាទី១ ផលសម្រេចអប់រំ និងការសិក្សារបស់សិស្ស សម្រេចបានលទ្ធផលតម្លៃ Mean=១.៧៩, SD=0.0៥ ស្តង់ដាទី២ ថ្នាក់រៀនមានដំណើរការសម្រាប់ការបង្រៀន និងរៀនសម្រេចបានលទ្ធផលតម្លៃ Mean=២.៦១, SD=0.២២ ស្តង់ដាទី៣ ភាពជាម្ចាស់នៃសហគមន៍សាលារៀន សម្រេចបានលទ្ធផលតម្លៃ Mean=១.៩៣, SD=0.0៦ ស្តង់ដាទី៤ រដ្ឋបាល និងដំណើរការសាលារៀន សម្រេចបានលទ្ធផលតម្លៃ Mean=២.៧៨, SD=0.0៥ និងស្តង់ដាទី៥ គណនេយ្យភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រេចបានលទ្ធផលតម្លៃម Mean=២.៤៩, SD=0.0៧។

លទ្ធផលនៃការស្រាវជ្រាវនេះក៏បានបង្ហាញឱ្យឃើញផងដែរនូវកត្តាចម្បងៗចំនួន៣ដែលនាំឱ្យស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជានក្នុងខេត្តស្វាយរៀង ស្ថិតក្រោមស្តង់ដាសាលារៀនគំរូ៖ ១. សមត្ថភាព ដោយអ្នកចូលរួម៧0% បានលើកឡើងថា ស្តង់ដាសាលារៀនគំរូ ជា

ការងារថ្មី និងមិនទាន់ទទួលបានការបំប៉នសមត្ថភាពឱ្យបានសមស្របនៅឡើយ (២) ខ្វះការចូលរួមពីភាគីពាក់ព័ន្ធ ដោយសំណាក៦១% បញ្ជាក់ថាការចូលរួមគាំទ្ររបស់អាជ្ញាធរមូលដ្ឋាន និងសហគមន៍មានចំនួនតិចតួច ហើយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង/ស្រុក ចូលរួមតិចតួចលើការចុះពិនិត្យតាមដាន វាយតម្លៃ និងផ្តល់ជាអនុសាសន៍ផ្សេង (៣) ធនធាន(មនុស្ស សម្ភារ ថវិកា)។ សំណាក៦៦% បានលើកឡើងពីការខ្វះខាតគ្រូភាសាអង់គ្លេស គ្រូបច្ចេកវិទ្យា ICT សម្ភារដំណើរការកម្មវិធីផ្សេងៗ ជាពិសេសថវិកាអភិវឌ្ឍន៍ក៏នៅមានចំនួនមិនសមស្របទៅនឹងតម្រូវការជាក់ស្តែង។

សរុបសេចក្តីមក ដើម្បីឱ្យស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានដំណើរការទៅបានល្អ ជាប់ស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ នាយកដ្ឋានអប់រំកុមារតូច គួរតែពិនិត្យតាមដាន និងវាយតម្លៃឱ្យបានជាប់លាប់និងជាក់លាក់ ព្រមទាំងមានកម្មវិធីបំប៉នសមត្ថភាពជាប្រចាំដល់ថ្នាក់ក្រោមជាតិ ពិសេសគឺគណៈគ្រប់គ្រងសាលារៀន។ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត គួរមានកម្មវិធីច្បាស់លាស់ក្នុងការពិនិត្យតាមដាន និងវាយតម្លៃ ព្រមទាំងបើកវគ្គបំប៉នសមត្ថភាពដល់គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន។ អាជ្ញាធរមូលដ្ឋាន និងសហគមន៍ គួរចូលរួមសហការគៀរគរសប្បុរសជនគាំទ្រការអភិវឌ្ឍសាលារៀន ដើម្បីសម្រេចបានតាមស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សា។

# Abstract

The main objective of this research is to discover the situation of leadership and management at Resource Kindergarten School in Svay Rieng province and challenges in leadership and management of those Resources Kindergarten School.

In this research there are two questions are mentioned in order to achieve this objective the researcher has surveyed through filling-questionnaire lists and direct interviews that are the mixed methods (quantitative and qualitative) in data collections. There are 44 participants are chosen not by chance from 6 resource kindergarten schools within 6 people form school management team, 32 teachers and 6 people from school committee. To succeed in this research the researcher analysis data by using Microsoft excel and graphical analysis.

The result showed that the situation of leadership and management at Resource Kindergarten School in the rest of Svay Rieng province is not better yet. It is under standard of modal schools for public kindergartens with the joint results in Mean is 2.32, Standard Deviation(SD) is 0.08, in 1$^{st}$ standard, Educational achievement and students' learning achievement that showed result in Mean = 1.79, Standard Deviation (SD) =0.05; 2$^{nd}$ standard: Classroom exists in teaching processing and learning achievement that showed result in Mean= 2.61, Standard Deviation (SD)=0.22; 3$^{rd}$ standard is ownership of community school that showed result in Mean=1.93, Standard Deviation(SD)=0.06; 4$^{th}$ standard: Administration and school processing that showed result in Mean=2.78, Standard Deviation (SD)= 0.05 and 5$^{th}$ standard: National and Sub-nation accountability that showed result in Mean = 2.49, Standard Deviation (SD) = 0.07

The result of this research is also presented the three main factors that caused the situation of leadership and management at Resource Kindergarten School in Svay Rieng province is under the standard of modal schools: (1) Participants 70% mentioned that standard of modal school is the new task and not yet provided capacity building to apply (2) lacking of participation form stakeholders from sample size is 61 % identified that the participation of local authority and community in small amount, so that the Department of Education, Youth and Sport of Svay Rieng Province and City/District Educational, Youth and Sport Office low participated in monitoring, evaluating and other recommendations (3) Resources (people, equipment and budget). 66 % sample size has showed the shortages of English teachers, ICT teachers and other educational program materials, especially, developing budget is not accurate to actual demand.

In conclusion, to improve the situation of leadership and management at Resource Kindergarten School acknowledged as the modal schools for public Kindergarten required all stakeholders´ participations. Department of Early Childhood Education should monitor and evaluate accurately, regularly and other capacity buildings to sub-nations, particularly school management team.

Department of Education, Youth and Sport, should have clear educational program in Monitoring and Evaluation (M&E) and provide capacity building to all school management team and teachers, either. Local authorities and community should join in gathering long-lasting charity people to support schools to achieve the standard of modal schools for Kindergarten Educational Resources.

# មាតិកា


សេចក្តីអះអាងរបស់បេក្ខជន ............ i

លិខិតបញ្ជាក់ ............ ii

លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ ............ iii

សេចក្តីថ្លែងអំណរគុណ ............ vii

មូលន័យសង្ខេប ............ iix

Abstract ............ xi

មាតិកា ............ xiii

បញ្ជីក្រាហ្វ ............ xxi

ជំពូក១ ............ ២

សេចក្តីផ្តើម ............ ២

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ............ ២

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ............ ៨

១.៣ គោលបំណងនៃការស្រាវជ្រាវ ............ ១២

១.៤ សំណួរស្រាវជ្រាវ ............ ១២

១.៥ សារៈសំខាន់នៃការស្រាវជ្រាវ ............ ១២

១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ............ ១៣

១.៦.១ វិសាលភាព ............ ១៣

១.៦.២ ដែនកំណត់ ............ ១៣

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ................................................................................................ ១៤
ជំពូក២ ...................................................................................................................១៧
រំលឹកទ្រឹស្តី.....................................................................................................................១៧
២.១ និយមន័យ ..........................................................................................................១៧
២.២ ចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០០-២០១៥............ ១៩
២.២.១ គោលដៅអប់រំជាតិ ២០០០-២០១៥ ..................................................................២០
២.២.២ គោលដៅអប់រំចំណេះទូទៅ ២០០០-២០១៥.........................................................២១
២.៣ ក្របខណ្ឌនៃការអភិវឌ្ឍជាតិ.................................................................................... ២៣
២.៣.១ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០.......................... ២៣
២.៣.២ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ........................................................... ២៣
២.៣.៣ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា................២៦
២.៣.៤ គោលដៅនៃការអប់រំជាតិ២០១៦-២០៣០ ......................................................... ២៧
២.៣.៥ ចក្ខុវិស័យ បេសកកម្ម របស់ក្រសួងអប់រំ យុវជន និងកីឡា ២០១៦-២០៣០.............៣០
២.៣.៦ គោលនយោបាយអប់រំរយៈពេលមធ្យម ..............................................................៣១
២.៤ ផែនការអនុវិស័យ ការអប់រំកុមារតូចឆ្នាំ២០១៩-២០២៣ ............................................ ៣២
២.៤.១ សាវតារ ........................................................................................................ ៣២
២.៤.២ វត្ថុបំណង ..................................................................................................... ៣៣
២.៤.៣ សកម្មភាពគោលនយោបាយ.............................................................................. ៣៣
២.៤.៤ យុទ្ធសាស្ត្រ និងសកម្មភាព...............................................................................៣៤

២.៤.៤.១ វត្ថុបំណងអនុវិស័យទី១៖ បង្កើនលទ្ធភាពទទួលបានសេវាអប់រំកុមារតូចប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ........ ៣៤

២.៤.៤.២ វត្ថុបំណងអនុវិស័យទី២៖ បន្តអភិវឌ្ឍសាលាមត្តេយ្យសិក្សាឱ្យស្របតាមស្តង់ដាគុណភាព ........ ៣៦

២.៤.៤.៣ វត្ថុបំណងអនុវិស័យទី៣៖ ពង្រឹងសមត្ថភាពអ្នកគ្រប់គ្រងអនុវិស័យអប់រំកុមារតូចនិងអនុវត្តការគ្រប់គ្រងតាមសាលារៀន ........ ៣៨

២.៥ ស្តង់ដានាយកសាលារៀន ........ ៣៩

២.៥.១ ស្តង់ដាទី១៖ កម្រិតវប្បធម៌ និងបទពិសោធន៍ ........ ៣៩

២.៥.២ ស្តង់ដាទី២៖ សមត្ថភាព និងគុណសម្បត្តិរបស់នាយកសាលារៀន ........ ៣៩

២.៥.៣ ស្តង់ដាទី៣៖ បំណិនត្រិះរិះពិចារណា និងនវានុវត្តន៍ ........ ៤១

២.៥.៤ ស្តង់ដាទី៤៖ ភាពជាអ្នកដឹកនាំគ្រប់គ្រងរដ្ឋបាលសាលារៀន ........ ៤២

២.៥.៥ ស្តង់ដាទី៥៖ ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា និងការបង្រៀននិងរៀន ........ ៤៤

២.៥.៦ ស្តង់ដាទី៦៖ ការផ្សារភ្ជាប់សាលារៀន និងសហគមន៍ ........ ៤៦

២.៦ ទម្រង់នៃកំណែទម្រង់សាលារៀន ........ ៤៨

២.៦.១ សាលារៀនជំនាន់ថ្មី ........ ៤៩

២.៦.២ សាលារៀនគំរូ ........ ៥០

២.៦.២.១ ស្តង់ដាទី១ សាលារៀនដំណើរការសម្រេចផលសម្រេចការអប់រំ និងការសិក្សារៀនសូត្ររបស់សិស្ស ........ ៥០

២.៦.២.២ ស្តង់ដាទី២ សាលារៀនដំណើរការសម្រាប់ការបង្រៀន និងការសិក្សារៀនសូត្ររបស់សិស្សម្នាក់ៗ ........ ៥១

២.៦.២.៣ ស្តង់ដាទី៣ គឺការចូលរួមរបស់សហគមន៍និងមាតាបិតា នៅក្នុងការគ្រប់គ្រង និង ដំណើរការសាលារៀន ..... ៥១

២.៦.២.៤ ស្តង់ដាទី៤ គឺដំណើរការប្រតិបត្តិការ និងរដ្ឋបាលសាលារៀន ..... ៥២

២.៦.២.៥ ស្តង់ដាទី៥ គឺគណនេយ្យភាព ..... ៥២

ជំពូក៣ ..... ៥៥

វិធីសាស្ត្រស្រាវជ្រាវ ..... ៥៥

៣.១ គម្រោងវិភាគ ..... ៥៥

៣.២ ការប្រមូលទិន្នន័យ ..... ៥៥

៣.៣ ឧបករណ៍ស្រាវជ្រាវ ..... ៥៦

៣.៤ ការជ្រើសរើសភាគសំណាក ..... ៥៧

៣.៥ ការវិភាគទិន្នន័យ ..... ៥៩

ជំពូក៤ ..... ៦១

លទ្ធផល និងការពិភាក្សា ..... ៦១

៤.១. ការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ..... ៦១

៤.១.១ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានទាំង៥ស្តង់ដា ក្នុងក្របខ័ណ្ឌទូទាំងខេត្ត ..... ៦១

៤.១.១.១ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី១.៦៣

៤.១.១.២ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី២ ៦៥

៤.១.១.៣ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៣ ៦៦

៤.១.១.៤ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី៤.៦៩

៤.១.១.៥ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី៥.៧១

៤.១.២ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រង នៅសាលាមត្តេយ្យសិក្សាធនជានទាំង៥ស្តង់ដាផ្អែកលើគណៈគ្រប់គ្រងសាលារៀន ........ ៧២

៤.១.២.១ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី១ ផ្អែកលើគណៈគ្រប់គ្រងសាលារៀន........ ៧៤

៤.១.២.២ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី២ ផ្អែកលើគណៈគ្រប់គ្រងសាលារៀន........ ៧៥

៤.១.២.៣ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី៣ ផ្អែកលើគណៈគ្រប់គ្រងសាលារៀន........ ៧៧

៤.១.២.៤ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី៤ ផ្អែកលើគណៈគ្រប់គ្រងសាលារៀន........ ៧៩

៤.១.២.៥ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី៥ ផ្អែកលើគណៈគ្រប់គ្រងសាលារៀន........ ៨១

៤.១.៣ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជានទាំង៥ស្តង់ដា ផ្អែកលើគ្រូបង្រៀន ........ ៨២

៤.១.៣.១ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី១ ផ្អែកលើគ្រូបង្រៀន ........ ៨៤

៤.១.៣.២ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី២ ផ្អែកលើគ្រូបង្រៀន ........ ៨៥

៤.១.៣.៣ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី៣ ផ្អែកលើ គ្រូបង្រៀន ........ ៨៧
៤.១.៣.៤ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី៤ ផ្អែកលើ គ្រូបង្រៀន ........ ៨៩
៤.១.៣.៥ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី៥ ផ្អែកលើ គ្រូបង្រៀន ........ ៩១
៤.១.៤ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជានទាំង៥ស្តង់ដា ផ្អែកលើ គណៈកម្មការគ្រប់គ្រងសាលារៀន ........ ៩២
៤.១.៤.១ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី១ ផ្អែកលើ គណៈកម្មការគ្រប់គ្រងសាលារៀន ........ ៩៤
៤.១.៤.២ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី២ ផ្អែកលើ គណៈកម្មការគ្រប់គ្រងសាលារៀន ........ ៩៥
៤.១.៤.៣ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី៣ ផ្អែកលើ គណៈកម្មការគ្រប់គ្រងសាលារៀន ........ ៩៧
៤.១.៤.៤ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី៤ ផ្អែកលើ គណៈកម្មការគ្រប់គ្រងសាលារៀន ........ ៩៩
៤.១.៤.៥ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី៥ ផ្អែកលើ គណៈកម្មការគ្រប់គ្រងសាលារៀន ........ ១០១
៤.២ បញ្ហាប្រឈម និងដំណោះស្រាយ ........ ១០២

៤.២.១ បញ្ហាប្រឈមនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានទាំង៥ស្តង់ដា ........ ១០៣

៤.២.១.១ បញ្ហាប្រឈមនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី១ ........ ១០៤

៤.២.១.២ បញ្ហាប្រឈមនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី២ ........ ១០៦

៤.២.១.៣ បញ្ហាប្រឈមនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៣ ........ ១០៧

៤.២.១.៤ បញ្ហាប្រឈមនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៤ ........ ១០៨

៤.២.១.៥ បញ្ហាប្រឈមនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៥ ........ ១០៩

៤.២.២ ដំណោះស្រាយលើការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន........ ១១០

៤.២.២.១ សមត្ថភាព........ ១១០

៤.២.២.២ ការចូលរួមពីភាគីពាក់ព័ន្ធ........ ១១០

៤.២.២.៣ ធនធាន(មនុស្ស សម្ភារ ថវិកា) ........ ១១១

៤.២.៣ ការពិភាក្សា........ ១១១

ជំពូក៥ ........ ១១៤

សេចក្តីសន្និដ្ឋាន និងសំណូមពរ........ ១១៤

៥.១. សេចក្តីសន្និដ្ឋាន ........ ១១៤

៥.២ សំណូមពរ ........ ១១៨

៥.២.១ នាយកដ្ឋានអប់រំកុមារតូច ........ ១១៩

៥.២.២ មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ........ ១១៩

៥.២.៣ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង-ស្រុក-ខណ្ឌ ........ ១២០

៥.២.៤ សាលារៀន ........ ១២០

៥.២.៥ សហគមន៍ ........ ១២០

ឯកសារយោង ........ ១២២

ឧបសម្ព័ន្ធ ទី១៖ លិខិតបង្គាប់ការរបស់គណៈកម្មការការពារនិក្ខេបបទ ........ ១២៥

ឧបសម្ព័ន្ធ ទី២៖ លិខិតចាត់តាំងគ្រូណែនាំគោល និងគ្រូណែនាំរង សម្រាប់ការសរសេរនិក្ខេបបទ ១៣៤

ឧបសម្ព័ន្ធ ទី៣៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា ........ ១៣៦

ឧបសម្ព័ន្ធ ទី៤៖ លិខិតអនុញ្ញាតរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង ........ ១៣៩

ឧបសម្ព័ន្ធ ទី៥៖ កម្រងសំណួរ ........ ១៣៩

# បញ្ជីក្រាហ្វ

*ក្រាហ្វទី១៖ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ក្នុងក្របខ័ណ្ឌទូទាំងខេត្ត ................................ ៦១*

*ក្រាហ្វទី២៖ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី១.........៦៣*

*ក្រាហ្វទី៣៖ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី២ ........ ៦៥*

*ក្រាហ្វទី៤៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៣.............. ៦៦*

*ក្រាហ្វទី៥៖ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៤......... ៦៩*

*ក្រាហ្វទី៦៖ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៥.........៧១*

*ក្រាហ្វទី៧៖ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានទាំង៥ស្តង់ដា ផ្អែកលើគណៈគ្រប់គ្រងសាលារៀន ................................ ៧២*

*ក្រាហ្វទី៨៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី១ ផ្អែកលើ គណៈគ្រប់គ្រងសាលារៀន................................៧៤*

*ក្រាហ្វទី៩៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី២ ផ្អែកលើ គណៈគ្រប់គ្រងសាលារៀន................................៧៥*

*ក្រាហ្វទី១០៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៣ ផ្អែកលើគណៈគ្រប់គ្រងសាលារៀន................................ ៧៧*

*ក្រាហ្វទី១១៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៤ ផ្អែកលើគណៈគ្រប់គ្រងសាលារៀន................................៧៩*

ក្រាហ្វទី១២៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាជនជាន ស្តង់ដាទី៥ ផ្អែកលើ គណៈគ្រប់គ្រងសាលារៀន ........ ៨១
ក្រាហ្វទី១៣៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាជនជានទាំង៥ស្តង់ដា ផ្អែកលើ គ្រូបង្រៀន ........ ៨២
ក្រាហ្វទី១៤៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាជនជាន ស្តង់ដាទី១ ផ្អែកលើ គ្រូបង្រៀន ........ ៨៤
ក្រាហ្វទី១៥៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាជនជាន ស្តង់ដាទី២ ផ្អែកលើ គ្រូបង្រៀន ........ ៨៥
ក្រាហ្វទី១៦៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាជនជាន ស្តង់ដាទី៣ ផ្អែកលើ គ្រូបង្រៀន ........ ៨៧
ក្រាហ្វទី១៧៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាជនជាន ស្តង់ដាទី៤ ផ្អែកលើ គ្រូបង្រៀន ........ ៨៩
ក្រាហ្វទី១៨៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាជនជាន ស្តង់ដាទី៥ ផ្អែកលើ គ្រូបង្រៀន ........ ៩១
ក្រាហ្វទី១៩៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាជនជានទាំង៥ស្តង់ដា ផ្អែកលើ គណៈកម្មការគ្រប់គ្រងសាលារៀន ........ ៩២
ក្រាហ្វទី២០៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាជនជាន ស្តង់ដាទី១ ផ្អែកលើ គណៈកម្មការគ្រប់គ្រងសាលារៀន ........ ៩៤
ក្រាហ្វទី២១៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាជនជាន ស្តង់ដាទី២ ផ្អែកលើ គណៈកម្មការគ្រប់គ្រងសាលារៀន ........ ៩៦

ក្រាហ្វទី២២៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៣ ផ្អែកលើគណៈកម្មការគ្រប់គ្រងសាលារៀន ........................................................................................ ៩៧

ក្រាហ្វទី២៣៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៤ ផ្អែកលើគណៈកម្មការគ្រប់គ្រងសាលារៀន ........................................................................................ ៩៩

ក្រាហ្វទី២៤៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៥ ផ្អែកលើគណៈកម្មការគ្រប់គ្រងសាលារៀន ...................................................................................... ១០១

ក្រាហ្វទី២៥៖ បញ្ហាប្រឈមនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានទាំង៥ស្តង់ដា.. ១០៤

ក្រាហ្វទី២៦៖ បញ្ហាប្រឈមនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី១ .... ១០៥

ក្រាហ្វទី២៧៖ បញ្ហាប្រឈមនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី២.... ១០៦

ក្រាហ្វទី២៨៖ បញ្ហាប្រឈមនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៣.... ១០៧

ក្រាហ្វទី២៩៖ បញ្ហាប្រឈមនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៤ .... ១០៨

ក្រាហ្វទី៣០៖ បញ្ហាប្រឈមនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៥ .... ១០៩

# ជំពូក១

# សេចក្តីផ្តើម

# ជំពូក១

# សេចក្តីផ្តើម

នៅក្នុងជំពូកនេះ នឹងធ្វើការរៀបរាប់បង្ហាញអំពីសេចក្តីផ្តើមនៃការស្រាវជ្រាវ ដោយពន្យល់បកស្រាយអំពីមូលហេតុ និងលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិសាលភាពនិងដែនកំណត់នៃការស្រាវជ្រាវ ព្រមទាំងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្ន ប្រទេសកម្ពុជាយើង មានសុខសន្តិភាពពេញបរិបូរណ៍ គ្រប់គ្រងបាននូវស្ថិរភាព នយោបាយ និងជំរុញបាននូវល្បឿននៃការអភិវឌ្ឍប្រកបដោយក្តីសង្ឃឹមទៅអនាគត ដោយសារការអនុវត្តគោលនយោបាយដ៏ឈ្លាសវៃរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ ការខិតខំកសាងបាននូវរដ្ឋបាលឯកភាពមួយរបស់ជាតិជំរុញឱ្យមានការកែទម្រង់លើគ្រប់វិស័យ ពិសេស វិស័យអប់រំ យុវជន និងកីឡាដែលកំពុងតែបន្តបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពជំនាញគ្រប់គ្រងដល់មន្ត្រីរាជការថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត ដើម្បីបន្តអនុវត្តគោលនយោបាយកំណែទម្រង់រដ្ឋបាលរបស់រាជរដ្ឋាភិបាល ឱ្យកាន់តែជោគជ័យបន្ថែមទៀត (រាជរដ្ឋាភិបាលកម្ពុជា, ២០១៨ (យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤); រាជរដ្ឋាភិបាលកម្ពុជា,២០២៣ (យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១))។

ក្នុងគោលបំណងបម្រើប្រជាជនឱ្យកាន់តែល្អប្រសើរឡើង និងដើម្បីសុខមាលភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងវិបុលភាពរបស់ប្រទេសជាតិ រាជរដ្ឋាភិបាល សហគមន៍ គ្រួសារ បាននឹងកំពុងបន្ត កសាងសាលារៀនឱ្យខិតជិតលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ ផ្តល់ឱកាស និងភាពងាយស្រួលដល់កុមារចូលរៀនក្នុងភូមិសាស្ត្រសិក្សានីមួយៗ។ នាយកសាលា និងគ្រូបង្រៀនគឺជាអ្នកដឹកនាំបណ្តុះបណ្តាលកុមារជាទីស្រឡាញ់ ដែលមានតម្លៃមិនអាចកាត់ថ្លៃបាន សម្រាប់គ្រួសារ និងប្រទេសជាតិ។ ពួកគេត្រូវតែក្លាយទៅជាមនុស្សពេញលេញ រីក

ចម្រើនព្រមៗគ្នា ដោយមានតុល្យភាពរវាងប្រាជ្ញាស្មារតី សញ្ចេតនា និងរូប រាង្គកាយ ពោលគឺជាមនុស្ស មានចំណេះដឹង ចំណេះធ្វើ និងមានកាអភិវឌ្ឍបុគ្គលិកលក្ខណៈជាវិជ្ជមាននិងជាប្រចាំ (ក្រសួង អ.យ.ក. ,២០១៦ ក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស។

សេចក្តីសង្ឃឹមដ៏រស់រវើកសម្រាប់គ្រួសារ និងប្រទេសជាតិគឺកុមារ។ ដូចនេះ តម្លៃរបស់កុមារមិនអាចខ្វះបានទេនៅក្នុងដំណើរការកសាងប្រទេសជាតិមួយឱ្យរឹងមាំ។ គ្រួសារណាគ្មានកុមារ គឺជាគ្រួសារគ្មានក្តីសង្ឃឹម។ ប្រទេសជាតិណាដែលមានកុមារមិនបានទទួលការអប់រំ ប្រទេសជាតិនោះមានអនាគតខ្មៅងងឹត និងគ្មានការអភិវឌ្ឍ។ ការអប់រំនៅកម្ពុជាថ្ងៃនេះយ៉ាងណា កម្ពុជាថ្ងៃស្អែកក៏យ៉ាងនោះដែរ (នី រដ្ឋា, ២០២២)។

នៅក្នុងនីតិកាលទី៦ នៃរដ្ឋសភា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសដាក់ចេញនៅក្នុងខែកញ្ញា ឆ្នាំ២០១៨ នូវ «យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤» ដោយបានបន្តផ្តោតការយកចិត្តទុកដាក់លើ «វិស័យអាទិភាព ៤» និងតម្កល់ «មនុស្ស» ជាអាទិភាពទី១ លើគេ។ ក្នុងន័យនេះ វិស័យអប់រំ ត្រូវបានចាត់ទុកជាវិស័យគន្លឹះ សម្រាប់ការឈានឡើងនៃការអភិវឌ្ឍសេដ្ឋកិច្ចក្នុងដំណាក់កាលថ្មី ពិសេសការឈានទៅសម្រេចបានប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងក្លាយទៅជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០ (រាជរដ្ឋាភិបាលកម្ពុជា, ២០១៨)។

ឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ដែលបានចាត់ទុកការអភិវឌ្ឍធនធានមនុស្សជាអាទិភាពទី១ ក្រសួងអប់រំ យុវជន និងកីឡា ប្តេជ្ញាសម្រេចឱ្យបាននូវមុំទី១ ស្តីពី «ការពង្រឹងគុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា» ផ្តោតអាទិភាពលើ ១) ការយកចិត្តទុកដាក់លើគ្រូបង្រៀន ២) ការពង្រឹងវិសាលភាពសាលារៀនគ្រប់កម្រិត ៣) ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលារៀន ៤) ការជំរុញការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ៥) ការអប់រំបំណិនឱ្យស្របតាមទីផ្សារការងារ ៦) ការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលគ្រប់ជ្រុងជ្រោយ និងទី ៧) ការត្រៀមប្រកួតកីឡាស៊ីហ្គេម ឆ្នាំ២០២៣ ដែលទើបតែបញ្ចប់ការប្រកួតកាលពីពាក់កណ្តាលខែឧសភា ឆ្នាំ២០២៣ កន្លងទៅ

ក្នុងនាមកម្ពុជាជាម្ចាស់ផ្ទះ។ ដើម្បីឆ្ពោះទៅសម្រេចបាននូវគោលដៅឆ្នាំ២០៣០ ក្រសួងអប់រំ យុវជន និងកីឡា ប្តេជ្ញាសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ស្តីពីការអប់រំ ដោយឈរលើគោលការណ៍ គុណភាព សមធម៌ បរិយាបន្ន ការសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា។ ម្យ៉ាងទៀត ក្រសួងបន្តកាត់បន្ថយគម្លាតជំនាញដោយសហការជាមួយអ្នកពាក់ព័ន្ធ ក្នុងការបង្កើនការផ្គត់ផ្គង់ជំនាញដែលមានតម្រូវការខ្ពស់ក្នុងវិស័យអាទិភាពមួយចំនួន និងបានដាក់ចេញនូវការអប់រំតាមបែបឌីជីថលដើម្បីឆ្លើយតបទៅនឹងគោលនយោបាយនិងទិសដៅសេដ្ឋកិច្ចឌីជីថលកម្ពុជា។

ឈរលើមូលដ្ឋាននេះ ក្រសួងបានកំណត់គោលនយោបាយចំនួនពីរគឺ៖ ១) ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា និងទី២) ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ (អ.យ.ក., ២០១៩)។

លើសពីនេះទៅទៀត គោលនយោបាយស្តីពីគ្រូបង្រៀនបានកំណត់ចក្ខុវិស័យ កសាងគ្រូបង្រៀនឱ្យមានចំណេះដឹង ជំនាញ សីលធម៌ និងមានសមត្ថភាពអនុវត្តវិជ្ជាជីវៈ ដោយមានការទទួលស្គាល់ពីសង្គម។

ដើម្បីសម្រេចបានចក្ខុវិស័យនេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញ យុទ្ធសាស្ត្រជាច្រើន ក្នុងនោះក៏មានការពង្រឹងប្រសិទ្ធភាពជាអ្នកដឹកនាំសាលារៀនផងដែរ (អ.យ.ក.,២០១៧)។ ក្នុងក្របខ័ណ្ឌផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនបានបង្ហាញពីការពង្រឹងយន្តការ ភាពជាអ្នកដឹកនាំសាលារៀនឱ្យមានប្រសិទ្ធភាព ដែលសំដៅលើការពង្រឹងសមត្ថភាពនាយកសាលារៀន ដើម្បីធ្វើឱ្យប្រសើរឡើងនូវការងារគ្រប់គ្រង និងដឹកនាំ (អ.យ.ក., ២០១៥)។ ក្នុងន័យនេះ កំណែទម្រង់អប់រំនាពេលបច្ចុប្បន្ន ផ្តោតទៅលើការពង្រឹងការគ្រប់គ្រងសាលារៀន ការពង្រឹងគុណភាពគ្រូ និងការកែលម្អការបង្រៀន និងការរៀន ដោយផ្តល់ឱ្យសាលារៀននូវស្វ័យភាពហិរញ្ញវត្ថុ និងការទទួលខុសត្រូវចំពោះលទ្ធផលសិក្សារបស់សិស្ស។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការខាងលើនេះ ក្នុងការអនុវត្តកំណែទម្រង់វិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡា បាន

បង្កើតនូវស្តង់ដាសាលារៀន ស្តង់ដាគ្រូបង្រៀន និងស្តង់ដានាយកសាលារៀន។ ចំពោះការបង្កើតស្តង់ដានាយកសាលារៀន គឺតម្រូវឱ្យនាយកសាលារៀនមានគុណវុឌ្ឍិគ្រប់គ្រាន់ មានសមត្ថភាពខាងការគិតបែបយុទ្ធសាស្ត្រនិងនវានុវត្តន៍ មានភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរដ្ឋបាលសាលារៀន ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សានិងការបង្រៀន និងការរៀនតាមបែបបរិបទថ្មីនៃសតវត្សរ៍ទី២១ ក្នុងគោលដៅជំរុញឱ្យគណៈគ្រប់គ្រងសាលារៀនមានលទ្ធភាពអភិវឌ្ឍខ្លួនពេញមួយជីវិត មានលទ្ធភាពដោះស្រាយបញ្ហាប្រឈមថ្មីៗប្រកបដោយឧត្តមភាព និងចេះផ្សារភ្ជាប់សាលារៀនទៅនឹងសហគមន៍ (អ.យ.ក., ២០១៧)។

ការស្រាវជ្រាវកម្រិតអន្តរជាតិជាច្រើនបានបង្ហាញថា ការគាំពារនិងអភិវឌ្ឍន៍កុមារតូចក្នុងឆ្នាំដំបូងៗមានសារៈសំខាន់ណាស់ សម្រាប់ការអភិវឌ្ឍនៅពេលបន្តបន្ទាប់ទៀតក្នុងជីវិត។ ការវិនិយោគលើធនធានមនុស្ស សម្រាប់កុមារស្ថិតក្នុងវ័យចូលរៀននៅមត្តេយ្យសិក្សា គឺផ្តល់នូវផលត្រឡប់មកវិញខ្ពស់បំផុត (World Bank, 2010)។ ផ្អែកតាមលោក James Heckman អន្តរាគមន៍កុមារតូចជាច្រើន ជួយបង្កើតជំនាញ ដែលមិនពាក់ព័ន្ធជាមួយពុទ្ធិបញ្ញា និងការជំរុញលើកទឹកចិត្ត។ អន្តរាគមន៍ដំបូងមានសារៈសំខាន់ណាស់ សម្រាប់ការអភិវឌ្ឍមូលធនជំនាញមិនមែនពុទ្ធិបញ្ញា ដូចគ្នាដែរ និងជំនាញមូលធនពុទ្ធិបញ្ញា (Cognitive capital) ។ អ្នកស្រាវជ្រាវបានរកឃើញថាជំនាញមិនមែនពុទ្ធិបញ្ញា ដូចជាការចេះលត់ដំខ្លួនឯង ការតស៊ូ ការជឿជាក់ និងចរិតលក្ខណៈផ្ទាល់ខ្លួន ដូចជាភាពជាអ្នកដឹកនាំ គឺនាំមកនូវភាពជោគជ័យក្នុងជីវិត។ មនុស្សដែលមានភាពឆ្លាតផ្នែកបញ្ញា (IQ) ខ្ពស់ ប្រហែលជាមិនទទួលបានជោគ ជ័យក្នុងជីវិតទេ ប្រសិនបើពួកគេមិនមានចរិតលក្ខណៈមួយចំនួនដូចជាភាពអំណត់ និងការតស៊ូព្យាយាមជាដើម។ ដូច្នេះ ការអភិវឌ្ឍជំនាញនៅវ័យជាទារក និងកុមារតូច មានសារៈសំខាន់យ៉ាងខ្លាំង នៅពេលដែលសមត្ថភាព និងការលើកទឹកចិត្តរបស់មនុស្ស ត្រូវបានកំណត់ដោយកត្តាគ្រួសារ និងកត្តាមជ្ឈដ្ឋានជុំវិញ (World Bank, 2011) ។ ដូចនេះការគាំពារ និងអភិវឌ្ឍន៍កុមារតូច គឺជាមូលដ្ឋាននៃការអភិវឌ្ឍសុខមាលភាព និងសុខភាពរយៈពេលវែងរបស់កុមារ។ ការគាំពារ និងអប់រំកុមារតូច គឺជាសសរគ្រឹះ សម្រាប់ការសិក្សាពេញមួយជីវិត តាមរយៈការកសាងនូវសមត្ថភាព និងបំណិន

ដែលផ្តល់លទ្ធភាពឲ្យមនុស្សអាចសិក្សារៀនសូត្រពេញមួយជីវិត និងរកចំណូល សម្រាប់ទ្រទ្រង់ជីវភាពរបស់ខ្លួន។ កម្ពុជាចាំបាច់ត្រូវតែវិនិយោគលើការគាំពារ និងអប់រំកុមារតូច ដើម្បីកសាងមូលធនមនុស្សដែលមានសារៈសំខាន់ក្នុងការជួយឱ្យ សម្រេចបាននូវចក្ខុវិស័យសេដ្ឋកិច្ច សង្គម ក៏ដូចជាការដោះស្រាយនូវភាពក្រីក្រ និងបញ្ហាលំបាកផ្សេងៗ (អ. យ. ក., ២០១៩)។ មិនតែប៉ុណ្ណោះ ការវិនិយោគប្រកបដោយប្រសិទ្ធភាពក្នុងការគាំពារនិងអភិវឌ្ឍកុមារតូច នឹងអាចកាត់បន្ថយវិសមភាពដែលកើតចេញពីភាពក្រីក្រ កង្វះអាហារូបត្ថម្ភ និងឱកាសរៀនសូត្រ។ ការបង្កើនការចុះឈ្មោះចូលរៀននៅមត្តេយ្យសិក្សាដល់២៥% ឬ៥០% នៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប និងមធ្យម អាចមានសមាមាត្រ អត្ថប្រយោជន៍ទៅនឹងការចំណាយចាប់ពី ៦:៤ ដល់ ១៧:៦ (Engle et al. 2011) ។

ក្នុងនោះផងដែរ ការលើកកម្ពស់ការអប់រំកុមារតូច គឺជាការកសាងមូលដ្ឋានគ្រឹះសម្រាប់ការអប់រំប្រកបដោយគុណភាព ដើម្បីឆ្លើយតបទៅនឹងកត្តាខាងក្រៅ ដូចជាការផ្លាស់ប្តូរក្នុងវិស័យសេដ្ឋកិច្ច ជាពិសេសក្នុងបរិបទនៃការប្រណាំងប្រជែងក្នុងពិភពលោកសម័យក្រោយកូវីត-១៩ បដិវត្តឌីជីថល បដិវត្តឧស្សាហកម្ម ៤.០ ការប្តេជ្ញាចិត្តសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព រួមទាំងកត្តាផ្ទៃក្នុងផងដែរ ដូចជាការការពារសិទ្ធិកុមារ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កាតព្វកិច្ចក្នុងច្បាប់ស្តីពីការអប់រំ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងការអនុវត្តគោលនយោបាយវិមជ្ឈការ ក្នុងវិស័យអប់រំជាដើម។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៤៨ បានកំណត់ថា« រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ពិសេសសិទ្ធិមានជីវិតរស់នៅ និងសិទ្ធិទទួលបានការអប់រំរៀនសូត្រ»។ ច្បាប់ស្តីពីការអប់រំ មាត្រា១៦ បានកំណត់ថា «រដ្ឋត្រូវគាំពារ និងអប់រំកុមារតូច ចាប់ពីកម្រិតសូន្យឆ្នាំមុនមត្តេយ្យសិក្សាដែលជាទូទៅប្រព្រឹត្តនៅទារកដ្ឋាន នៅសហគមន៍ ឬនៅផ្ទះ»។ ការអប់រំមត្តេយ្យសិក្សា ត្រូវចាប់អនុវត្តមុនបឋមសិក្សា ដើម្បីត្រៀមលក្ខណៈចូលបឋមសិក្សា។

នៅឆ្នាំ២០១៣ ពិភពលោកបានបោះជំហានចូលក្នុងយុគសម័យថ្មី ដែលមានឈ្មោះថាយុគសម័យឌីជីថល» យុគសម័យនេះទាមទារធនធានមនុស្ស ដែលមានគុណភាពនិងសមត្ថភាពខ្ពស់។ ក្នុងនីតិកាលទី៥ នៃរដ្ឋសភា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសដាក់ចេញនៅក្នុងខែកញ្ញា ឆ្នាំ២០១៣ នូវ «យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ » ដោយចាត់ទុកវិស័យអប់រំជាវិស័យគន្លឹះ សម្រាប់ការឈានឡើងនៃការអភិវឌ្ឍសេដ្ឋកិច្ច ក្នុងដំណាក់កាលថ្មី ពិសេសការឈានទៅសម្រេចជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងក្លាយទៅជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០ (រាជរដ្ឋាភិបាលកម្ពុជា, ២០១៣)។

ការអប់រំចាប់ផ្តើមពីកុមារតូច ជាការអប់រំដែលមានសារៈសំខាន់បំផុត ក្នុងការបណ្តុះស្មារតីជាមូលដ្ឋានការបង្កើតចរិតលក្ខណៈមនុស្សពេញលេញ។ ការបណ្តុះសញ្ញាណបំណិនសិក្សាពេញមួយជីវិត បង្កើតបរិស្ថានសិក្សារួម និងមធ្យោបាយមានប្រសិទ្ធភាពជាច្រើន នឹងធ្វើឱ្យសម្រេចបាននូវគោលដៅរួមនៃលទ្ធផលសិក្សារបស់កុមារ។ សេវាអប់រំកុមារតូចរួមមានមត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ មត្តេយ្យសិក្សាឯកជន និងកម្មវិធីអប់រំកុមារតូចតាមផ្ទះ (កម្មវិធីអប់រំមាតាបិតា) ទទួលកុមារអាយុ៣ឆ្នាំបាន ១៤.២០% កុមារអាយុ៤ឆ្នាំបាន៣៤.២០% និងកុមារអាយុ៥ឆ្នាំបាន៦៤.៨០% នៅឆ្នាំសិក្សា២០២១-២០២២ (អ.យ.ក., ២០២៣)។ ក្រសួងអប់រំ យុវជន និងកីឡាបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ដល់ការសិក្សានៅមត្តេយ្យសិក្សារដ្ឋ និងមត្តេយ្យសហគមន៍ ជាពិសេសនៅតំបន់ជួបការលំបាក។ កម្មវិធីសិក្សានៅមត្តេយ្យសិក្សាត្រូវបានកែលម្អឡើងវិញនៅឆ្នាំ២០០៧ ដោយបានរៀបចំតម្រូវតាមស្តង់ដាអភិវឌ្ឍការសិក្សារបស់កុមារតូច ដែលមាន៥ផ្នែកសំខាន់ៗ គឺការអភិវឌ្ឍផ្នែករាងកាយនិងសុខភាព ការអភិវឌ្ឍផ្នែកសីលធម៌និងវប្បធម៌ ការអភិវឌ្ឍផ្នែកចិត្តសង្គមនិងអារម្មណ៍ ការអភិវឌ្ឍផ្នែកពិចារណានិងការយល់ដឹង និងការអភិវឌ្ឍផ្នែកភាសា។ ទន្ទឹមនឹងនោះ រាជរដ្ឋាភិបាលបានឯកភាពគោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ក្នុងសម័យប្រជុំពេញអង្គ

គណៈរដ្ឋមន្ត្រី នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០ ព្រមទាំងបានឯកភាពរៀបចំយន្តការអន្តរក្រសួងក្នុងការអនុវត្តគោលនយោបាយជាតិផងដែរ។

ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDG-4) " ធានាការអប់រំបរិយាបន្ន សមធម៌ គុណភាព និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា "ជាពិសេសក្នុងចំណុចដៅ៤.២ បានកំណត់ត្រឹមឆ្នាំ២០៣០ ធានាថា កុមារទាំងអស់ទទួលបានការអប់រំកម្រិតមត្តេយ្យសិក្សា ការថែទាំ ការអភិវឌ្ឍកុមារតូចប្រកបដោយគុណភាពដើម្បីពួកគេបានត្រៀមខ្លួនជាស្រេចចូលរៀននៅកម្រិតបឋមសិក្សា (អ.យ.ក., ២០១៨)។

ការរៀបរាប់ខាងលើនេះ គឺជាបញ្ហាដែលអ្នកសិក្សាស្រាវជ្រាវលើកឡើងមក ដើម្បីឱ្យមានភាពប្រទាក់ក្រឡានៅក្នុងប្រធានបទ **ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានក្នុងខេត្តស្វាយរៀង**។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

វិស័យអប់រំ មានតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍធនធានមនុស្ស ឱ្យមានចំណេះដឹង និងសមត្ថភាពខ្ពស់ ភាពច្នៃប្រឌិត ស្មារតីសហគ្រិនភាព នវានុវត្តន៍ និងក្រមសីលធម៌ខ្ពស់ ដើម្បីរួមចំណែកលើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្ម ដែលជួយបង្កើនកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងលើកកម្ពស់ផលិតភាព។ ក្នុងន័យនេះ ការអប់រំសម្រាប់ឆ្នាំ២០៣០ ផ្តោតជាសំខាន់លើការផ្តល់សេវាប្រកបដោយគុណភាព សមធម៌ បរិយាបន្ន សម្រាប់អប់រំកុមារតូច បឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា រួមទាំងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ជាពិសេសការសិក្សាពេញមួយជីវិត ដើម្បីបង្កើនប្រសិទ្ធភាព គុណភាព ផលិតភាពការងារ ស្របតាមយុគសម័យបច្ចេកវិទ្យា ក្នុងការបង្កើនសេដ្ឋកិច្ច និងសុខដុមជីវិតបុគ្គល និងសង្គម (អ.យ.ក., ២០១៩)។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌របស់កម្ពុជា និងការរីកចម្រើននៅក្នុងតំបន់ និងសាកលលោក រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពអប់រំ ការពង្រឹងប្រព័ន្ធគ្រប់គ្រងអប់រំ និងការត្រៀមអនុវត្តវិមជ្ឈការ និងវិសហមជ្ឈការ ការអភិវឌ្ឍសមត្ថភាពរបស់នាយកសាលា មន្ត្រីគ្រប់គ្រងនៅថ្នាក់មន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ។ ការពង្រឹងក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ក្នុងការពិនិត្យតាមដាននិងគាំទ្រសាលារៀនគ្រប់កម្រិតក្រសួងអប់រំ យុវជន និងកីឡាបានវាយតម្លៃថា គុណភាពអប់រំ អាស្រ័យជាចម្បងលើគុណភាពគ្រូបង្រៀន និងគុណភាពនាយកសាលារៀន(រាជរដ្ឋាភិបាលកម្ពុជា,២០១៤)។ ជាការឆ្លើយតប កំណែទម្រង់អប់រំនាពេលបច្ចុប្បន្ន បានផ្តោតទៅលើការពង្រឹងការគ្រប់គ្រងសាលារៀន ការពង្រឹងគុណភាពគ្រូ និងការកែលម្អការបង្រៀន និងការរៀន ដោយផ្តល់ឱ្យសាលារៀននូវស្វ័យភាពហិរញ្ញវត្ថុនិងការទទួលខុសត្រូវចំពោះលទ្ធផលសិក្សារបស់សិស្ស។ ឆ្លើយតបទៅនឹងបរិបទនេះ កម្ពុជាបាននិងកំពុងធ្វើកំណែទម្រង់យ៉ាងទូលំទូលាយ និងស៊ីជម្រៅលើគ្រប់វិស័យ ពិសេសវិស័យអប់រំ យុវជន និងកីឡា ដោយបានដាក់ចេញនូវវិធានការអាទិភាពនៃកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាដែលរួមមាន៨ចំណុចក្នុងឆ្នាំ២០១៤។ ដោយមើលឃើញពីវឌ្ឍនភាពរយៈពេលមួយឆ្នាំនៃការអនុវត្តកម្មវិធីកែទម្រង់វិស័យអប់រំ ជាថ្មីម្តងទៀត ក្រសួងអប់រំ យុវជន និងកីឡា បានពង្រីកកម្មវិធីកែទម្រង់រហូតដល់១៥ចំណុចពីឆ្នាំ២០១៥ ដល់២០១៨ ឈរលើមូលដ្ឋានសសរស្តម្ភចំនួន៥ ក្នុងនោះសសរស្តម្ភទី១ បានកំណត់ឱ្យអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ដែលផ្តោតនិងយកចិត្តទុកដាក់សំខាន់លើការបង្កើនគុណវុឌ្ឍិ និងបទពិសោធន៍បុគ្គលិកអប់រំ ការអភិវឌ្ឍវិជ្ជាជីវៈ ការរៀបចំគន្លងអាជីពគ្រូបង្រៀន និងការពង្រឹងអភិបាលកិច្ចតាមគ្រឹះស្ថានសិក្សា តាមរយៈរៀបចំស្តង់ដា និងបណ្តុះបណ្តាលនាយកសាលារៀន ផ្អែកតាមយុទ្ធសាស្ត្រ ទី៨ នៃគោលនយោបាយស្តីពីគ្រូបង្រៀន ពោលគឺការពង្រឹងប្រសិទ្ធភាពជាអ្នកដឹកនាំសាលារៀន (អ.យ.ក.អ., ២០១៧)។

បន្ទាប់ពី ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញវិធានការកំណែទម្រង់កម្មវិធីសិក្សាឆ្លើយតបទៅនឹងតម្រូវការគុណភាព និងបរិបទនៃការរីកចម្រើនឥតឈប់ឈររបស់ពិភពលោក នាយកដ្ឋានអប់រំកុមារតូចបានសិក្សាពីទិដ្ឋភាពជាក់ស្តែងនៃការអនុវត្តកម្មវិធីសិក្សាចាស់ទាំង៣កម្រិត និងសិក្សាស្វែងយល់កម្មវិធីសិក្សាកម្រិតមត្តេយ្យសិក្សារបស់បណ្តាប្រទេសជឿនលឿនមួយចំនួន ដូចជាកម្មវិធីសិក្សាសម្រាប់កម្រិតមត្តេយ្យសិក្សារបស់ប្រទេសជប៉ុន ប្រទេសស៊ុយអែត សាធារណៈរដ្ឋកូរ៉េ និងប្រទេសសឹង្ហបុរី ជាពិសេសដោយមានការគាំទ្រពីអង្គការយូនីសេហ្វ ការរៀបចំកម្មវិធីសិក្សានេះ បានជ្រើសរើសអ្នកឯកទេសរៀបចំកម្មវិធីសិក្សាសម្រាប់កម្រិតមត្តេយ្យសិក្សាពីប្រទេសសឹង្ហបុរី ដើម្បីបណ្តុះបណ្តាលដល់មន្ត្រីជំនាញ និងពិគ្រោះយោបល់ក្នុងការរៀបចំកម្មវិធីសិក្សាថ្មី។ ការពិនិត្យ និងកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សាឡើងវិញនេះ បានធ្វើបច្ចុប្បន្នភាព ដោយផ្អែកលើស្ថានភាពជាក់ស្តែងនៃការអប់រំកម្រិត មត្តេយ្យសិក្សានៅកម្ពុជា មានសង្គតិភាពជាមួយកម្មវិធីសិក្សាកម្រិតបឋមសិក្សា ព្រមទាំងមានសង្គតិភាពជាមួយកម្មវិធីសិក្សាមត្តេយ្យសិក្សានៃបណ្តាប្រទេសនានាក្នុងតំបន់ និងពិភពលោក។ កម្មវិធីសិក្សា បានរៀបចំឡើងវិញសម្រាប់សេវាអប់រំកម្រិតមត្តេយ្យសិក្សា កម្រិតទាប កម្រិតមធ្យម និងកម្រិតខ្ពស់ ដែលកំណត់ជាបណ្តុំមុខវិជ្ជាគោលចំនួន ៥ រួមមានមុខវិជ្ជាចិត្តចលភាព មុខវិជ្ជាវិទ្យាសាស្ត្រ មុខវិជ្ជាសិក្សាសង្គម មុខវិជ្ជាបុរេគណិត និងមុខវិជ្ជាភាសាខ្មែរ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរីកចម្រើនរបស់កុមារក្នុងបរិបទថ្មីនេះ (នាយកដ្ឋានអប់រំកុមារតូច, ២០២២)។

គុណភាពអប់រំកុមារតូច ជាកង្វល់មួយដ៏ធំផងដែរ។ ការវាយតម្លៃអំណានថ្នាក់ដំបូងដែលបានធ្វើឡើងនៅឆ្នាំ២០១០ និង២០១២ បង្ហាញថា កុមារកម្ពុជាពុំទទួលបានការត្រៀមខ្លួនឱ្យបានគ្រប់គ្រាន់ ដើម្បីចូលរៀននៅបឋមសិក្សាឡើយ។ តេស្តវាយតម្លៃអំណានថ្នាក់ដំបូង ឆ្នាំ២០១២ បានបង្ហាញថា សិស្សថ្នាក់ទី១ ពាក់កណ្តាលពុំអាចចំណាំអក្សរណាមួយបានឡើយ និងពីរភាគបីនៃសិស្សថ្នាក់ទី១ ពុំអាចអានពាក្យដែលពួកគេពុំធ្លាប់ឃើញណាមួយបានឡើយ។ ដូចគ្នានេះដែរ សិស្សថ្នាក់ទី២ ពាក់កណ្តាល ពុំអាចអានពាក្យដែលពួកគេពុំធ្លាប់រៀនហើយណាមួយនោះទេ។ បញ្ហាប្រឈមទាក់ទងនឹងលទ្ធភាពចូលរៀន និងគុណភាពអប់រំ អាច

បណ្តាលមកពីកង្វះគ្រូបង្រៀន ឬអ្នកអប់រំកុមារតូចដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ និងមានគុណវុឌ្ឍិ កង្វះលិខិតបទដ្ឋានគតិយុត្ត និងការពិនិត្យតាមដានបុគ្គលិកដែលកំពុងចូលរួមអនុវត្តកម្មវិធីអប់រំកុមារតូចគ្រប់រូបភាព ការផ្តល់ថវិកាពុំគ្រប់គ្រាន់ ក្របខណ្ឌគោលនយោបាយមិនទាន់ល្អ ការសម្របសម្រួលពុំបានល្អក្នុងចំណោមវិស័យនានា ការពិនិត្យតាមដានពុំបានគ្រប់គ្រាន់ និងកង្វះសម្ភារសិក្សា (អ.យ.ក., ២០១៩)។

ទោះបីមានការខិតខំប្រឹងប្រែង និងជួយជ្រោមជ្រែងពីគ្រប់ភាគីពាក់ព័ន្ធយ៉ាងណាក៏ដោយ ក៏សេវាអប់រំមួយនេះនៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវយកចិត្តទុកដាក់បន្ថែមទៀត ដូចជាបញ្ហាកុមារខ្វះអាហារូបត្ថម្ភ កុមារមានវិបត្តិផ្លូវចិត្ត(អំពើហិង្សាក្នុងគ្រួសារ) អនាម័យ កង្វះការថែទាំសុខភាព កង្វះការយកចិត្តទុកដាក់ និងកង្វះការថែទាំគ្រប់គ្រាន់ពីមនុស្សពេញវ័យ ជាពិសេស កុមារមួយចំនួននៅតែបន្តទទួលបានការចិញ្ចឹមបីបាច់ក្នុងស្ថានភាពអវិជ្ជមានពីសំណាក់មាតាបិតា ឬអ្នកអាណាព្យាបាល ការប្រមូលកុមារក្នុងវ័យមត្តេយ្យសិក្សាឱ្យទទួលសេវាអប់រំ និងគុណភាពនៃសេវាអប់រំកម្រិតមត្តេយ្យសិក្សាមិនទាន់ឆ្លើយតបទៅនឹងលទ្ធផលរំពឹងទុកនៃកម្មវិធីសិក្សានៅឡើយ។ កត្តាទាំងនេះនឹងមានផលប៉ះពាល់អវិជ្ជមានទៅលើសមត្ថភាពកុមារក្នុងការសិក្សារៀនសូត្រនាពេលអនាគត និងមិនអាចមានឱកាស ដើម្បីទទួលបានជោគជ័យនៅពេលពួកគេក្លាយជាមនុស្សពេញវ័យនោះឡើយ។ បញ្ហាទាំងនេះ ជាមូលហេតុនាំឱ្យមានបញ្ហាប្រឈមចំពោះមុខមួយចំនួនដែលកើតមាននៅកម្រិតបឋមសិក្សា ជាពិសេសបញ្ហាអត្រាបោះបង់ការសិក្សា និងអត្រាត្រួតថ្នាក់របស់កុមារ និងបញ្ហាប្រឈមក្នុងការសិក្សាពេញមួយជីវិតរបស់មនុស្សផងដែរ (នាយកដ្ឋានអប់រំកុមារតូច, ២០២២)។

អាស្រ័យហេតុនេះ ការលើកយកប្រធានបទ **ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានក្នុងខេត្តស្វាយរៀង** មកសិក្សាស្រាវជ្រាវ ដើម្បីរកឱ្យឃើញពីស្ថានភាពនិងបញ្ហាប្រឈម នៃការដឹកនាំ និងគ្រប់គ្រងសាលារៀនរបស់គណៈគ្រប់គ្រង នៅសាលា មត្តេយ្យសិក្សាធនជានក្នុងខេត្តស្វាយរៀង សម្រាប់ជាកញ្ចក់ឆ្លុះបញ្ចាំង និងជាត្រីវិស័យក្នុងការអភិវឌ្ឍសាលារៀន

ប្រកបដោយគុណភាព នឹងជួយឱ្យកុមារទទួលបាននូវការអប់រំសមស្របតាមបរិបទសង្គមជាតិ តំបន់ ក៏ដូចជាពិភពលោក។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងសំខាន់ពីរ គឺៈ

១-រកឱ្យឃើញពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជានក្នុងខេត្តស្វាយរៀង។

២-រកឱ្យឃើញពីបញ្ហាប្រឈមនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជានក្នុងខេត្តស្វាយរៀង។

## ១.៤ សំណួរស្រាវជ្រាវ

ការដឹកនាំ និងគ្រប់គ្រងនៅកម្រិតមត្តេយ្យសិក្សា គឺពិតជាមានសារៈសំខាន់ណាស់ ដើម្បីជួយឱ្យកុមារត្រៀមលក្ខណៈបានល្អមុននឹងចាប់ផ្តើមថ្នាក់ដំបូងរបស់ពួកគេ។ ដើម្បីសម្រេចគោលបំណងខាងលើ ការសិក្សាស្រាវជ្រាវនេះផ្តោតលើសំណួរស្រាវជ្រាវចំនួនពីរដូចខាងក្រោមៈ

១-តើការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជានក្នុងខេត្តស្វាយរៀងមានស្ថានភាពដូចម្តេច?

២-តើមានបញ្ហាប្រឈមអ្វីខ្លះនៅក្នុងការដឹកនាំ និងគ្រប់គ្រងសាលាមត្តេយ្យសិក្សាធនជានក្នុងខេត្តស្វាយរៀង?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

លទ្ធផលនៃការស្រាវជ្រាវនេះ នឹងបង្ហាញពីស្ថានភាពទូទៅនៃការដឹកនាំ និងគ្រប់គ្រងសាលាមត្តេយ្យសិក្សាធនជាន និងបញ្ហាប្រឈម ព្រមទាំងដំណោះស្រាយមួយចំនួនដែលអាចឱ្យនាយកសាលា យកទៅអនុវត្ត ដើម្បីអភិវឌ្ឍ បំពេញនូវចន្លោះប្រហោងរបស់ខ្លួនក្នុងការដឹកនាំសាលារៀន និងអប់រំកុមារ ឱ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការត្រៀមខ្លួនចូលសិក្សាថ្នាក់ដំបូងរបស់ពួកគេ។ មួយវិញទៀត លទ្ធផលនេះ អាចជួយដល់ក្រសួងអប់រំ យុវជន និងកីឡា មើលឃើញពីស្ថានភាពដឹកនាំ និងគ្រប់គ្រងនៅសាលា មត្តេយ្យសិក្សាធនជានងាយស្រួលរកដំណោះស្រាយផ្សេងៗ និងជួយអភិវឌ្ឍភាពជាអ្នកដឹកនាំរបស់នាយកសាលា ក៏ដូចជារៀបចំកម្មវិធីបណ្តុះបណ្តាល បំប៉នសមត្ថភាពបន្ថែម ចំទិសដៅ ត្រូវនឹងស្ថានភាពជាក់ស្តែង។ មិនតែប៉ុណ្ណោះ ការសិក្សា

ស្រាវជ្រាវនេះ ក៏ជាមូលដ្ឋានដល់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយៗទៀតសិក្សាស្រាវជ្រាវបន្ថែមនូវចំណុចថ្មីៗ លើការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ក៏ដូចជាសាលារៀនចំណោះទូទៅនៅកម្រិតផ្សេងៗទៀត។

## ១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

### ១.៦.១ វិសាលភាព

យោងទៅលើពេលវេលា ឯកសារដែលមានខ្លឹមសារពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវពិបាករក និងធនធានមានកំណត់ ហើយដោយសារខ្វះលទ្ធភាពក្នុងការចុះប្រមូលទិន្នន័យឱ្យបានទូលំទូលាយទូទាំងប្រទេស និងគ្រប់សាលាមត្តេយ្យសិក្សាធនធានទាំងអស់ ដែលត្រូវការចំណាយច្រើន ដូច្នេះ ការសិក្សាស្រាវជ្រាវនេះ គឺផ្តោតតែទៅលើសាលាមត្តេយ្យសិក្សាធនធានក្នុងខេត្តស្វាយរៀងប៉ុណ្ណោះ។ សាលាមត្តេយ្យសិក្សាធនធានក្នុងខេត្តស្វាយរៀងមាន៦គឺៈ សាលាមត្តេយ្យសិក្សាធនធានកុមារថ្មី សាលាមត្តេយ្យសិក្សាធនធានបាវិត សាលាមត្តេយ្យសិក្សាធនធានស្រុករមាសហែក សាលាមត្តេយ្យសិក្សាធនធានកូវ សាមុតកំពង់ចក សាលាមត្តេយ្យសិក្សាធនធានស្វាយជ្រំ និងសាលាមត្តេយ្យសិក្សាធនធានកំពង់រោទិ៍។ ការស្រាវជ្រាវលើប្រធានបទ **ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានក្នុងខេត្តស្វាយរៀង** គឺផ្តោតលើស្តង់ដាទាំង៥ នៃស្តង់ដាសាលារៀនគំរូសម្រាប់សាលាមត្តេយ្យសិក្សារដ្ឋ។ ស្តង់ដាសាលារៀនគំរូទាំងនោះរួមមានៈ **ស្តង់ដាទី១** ផលសម្រេចអប់រំ និងការសិក្សារបស់សិស្ស **ស្តង់ដាទី២** ថ្នាក់រៀនមានដំណើរការសម្រាប់ការបង្រៀននិងរៀន **ស្តង់ដាទី៣** ភាពជាម្ចាស់នៃសហគមន៍សាលារៀន **ស្តង់ដាទី៤** រដ្ឋបាល និងដំណើរការសាលារៀន **ស្តង់ដាទី៥** គណនេយ្យភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

### ១.៦.២ ដែនកំណត់

អ្នកសិក្សាស្រាវជ្រាវនឹងរៀបចំតាក់តែងកម្រងសំណួរ ដោយផ្អែកតាមផែនការកែលម្អសាលារៀនសម្រាប់សាលាមត្តេយ្យសិក្សាធនធាន ដោយមាននាយកសាលារៀន៦នាក់ (១នាក់ក្នុងមួយសាលា) គ្រូ

បង្រៀន៣២នាក់ (១នាក់ក្នុងមួយថ្នាក់) និងគណៈកម្មការគ្រប់គ្រងសាលារៀន៦នាក់ (១នាក់ក្នុងមួយសាលា) បំពេញ និងផ្តោតតែទៅលើសាលាមត្តេយ្យសិក្សាធនធានក្នុងខេត្តស្វាយរៀងប៉ុណ្ណោះ ពោលមិនគ្របដណ្តប់ទៅដល់សាលាមត្តេយ្យសិក្សាធនធានទូទាំងប្រទេស និងគ្រប់រូបភាពនៃមត្តេយ្យសិក្សានោះទេ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ បានចែកចេញជា៥ជំពូកដូចខាងក្រោម៖

**ជំពូក១ សេចក្តីផ្តើម៖** នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវ នឹងបង្ហាញអំពីមូលហេតុ និងលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូក២ រំលឹកទ្រឹស្តី៖** នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានប្រមូលយកទ្រឹស្តីចាស់ៗ ពីអ្នកសិក្សាស្រាវជ្រាវមុនៗ និងឯកសារផ្សេងៗ ដែលមានខ្លឹមសារទាក់ទងទៅនឹងប្រធានបទនៃកិច្ចការស្រាវជ្រាវនេះ ដើម្បីលើកយកមកបង្ហាញ និងការពារអំណះអំណាងក្នុងនិក្ខេបបទសម្រាប់ស្រាវជ្រាវ និងបង្កើតស្នាដៃថ្មីឡើង។

**ជំពូក៣ វិធីសាស្ត្រស្រាវជ្រាវ៖** នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ វិធីជ្រើសរើសភាគសំណាក ព្រមទាំងវិធីសាស្ត្រវិភាគទិន្នន័យដែលប្រមូលបាន។

**ជំពូក៤ លទ្ធផលនៃការស្រាវជ្រាវ៖** ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងយកទិន្នន័យដែលប្រមូលបាន មកវិភាគ និងបកស្រាយយ៉ាងក្បោះក្បាយ ទៅលើចំណុចទាំងអស់ដែលបានអនុវត្តជាក់ស្តែង តើវាស៊ីគ្នាទៅនឹងទ្រឹស្តីដែរឬទេ? ក្នុងគោលបំណងរកឱ្យឃើញពីស្ថានភាពពិតប្រាកដនៃការដឹកនាំ និងគ្រប់គ្រង របស់នាយកសាលាមត្តេយ្យសិក្សាធនធានក្នុងខេត្តស្វាយរៀង និងចំណុចដែលត្រូវធ្វើឱ្យប្រសើរឡើងវិញ នៅក្នុងស្ថានភាពជាក់ស្តែង របស់សាលារៀននីមួយៗ ដើម្បីជួយលើកកម្ពស់គុណភាពដឹកនាំ និងគ្រប់គ្រង ហើយជំរុញលទ្ធផលសិក្សារបស់សិស្សបានល្អប្រសើរ។

**ជំពូក៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ៖** ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវសង្ខេប និងធ្វើសេចក្តីសន្និដ្ឋានទៅលើគ្រប់ចំណុចដែលបានវិភាគ និងលើកជាសំណូមពរលើចំណុចដែលត្រូវកែលម្អ ដើម្បីជាព័ត៌មានសំខាន់សម្រាប់ក្រសួងអប់រំ យុវជន និងកីឡា មានទិន្នន័យច្បាស់លាស់ក្នុងការរៀបចំផែនការ ក្នុងការជំរុញលើកកម្ពស់ ការលើកទឹកចិត្ត និងការបណ្តុះបណ្តាលបន្ថែមទៅលើភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសាលារៀន។

# ជំពូក២

# រំលឹកទ្រឹស្តី

# ជំពូក២

# រំលឹកទ្រឹស្តី

## ២.១ និយមន័យ

ដើម្បីឱ្យការសិក្សាស្រាវជ្រាវលើប្រធានបទ **ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានក្នុងខេត្តស្វាយរៀង** នេះមានភាពច្បាស់លាស់ និងងាយស្រួល អ្នកសិក្សាស្រាវជ្រាវបានកំណត់ពាក្យគន្លឹះមួយចំនួនដូចខាងក្រោម៖

អ្នកដឹកនាំ ជាបុគ្គលដែលត្រូវបានទទួលស្គាល់ពីសមាជិកក្រុម ក្នុងអង្គភាពផ្សេងៗ ដើម្បីឱ្យគេធ្វើជាអ្នកដឹកនាំក្រុម ដឹកនាំអនុវត្តការងារ ដើម្បីសម្រេចគោលបំណងដែលបានគ្រោងទុក។ កាលណាមានមនុស្សរួមគ្នាធ្វើការចាប់ពីពីរនាក់ឡើងទៅ ត្រូវតែមានអ្នកដឹកនាំ។ គ្រួសារមួយ ភូមិមួយ ឃុំមួយ អង្គភាពមួយ ប្រសិនបើគ្មានអ្នកដឹកនាំ វានឹងធ្វើឱ្យគ្រួសារនោះ ភូមិនោះ ឃុំនោះ អង្គភាពនោះ ខ្វះសណ្តាប់ធ្នាប់ ខ្វះសន្តិសុខ និងមិនមានការរីកចម្រើន។ អ្នកដឹកនាំ ជាបង្គោលក្នុងការសម្រេចចិត្ត ដែលធ្វើឱ្យមានទំនាក់ទំនងគ្នា ពីក្រុមមួយទៅក្រុមមួយទៀត និងជាអ្នកជួយជំរុញទឹកចិត្ត ផ្តល់សម្ភារក្នុងការធ្វើការងារនោះផង (អ.យ.ក., ២០០៦)។

អ្នកដឹកនាំ (Leader) គឺជាបុគ្គលដែលត្រូវបានប្រគល់តួនាទី ឬទទួលស្គាល់ និងតែងតាំងឱ្យធ្វើជាមេក្រុម អ្នកបង្គាប់បញ្ជា អ្នកសម្រេចចិត្ត អ្នកផ្តល់គំនិតយោបល់ ឬចាត់ចែងការងាររបស់ក្រុម អង្គការ សហគមន៍ ឬប្រទេស។ល។ ដែលមានតួនាទីសំខាន់ក្នុងការបំផុសទឹកចិត្តជួយឱ្យមនុស្សធ្វើការកាន់តែមានប្រសិទ្ធភាពខ្ពស់ ដើម្បីជាប្រយោជន៍រួម របស់សមាជិកទាំងអស់ (Kim, 2012)។

អ្នកដឹកនាំ គឺជាមនុស្សដែលមានទស្សនៈរយៈពេលវែង ចេះប៉ាន់ស្មានពីស្ថានការណ៍ទុកមុនពេលដែលសម្រេចចិត្តធ្វើអ្វីមួយនៅពេលបច្ចុប្បន្ន។ ពួកគេនឹងប្រមើលឃើញទៅខាងមុខ ១ ២ ៣ ៤ ៥ឆ្នាំ អាចដល់ ១០ឬ២០ឆ្នាំខាងមុខ ហើយប្រើពេលគិតឱ្យបានល្អិតល្អន់ពីលទ្ធផលដែលនឹងទទួលបានពីការប្រតិបត្តិ ឬការ

ប្រព្រឹត្តមុននឹងសម្រេចចិត្តធ្វើអ្វីមួយ ពួកគេហ្វឹកហាត់គិតបែបត្រឡប់ពីអនាគតមកវិញ (Brain & Peter, 2013)។

អ្នកដឹកនាំ គឺជាអ្នកដែលមានតួនាទីដឹកអ្នកដែលមិនដឹងគោលដៅ និងនាំអ្នកមិនស្គាល់ផ្លូវឱ្យបានទៅដល់គោលដៅមួយដែលគេប្រាថ្នាដោយសុវត្ថិភាព (Heng, 1995)។

អ្នកដឹកនាំ ជាបុគ្គលដែលត្រូវបានទទួលស្គាល់ពីសមាជិកក្នុងក្រុម ឬក្នុងអង្គភាពផ្សេងៗ ដើម្បីឱ្យគេធ្វើជាអ្នកដឹកនាំក្រុម អនុវត្តការងារឱ្យសម្រេចគោលបំណង ដែលគេបានគ្រោងទុក (Chao, Good Governance in Education, 2011)។

ភាពជាអ្នកដឹកនាំ គឺសមត្ថភាពដែលអាចនាំ ឬជំរុញអ្នកឯទៀតក្នុងក្រុម ក្នុងអង្គភាព...ឱ្យពួតដៃគ្នាធ្វើការដើម្បីសម្រេចគោលដៅ (អ.យ.ក.,២០០៦)។ ភាពជាអ្នកដឹកនាំ គឺជាសមត្ថភាពក្នុងការបណ្តុះបណ្តាល និងជំរុញមន្ត្រីទាំងអស់ ឬបុគ្គលិកក្រោមឱវាទឱ្យមានការរីកចម្រើន ធ្វើតាមបែបច្នៃប្រឌិត មានឆន្ទៈក្នុងការគិតរកគំនិតប្លែកៗ និងហ៊ានប្រថុយ ដើម្បីនាំទៅរកភាពជោគជ័យក្នុងការងារ (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ, ២០១៦)

ភាពជាអ្នកដឹកនាំ គឺជាសមត្ថភាពដែលអាចនាំ ឬជំរុញអ្នកផ្សេងទៀតក្នុងក្រុម ក្នុងអង្គភាពឱ្យពួតដៃគ្នាធ្វើការ ដើម្បីសម្រេចគោលដៅ (Chao, Good Governance in Education, 2011)។ ចំណែកឯពាក្យ ភាពជាអ្នកដឹកនាំ (Leadership) មានអត្ថន័យទូលំទូលាយជាងតួអង្គ ឬបុគ្គលដែលសំដៅលើសមត្ថភាពរបស់អ្នកដឹកនាំ និងក្រុមអ្នកដឹកនាំក្នុងការទទួលស្គាល់ សង្កេត មានឥទ្ធិពល ជួយអ្នកដទៃ ឱ្យរួបរួមសាមគ្គីគ្នា ធ្វើការងារឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល ដើម្បីសម្រេចគោលដៅរួម និងធ្វើការកែទម្រង់សហគមន៍ អង្គការ ឬប្រទេសជាតិ ឱ្យចម្រើនជឿនលឿនឆាប់រហ័ស (Kim,2012)។ ភាពជាអ្នកដឹកនាំ គឺជាដំណើរការដ៏មានឥទ្ធិពលរបស់ថ្នាក់ដឹកនាំ និងថ្នាក់ក្រោម ឱ្យធ្វើការងារឆ្ពោះទៅសម្រេចគោលបំណងរបស់អង្គភាព តាមរយៈការផ្លាស់ប្តូរ (Ourn, 2016)។

ការដឹកនាំ គឺជាការសម្របសម្រួលផ្លាស់ប្តូរ ការពុះពារគ្រប់ឧបសគ្គ និងធ្វើឱ្យអង្គភាពមួយមានការអភិវឌ្ឍ។

ការគ្រប់គ្រង សំដៅដល់ការធ្វើផែនការ ការរៀបចំចាត់ចែង ការដឹកនាំ ការត្រួតពិនិត្យធនធានមនុស្ស និងធនធានដទៃទៀត ដើម្បីសម្រេចគោលដៅរបស់អង្គភាព ឬស្ថាប័ន ប្រកបដោយប្រសិទ្ធភាព (អ.យ.ក., ២០១៦)

## ២.២ ចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០០-២០១៥

ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់នូវចក្ខុវិស័យរបស់ខ្លួនគឺការកសាង និងអភិវឌ្ឍធនធានមនុស្សលើគ្រប់ផ្នែកឱ្យប្រសើរបំផុតដោយផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយទៅជាសង្គមមួយរីកចម្រើន។ ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើនេះ ក្រសួងអប់រំ យុវជន និងកីឡាចាំបាច់ត្រូវមានបេសកកម្មដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជាឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់កម្ពុជាជាមួយនឹងការរីកចម្រើនព្រមគ្នាទាំងក្នុងតំបន់ និងសកលលោក។ គោលបំណងរយៈពេលវែងរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺអភិវឌ្ឍ និងបណ្តុះស្មារតីយុវជន យុវតីកម្ពុជាគ្រប់រូប លើគ្រប់វិស័យ ឱ្យមានសីលធម៌រស់នៅល្អ និងមានគុណធម៌ខ្ពស់ ព្រមទាំងមានស្មារតីសុទិដ្ឋិនិយម និងមោទកភាពចំពោះប្រទេសជាតិ និងប្រជាជនរបស់ខ្លួន ស្របតាមរដ្ឋធម្មនុញ្ញ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ។ ក្រសួងអប់រំ យុវជន និងកីឡាក៏បានកំណត់នូវវត្ថុបំណងចំពោះមុខរបស់ខ្លួនគឺផ្តល់ឱកាសស្មើៗគ្នាដល់យុវជន និងកុមារកម្ពុជាគ្រប់រូប ក្នុងបំណងឱ្យពួកគេទាំងនោះទទួលបាននូវការអប់រំប្រកបដោយគុណភាព ឈរលើគោលការណ៍ មិនរើសអើងអំពីស្ថានភាពសង្គម ភូមិសាស្ត្រ ជនជាតិ សាសនា ភាសា ភេទ និងកាយសម្បទា។ បន្ទាប់ពីសិស្ស និស្សិតបានបញ្ចប់ការសិក្សា ក្រសួងអប់រំ យុជន និងកីឡាសង្ឃឹមថាពួកគេនឹងទទួលបាននូវចំណេះដឹងសមស្របទៅតាមស្តង់ដាមួយដែលអាចប្រគួតប្រជែងនៅលើទីផ្សារការងារ ក្នុង

តំបន់ និងលើសកលលោក ហើយពួកគេទាំងនោះនឹងក្លាយជាកម្លាំងស្នូលសម្រាប់ជំរុញការអភិវឌ្ឍសង្គម និង សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់គោលនយោបាយធំៗចំនួនបីគឺៈ

១. ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ ដល់ប្រជាជនគ្រប់ៗរូប

២. លើកកម្ពស់គុណភាព និងភាពឆ្លើយតបនៃសេវាអប់រំ

៣. ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្រ្តីអប់រំនៅគ្រប់លំដាប់ថ្នាក់

ឈរលើគោលនយោបាយនេះ ក្រសួងអប់រំ យុវជន និងកីឡារំពឹងទុកថានឹងសម្រេចបាននូវគោល បំណងនាពេលណាមួយជាក់ជាពុំខាន(អ.យ.ក., ២០១៤)។ គោលនយោបាយទាំងបីខាងលើត្រូវបាន ប្របាច់បញ្ចូលគ្នាទៅជាគោលនយោបាយចំនួនពីរវិញ ចាប់ពីឆ្នាំ២០១៨ (អ.យ.ក.ESP, ២០១៨)។ គោល នយោបាយទាំងពីរនោះរួមមានៈ (១) ធានាការអប់រំមានគុណភាព សមធម៌ បរិយាបន្ន និងលើកកម្ពស់ការ សិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និង (២) ការលើកកម្ពស់ភាពជាអ្នកដឹកនាំ និងអភិវឌ្ឍសមត្ថភាព មន្ត្រីគ្រប់គ្រងគ្រប់លំដាប់ថ្នាក់។

### ២.២.១ គោលដៅអប់រំជាតិ២០០០-២០១៥

គោលនយោបាយអប់រំរបស់ព្រះរាជាណាចក្រកម្ពុជា គឺផ្តោតសំខាន់លើការអប់រំ និងការបណ្តុះ បណ្តាលចំណេះវិជ្ជាដល់ប្រជាពលរដ្ឋ ពិសេសសិស្សានុសិស្សគ្រប់ភូមិសិក្សា ឱ្យអភិវឌ្ឍទាន់អន្តរកាលនៃការ រីកចម្រើនរបស់តំបន់ និងសកលលោក ព្រមទាំងឆ្លើយតបទៅនឹងទីផ្សារការងារនៃសេដ្ឋកិច្ចទីផ្សារសេរីផង ដែរ។ តែទោះយ៉ាងនេះក្តី ក៏គ្រប់គោលយោបាយអប់រំទាំងអស់គឺត្រូវបម្រើឱ្យគោលដៅអប់រំជាតិទាំងមូលដែរ ព្រោះគោលដៅអប់រំជាតិរបស់ព្រះរាជាណាចក្រកម្ពុជាគឺជាសសរគ្រឹះ សម្រាប់ការកសាងធនធានមនុស្ស និង សេដ្ឋកិច្ច។ គោលដៅអប់រំជាតិមានគោលបំណងកសាងធនធានមនុស្សឱ្យរីកចម្រើន លូតលាស់គ្រប់ផ្នែក

ហើយត្រូវមានតុល្យភាពគ្នារវាងប្រាជ្ញា ស្មារតី សញ្ចេតនា និងរូបរាងកាយ សំដៅទទួលបានមនុស្សពេញលេញ ប្រកបដោយចំណេះវិជ្ជា បំណិន ជំនាញ និងឥរិយាបថគ្រប់គ្រាន់។

យ៉ាងណាមិញ គោលដៅអប់រំជាតិក៏មានគោលដៅធានាការកសាងពលរដ្ឋថ្លៃថ្នូរ ប្រកបដោយចំណេះដឹង បំណិន និងឥរិយាបថចាំបាច់ សម្រាប់ជួយលើកស្ទួយការថែរក្សាសុខភាពទាំងផ្លូវកាយ បញ្ញា និងស្មារតី ដើម្បីរួមចំណែកក្នុងការលើកស្ទួយសុខភាពគ្រួសារ និងសង្គមជាតិឱ្យកាន់តែប្រសើរឡើង។ គោលដៅអប់រំជាតិរបស់ព្រះរាជាណាចក្រកម្ពុជាសង្ឃឹមថាសិស្សនឹងមានសមត្ថភាពគ្រប់គ្រង ថ្លឹងថ្លែងពិចារណាលើសកម្មភាពជាមុន ហើយធ្វើការសម្រេចចិត្តបានត្រឹមត្រូវ មានភាពជឿជាក់ មានស្មារតីទទួលខុសត្រូវខ្ពស់ មានសីលធម៌ ចេះវិភាគ បែងចែក និងដោះស្រាយបញ្ហានៅក្នុងគ្រួសារ និងសង្គមបាន ព្រមទាំងមានបំណិនក្នុងការបម្រើការងារ មានការយល់ដឹង មានឥរិយាបថជាវិជ្ជមាន និងមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីធ្វើការងារជាក្រុមប្រកបដោយប្រសិទ្ធភាព និងភាពសុខដុម។ ការអប់រំត្រូវផ្តល់ឱ្យសិស្សនូវការសិក្សាស្វែងយល់ពីតម្លៃនៃវប្បធម៌ អរិយធម៌ ប្រវត្តិសាស្ត្រនានាទាំងរបស់ជាតិ និងអន្តរជាតិ ដោយធ្វើឱ្យមានការកោតសរសើរ និងឱ្យតម្លៃទៅលើគំនិតបែបវិទ្យាសាស្ត្រ បច្ចេកវិទ្យា ការបង្កើតថ្មី និងគំនិតច្នៃប្រឌិតខ្ពស់ក្នុងការរស់នៅ ដើម្បីអាចឈានទៅរកការកសាងស្មារតីសាធារណៈមួយក្នុងន័យឱ្យមានសីលធម៌រស់នៅល្អ និងការគោរពសិទ្ធិគ្នានៅក្នុងសង្គមកម្ពុជា។

ការអប់រំក៏ត្រូវមានកាតព្វកិច្ចសំខាន់មួយដែរ ក្នុងការកសាងពលរដ្ឋសកម្ម និងមានស្មារតីប្រកួតប្រជែងខាងផ្នែកវិទ្យាសាស្ត្រ និងការបង្កើតថ្មី ព្រោះវានឹងអាចជួយឱ្យប្រជាពលរដ្ឋមានគំនិតកាន់តែជ្រៅជ្រះ ស្រឡាញ់ជាតិ សាសនា និងព្រះមហាក្សត្រ និងជួយឱ្យប្រទេសជាតិមានសន្តិភាព ព្រោះប្រជាពលរដ្ឋទាំងអស់ចេះគោរពច្បាប់ទម្លាប់បានត្រឹមត្រូវ ហើយឈានទៅបណ្តុះបណ្តាលស្មារតីចេះការពារបរិស្ថានធម្មជាតិ សង្គម និងវប្បធម៌របស់ប្រទេសជាតិ (វិទ្យាស្ថានស្រាវជ្រាវ, ១៩៩៦)។

## ២.២.២ គោលដៅអប់រំចំណេះទូទៅ២០០០-២០១៥

ការអប់រំចំណេះទូទៅ គឺជាសសរគ្រឹះសំខាន់ជាងគេក្នុងការបណ្តុះធនធានមនុស្ស សម្រាប់កសាង និងអភិវឌ្ឍសង្គមជាតិឱ្យរីកចម្រើន។ ការអប់រំចំណេះទូទៅក៏មានគោលដៅទ្រទ្រង់គោលដៅអប់រំជាតិផងដែរ។ ស្ថិតក្នុងន័យនេះ ការអប់រំចំណេះទូទៅមានគោលបំណងបណ្តុះបណ្តាលបំណិន បទពិសោធន៍ការងារ និងបទពិសោធន៍នៃជីវិតផ្សេងៗទៀត ព្រមទាំងបណ្តុះតម្លៃបុគ្គលិកលក្ខណៈ សំដៅធ្វើយ៉ាងណាឱ្យការចូលរួមយ៉ាងផុសផុលក្នុងការអភិវឌ្ឍសង្គមជាតិ និងសកលលោក។

សម្រេចបាននូវគោលបំណងនេះ ការអប់រំចំណេះទូទៅត្រូវមានគោលដៅអប់រំសិស្សឱ្យក្លាយទៅជាពលរដ្ឋថ្លៃថ្នូរ និងពលករល្អ ពោលគឺបណ្តុះសិស្សឱ្យមានមូលដ្ឋានចំណេះដឹងផ្នែកភាសាខ្មែរ អក្សរសាស្ត្រខ្មែរ និងគណិតវិទ្យាច្បាស់លាស់ ហើយមានចំណូលចិត្តស្រឡាញ់ការសិក្សាដើម្បីបម្រើការងារ និងបន្តការសិក្សាពេញមួយជីវិត។ ការកសាងចំណេះទូទៅ បំណិន និងសមត្ថភាពក្នុងការប្រើប្រាស់ចំណេះដឹង និងបំណិនទាំងនេះ ដើម្បីឱ្យសិស្សចេះពង្រឹងនូវសុខភាពខ្លួន ទាំងផ្លូវកាយ ផ្លូវចិត្ត និងប្រាជ្ញាស្មារតីដើម្បីឈានទៅរកការកសាងទំនុកចិត្តលើខ្លួនឯង ហើយអាចរៀបចំផែនការកែលម្អសុខភាពគ្រួសារ សង្គម និងការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយជោគជ័យក្នុងស្ថានភាពរស់នៅជាក់ស្តែងក្នុងសង្គម។ ជាងនេះទៅទៀត ការអប់រំចំណេះទូទៅ ក៏មានគោលដៅបណ្តុះស្មារតីសិស្សឱ្យមានសញ្ចេតនា អធ្យាស្រ័យល្អចំពោះគ្នា ចេះជួយធុរៈគ្នា យោគយល់គ្នា ហើយទទួលស្គាល់ផលប្រយោជន៍អ្នកដទៃ ក្នុងស្មារតីមួយស្រឡាញ់ រាប់អាន ភាតរភាព និងដើម្បីឱ្យមានសមភាពក្នុងសហគមន៍។ គោលដៅសំខាន់មួយទៀតគឺអប់រំឱ្យសិស្សចេះស្រឡាញ់ពលកម្ម ចេះរស់នៅជាមួយគ្នា មានចំណូលចិត្តវិទ្យាសាស្ត្រទំនើប ចេះសិក្សាស្វែងយល់ពីការវិវត្តដើម្បីសម្របខ្លួនទៅតាមការវិវត្តនោះ ស្វែងយល់ពីរបៀបនៃការគ្រប់គ្រងការងារ ដើម្បីត្រៀមខ្លួនទុកជាមុន ក្នុងការប្រកបរបរណាមួយឱ្យសមស្របទៅតាមសមត្ថភាព និងចំណង់ចំណូលចិត្តរបស់ខ្លួន ហើយ ក៏ដើម្បីចូលរួមអភិវឌ្ឍសង្គមជាតិឱ្យទទួលបានជោគជ័យ ប្រកបដោយស្មារតីថែរក្សាបរិស្ថាន សម្បត្តិធម្មជាតិ វប្បធម៌ សិល្បៈ មានមោទកភាពជាតិ ស្រឡាញ់ជាតិ សាសនា និងព្រះមហាក្សត្រ (នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ, ២០០៨)។

## ២.៣ ក្របខណ្ឌនៃការអភិវឌ្ឍជាតិ

### ២.៣.១ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០

ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបានដើរតួយ៉ាងសំខាន់ក្នុងការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា និងទិសដៅសម្រាប់អភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា។ ឈរលើមូលដ្ឋាននេះ កម្ពុជាបានសម្រេចគោលដៅធំៗជាច្រើនដូចជា សន្តិភាព ស្ថិរភាពនយោបាយ វិបុលភាព និងការកាត់បន្ថយភាពក្រីក្របានយ៉ាងឆាប់រហ័ស។ ទន្ទឹមនឹងនោះ កម្ពុជាបានធ្វើមូលដ្ឋាននីយកម្មគោលដៅអភិវឌ្ឍន៍សហវត្សរ៍សកលទៅជាគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា និងបានសម្រេចគោលដៅជាច្រើនមុនកាលកំណត់ឆ្នាំ២០១៥។

ដំណាក់កាលថ្មីនេះ រាជរដ្ឋាភិបាលបានបន្តការខិតខំរបស់ខ្លួន ដើម្បីធ្វើមូលដ្ឋាននីយកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសកលឱ្យស្របនឹងបរិការណ៍កម្ពុជា និងបានធ្វើសមាហរណកម្មទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ជាពិសេស ប្រើជាធាតុចូលយ៉ាងសំខាន់សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣។

រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០៣០ នៅចុងឆ្នាំ២០១៨ ដែលមានគោលដៅចំនួន១៨ ចំណុចដៅចំនួន៨៨ និងសូចនាករចំនួន១៤៨ ដោយបានបន្ថែមគោលដៅមួយថ្មីស្តីពីការបោសសម្អាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះសល់ពីសង្គ្រាម ព្រមទាំងបានរក្សាទុកចំណុចដៅសកលប្រមាណ ៧៥ ភាគរយ ដែលពាក់ព័ន្ធនឹងកម្ពុជា។

### ២.៣.២ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល

ទិសដៅរួមរបស់រាជរដ្ឋាភិបាលកម្ពុជា គឺកសាងនូវសង្គមកម្ពុជាមួយ ដែលរឹងមាំមានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម មានការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌ ជាមួយនឹងការប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់នូវគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូរ

របស់មនុស្ស ជាសង្គមមួយដែលមានកោសិការផ្សារភ្ជាប់គ្នា និងត្រូវបានពង្រឹង ដើម្បីធានាថា ប្រជាជនកម្ពុជាមានចំណេះដឹងខ្ពស់ និងមានសុខភាពល្អ មានជីវភាពសមរម្យ និងមានការរស់នៅប្រកបដោយសុខដុមរមនា ទាំងក្នុងរង្វង់គ្រួសារ និងក្នុងសង្គមជាតិ។

នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភាបានដាក់ចេញនូវចក្ខុវិស័យសេដ្ឋកិច្ច សង្គមកិច្ច ដើម្បីឱ្យកម្ពុជាឈានទៅសម្រេចបានឋានៈជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។ គោលដៅយុទ្ធសាស្ត្រ៤យ៉ាង គឺដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព នៅតែចាំបាច់ និងសមស្របសម្រាប់កម្ពុជាអនុវត្តនៅក្នុងនីតិកាលទី៦ ឆ្នាំ២០១៨-២០២៣ ក្នុងគោលបំណង ១) ធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុង អត្រាមធ្យមប្រចាំឆ្នាំរង្វង់៧ ភាគរយ ប្រកបដោយចីរភាព ធន់នឹងវិបត្តិ ២) បង្កើតការងារឱ្យបានកាន់តែច្រើនទាំងបរិមាណ និងគុណភាពជូនដល់ប្រជាជនកម្ពុជា ពិសេសសម្រាប់ស្រទាប់យុវជន ៣) សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រឱ្យស្ថិតនៅក្នុងអត្រាទាបជាង១០ភាគរយ និង ៤) បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាបាននូវប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈ។

ស្នូលនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ គឺការបង្កើនល្បឿននៃកំណែទម្រង់អភិបាលកិច្ចដោយផ្ដោតសំខាន់លើ ១) ការកែទម្រង់ និងលើកកម្ពស់សមត្ថភាពស្ថាប័ន ២) ការពង្រឹងភាពស្អាតស្អំ ក្នុងរដ្ឋបាលសាធារណៈ ៣) ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ និង៤) ការពង្រឹងអភិបាលកិច្ច វិស័យឯកជន។

រាជរដ្ឋាភិបាល បាននិងកំពុងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម២០១៥-២០២៥ ដើម្បីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា ដែលរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាបន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់

ផលិតភាព។ គោលនយោបាយនេះមានគោលបំណងកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជាពីឧស្សាហកម្មអតិពលកម្មឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥ តាមរយៈការភ្ជាប់ខ្សែចង្វាក់តម្លៃសកល សមាហរណកម្មទៅក្នុងបណ្តាញផលិតកម្មតំបន់ និងការអភិវឌ្ឍកន្សោមផលិតកម្មប្រទាក់ក្រឡាគ្នា ទន្ទឹមនឹងការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព ឧស្សាហកម្មក្នុងស្រុក។ ក្នុងនោះមានយុទ្ធសាស្ត្រមួយបានផ្តោតលើការអភិវឌ្ឍធនធានមនុស្ស និងបណ្តុះបណ្តាលបច្ចេកទេស។ ជំនាញ និងបច្ចេកវិទ្យាមនុស្ស គឺមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ការធ្វើសមាហរណកម្មឱ្យកាន់តែស៊ីជម្រៅរបស់កម្ពុជាទៅក្នុងតំបន់អាស៊ាន។

ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា នឹងឈានដល់ដំណាក់កាល ប្រែប្រួលថ្មីមួយទៀត ដែលជាអន្តរកាលឆ្ពោះទៅសម្រេចឋានៈប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០២៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលនឹងបន្តផ្តោតការយកចិត្តទុកដាក់លើវិស័យអាទិភាព៤ ដោយតម្កល់មនុស្សជាអាទិភាពទី១ វិញ ហើយ ផ្លូវ ភ្លើង និងទឹក ជាអាទិភាពបន្តបន្ទាប់នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ក្នុងនីតិកាលទី៦នៃរដ្ឋសភា។ ក្នុងនោះ យុទ្ធសាស្ត្រចតុកោណទី១៖ ការអភិវឌ្ឍធនធានមនុស្ស សំដៅលើកកម្ពស់ចំណេះដឹង ជំនាញវិជ្ជាជីវៈ សមត្ថភាពសហគ្រិនភាព ការច្នៃប្រឌិត នវានុវត្តន៍ គុណធម៌ មនសិការស្នេហាជាតិ និងស្មារតីទទួលខុសត្រូវ សុខភាព និងកាយសម្បទារឹងមាំ តួនាទីស្ត្រី និងកិច្ចគាំពារសង្គម។ ការអភិវឌ្ឍធនធានមនុស្សបន្តផ្តោតលើ៖ ១) ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ២) ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ៣) ការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ និង ៤) ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម។

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺអភិវឌ្ឍប្រព័ន្ធប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ដោយផ្តោតសំខាន់លើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការតម្រង់ទិសសម្រាប់ទីផ្សារការងារ និងការយកចិត្តទុកដាក់លើការអប់រំកាយ សម្រាប់ទ្រទ្រង់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ។ ក្នុងន័យនេះ រាជរដ្ឋាភិបាល

នឹងផ្តោតអាទិភាពលើ៖ ១) ការយកចិត្តទុកដាក់លើគ្រូបង្រៀន ២) ការពង្រីកវិសាលភាពសាលារៀនគ្រប់កម្រិត ៣) ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលារៀន ៤) ការជំរុញការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ តាមទស្សនាទាន ខេត្តមួយមានវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសមួយយ៉ាងតិច សម្រាប់រយៈពេលវែង ៥) ការបង្កើនភាពឆ្លើយតបឱ្យកាន់តែពេញលេញនៃការអប់រំទៅនឹងទីផ្សារការងារ និងការរស់នៅ តាមរយៈទស្សនាទាន យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត ៦) ការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលគ្រប់ជ្រុងជ្រោយ និង៧) ការត្រៀមប្រកួតកីឡាស៊ីហ្គេមឆ្នាំ ២០២៣ និងជំរុញចលនា យុវជនម្នាក់ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត។

### ២.៣.៣ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា

កម្ពុជាបានឈានដល់ដំណាក់កាលថ្មីមួយទៀតនៃការអភិវឌ្ឍវិស័យអប់រំ ឱ្យឆ្លើយតបនឹងបរិបទសកលលោក និងថ្នាក់តំបន់ ដែលមានមហិច្ឆតា និងវិសាលភាពធំទូលាយជាងមុន សំដៅលើកកម្ពស់គុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិតក្នុងក្របខណ្ឌទូលំទូលាយ គ្របដណ្តប់លើគ្រប់ប្រភេទ និងកម្រិតនៃការអប់រំ ជាពិសេស ស្របនឹងទស្សនវិស័យអភិវឌ្ឍន៍កម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ក្រសួងអប់រំ យុវជន និងកីឡាបានអនុម័តផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០ ស្តីពីការអប់រំនៅកម្ពុជា នៅដើមឆ្នាំ២០១៩ ដើម្បីធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

ផែនទីបង្ហាញផ្លូវនេះបានកំណត់អាទិភាពគោលនយោបាយអប់រំធំៗចំនួន ៥ គឺ ១) កុមារគ្រប់រូបទទួលបានការគាំពារ និងអភិវឌ្ឍន៍កុមារតូច ការអប់រំកម្រិតមត្តេយ្យសិក្សា ការបញ្ចប់ការអប់រំកម្រិតមូលដ្ឋានដោយឥតបង់ថ្លៃនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ដោយទទួលបានលទ្ធផលសិក្សាប្រកបដោយគុណភាព ប្រសិទ្ធភាព សមធម៌ និងភាពឆ្លើយតប ២) កុមារ និងយុវជនគ្រប់រូបបញ្ចប់ការសិក្សា

នៅកម្រិតអប់រំមធ្យមសិក្សាទុតិយភូមិ ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ដោយទទួលបានលទ្ធផលសិក្សាប្រកបដោយគុណភាព និងភាពឆ្លើយតប ៣) ធានាឱ្យអ្នកសិក្សាគ្រប់រូបមានលទ្ធភាពស្មើគ្នាក្នុងការទទួលបានការអប់រំបច្ចេកទេសវិជ្ជាជីវៈ និងឧត្តមសិក្សាប្រកបដោយគុណភាព ៤) យុវជន និងមនុស្សពេញវ័យគ្រប់រូបទទួលបានចំណេះដឹងអក្ខរកម្ម និងលេខនព្វន្ត និងមានឱកាសកាន់តែច្រើនក្នុងការសិក្សាពេញមួយជីវិត និង ៥) អភិបាលកិច្ច និងការគ្រប់គ្រងវិស័យអប់រំ មានភាពល្អប្រសើរជាងមុននៅគ្រប់កម្រិត។

### ២.៣.៤ គោលដៅនៃការអប់រំជាតិ២០១៦-២០៣០

១. បណ្តុះមនសិការជាតិ មានស្មារតីទទួលខុសត្រូវ ស្មោះត្រង់ និងមានមោទកភាពជាតិ តាមរយៈការលើកកម្ពស់ការប្រកាន់នូវគំនិត គុណតម្លៃ បំណងប្រាថ្នារួមគ្នា ដើម្បីបង្កើតបាននូវសាមគ្គីភាពជាតិ និងអត្តសញ្ញាណជាតិ។

២. ផ្តល់ការអភិវឌ្ឍគ្រប់ជ្រុងជ្រោយដល់អ្នកសិក្សា ដើម្បីទទួលបានតុល្យភាពរវាងការអភិវឌ្ឍកាយសម្បទា បញ្ញា អារម្មណ៍ សោភណ្ឌភាព និងស្មារតី។

៣. ផលិតធនធានមនុស្សដែលមានចំណេះដឹង បំណិន និងសមត្ថភាពស្របទៅតាមតម្រូវការទីផ្សារការងារសម្រាប់សេដ្ឋកិច្ចពុទ្ធិប្រកបដោយពិពិធភាព ហើយអាចប្រកួតប្រជែងថ្នាក់ដំបន់ និងសកលលោក។

៤. រៀបចំអ្នកសិក្សាពេញមួយជីវិត ដើម្បីឱ្យពួកគេអាចចូលរួមក្នុងពិភពលោក ដែលមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ពឹងអាស្រ័យគ្នាទៅវិញទៅមក អាចធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់ និងសកលលោក ដើម្បីបង្កើតនូវពិភពលោកមួយឱ្យកាន់តែមានសុខសន្តិភាព និងប្រកបដោយចីរភាព។

ផែនទីបង្ហាញផ្លូវ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា បានដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រសំខាន់ៗ ឆ្ពោះទៅសម្រេចគោលដៅអប់រំ ឆ្នាំ២០៣០ ដូចខាងក្រោម៖

- កម្ពុជាត្រូវមានប្រព័ន្ធអប់រំ រឹងមាំ និងមានសមត្ថភាពប្រកួតប្រជែងថ្នាក់តំបន់សម្រាប់សង្គមពុទ្ធិ។

ប្រព័ន្ធអប់រំ ត្រូវមានធនធានគ្រប់គ្រាន់ មានអភិបាលកិច្ចល្អ និងមានតុល្យភាព ដោយចាត់ទុកថា សមធម៌ បរិយាបន្ន ប្រសិទ្ធភាព និងស្តង់ដាគុណភាពខ្ពស់ជាគោលការណ៍សំខាន់របស់ខ្លួន។ ប្រព័ន្ធអប់រំត្រូវមានលក្ខណៈគ្រប់ជ្រុងជ្រោយទូទាំងវិស័យដែលអនុវិស័យនីមួយៗ និងសមាសភាពទាំងអស់នៃប្រព័ន្ធអប់រំ ត្រូវឆ្លើយតបទៅនឹងតម្រូវការនៃការសិក្សាពេញមួយជីវិត នៅគ្រប់ដំណាក់កាលទាំងអស់នៃជីវិត តាមរយៈបង្កើតឱកាសក្នុងការសិក្សាគ្រប់បរិបទ និងទម្រង់ (ក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ) សម្រាប់ប្រជាពលរដ្ឋគ្រប់វ័យ។

- ក្រសួងអប់រំ យុវជន និងកីឡាគឺជាក្រសួងដែលមានឧត្តមភាពក្នុងការផ្តល់នូវការអប់រំនិងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ប្រកបដោយគុណភាព ដើម្បីក្លាយជាចលករក្នុងការឈានទៅសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច។ ក្រសួងត្រូវមានសមត្ថភាពវិជ្ជាជីវៈក្នុងការបំពេញមុខងារផ្នែកបច្ចេកទេសដូចជា ការរៀបចំផែនការ ការពិនិត្យតាមដាន ការអភិវឌ្ឍកម្មវិធីសិក្សា ការបណ្តុះបណ្តាលគ្រូ ការវាយតម្លៃ និងអភិបាលកិច្ចវិស័យ។ល។ ក្រសួងរៀបចំ និងអនុវត្តគោលនយោបាយ ផែនការអប់រំ គោលបំណងនិយាម និងស្តង់ដាសម្រាប់គ្រប់កម្រិត និងគ្រប់សមាសភាគនៃការអប់រំ និងសម្របសម្រួលការគ្រប់គ្រងកំណែទម្រង់ដែលជាធាតុផ្សំផ្សេងៗនៃវិស័យអប់រំ (រដ្ឋបាល កិច្ចការសិក្សាធិការ ធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស)។ ក្រសួងរៀបចំទិសដៅក្នុងការអភិវឌ្ឍវិស័យអប់រំ ហើយធានាឱ្យបាននូវអភិបាលកិច្ចល្អសម្រាប់អ្នកផ្តល់សេវាអប់រំទាំងអស់ និងពិនិត្យតាមដានលទ្ធផលនៃប្រព័ន្ធអប់រំ ដើម្បីសម្រេចបាននូវគោលបំណងនៃការអប់រំរបស់ប្រទេស។ ប្រព័ន្ធនេះ មានគោលបំណងធានាឱ្យបាននូវភាពប្រសើរឡើង លើការទទួលសេវាប្រកបដោយសមធម៌ គុណភាព និងភាពឆ្លើយតប ដ៏ដូចជាអភិបាលកិច្ច និងការគ្រប់គ្រងគ្រឹះស្ថានសិក្សាគ្រប់ប្រភេទ និងគ្រប់កម្រិតថ្នាក់។

- សាលារៀន គឺជាគ្រឹះស្ថានសិក្សាដែលធានាបាននូវការអប់រំប្រកបដោយគុណភាព សម្រាប់ទាំងអស់គ្នា។ សាលារៀនទាំងអស់នឹងមានស្វ័យភាពផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងគណនេយ្យភាពក្នុងការសម្រេចបាននូវលទ្ធផលសិក្សា ប្រកបដោយគុណភាពខ្ពស់ សម្រាប់ទាំងអស់គ្នា។ សាលារៀននឹងទទួលបានគ្រូបង្រៀនដែល

មានសមត្ថភាពវិជ្ជាជីវៈ និងការលើកទឹកចិត្ត ហើយមានអ្នកដឹកនាំការងារបង្រៀនប្រកបដោយចក្ខុវិស័យ និងផ្តល់នូវបរិយាកាសប្រកបដោយសុវត្ថិភាព អនាម័យ ឆ្លើយតបចំពោះយេនឌ័រ បរិយាបន្ន ការរៀន និងបង្រៀនប្រកបដោយគុណភាពខ្ពស់ ដោយប្រើប្រាស់បច្ចេកវិទ្យាជាជំនួយ។

- គ្រូបង្រៀនកម្ពុជា មានសមត្ថភាពទទួលបានការលើកទឹកចិត្ត និងទទួលបានការគាំទ្រគ្រប់គ្រាន់ដើម្បីជួយគាំទ្រដល់អ្នកសិក្សាឱ្យទទួលបានការអប់រំប្រកបដោយគុណភាពខ្ពស់។ ប្រព័ន្ធអប់រំកម្ពុជានឹងមានគ្រូបង្រៀនដែលមានសមត្ថភាពវិជ្ជាជីវៈ ទទួលបានការលើកទឹកចិត្ត ទទួលបានការគាំទ្រ និងការបំប៉នចំណេះដឹងមុខវិជ្ជាជំនាញគ្រប់គ្រាន់ ព្រមទាំងជំនាញគរុកោសល្យ និងស្រឡាញ់ការបង្រៀនសិស្សានុសិស្សរបស់ខ្លួន។ វិជ្ជាជីវៈគ្រូបង្រៀននឹងត្រូវបានលើកកម្ពស់ដើម្បីឱ្យការទាក់ទាញ និងរក្សាបាននូវមនុស្សដែលមានគុណវុឌ្ឍិខ្ពស់បំផុត និងមានទឹកចិត្តបំពេញការងារបានល្អ។ គ្រូបង្រៀននឹងទទួលបានការគាំទ្រជាប្រចាំ ដើម្បីឱ្យពួកគេអាចអភិវឌ្ឍចំណេះដឹង និងសមត្ថភាព សម្រាប់លើកកម្ពស់ការសិក្សារៀនសូត្ររបស់សិស្ស។ ការបង្រៀន គឺជាវិជ្ជាជីវៈប្រកបដោយក្រមសីលធម៌ ក្នុងនោះ គ្រូបង្រៀនត្រូវបំពេញការងារប្រកបដោយស្តង់ដាវិជ្ជាជីវៈ និងមានសីលធម៌ខ្ពស់បំផុត ដើម្បីធានាឱ្យសិស្សគ្រប់រូបរបស់ខ្លួនអាចទទួលបានជោគជ័យ។

- បន្ទប់រៀនកម្ពុជា ជាបន្ទប់រៀនវៃឆ្លាត ដែលផ្តល់ឱ្យសិស្សនូវឱកាសល្អបំផុត សម្រាប់ការរៀនសូត្រ។ បន្ទប់រៀនត្រូវប្រែក្លាយជាបណ្តើរៗទៅជាបន្ទប់រៀនវៃឆ្លាត ដោយបំពាក់ធនធានអប់រំ និងបច្ចេកវិទ្យា ដើម្បីផ្តល់នូវបរិយាកាសសិក្សា ដែលមានការរៀបចំដោយប្រយ័ត្នប្រយែង មានសុវត្ថិភាព និងមានលក្ខណៈអំណោយផលសម្រាប់ការសិក្សាទាំងអស់គ្នា។ គ្រូបង្រៀននឹងប្តូរតួនាទីទៅជាអ្នកសម្របសម្រួលការរៀនសូត្រ ដោយបំពេញតួនាទីជាអ្នកបង្កើតឱកាសរៀនសូត្រ សម្រាប់ទាំងអស់គ្នា តាមរយៈការប្រើប្រាស់វិធី សាស្ត្របង្រៀនបែបអន្តរកម្ម បែបសហការ និងវិធីសាស្ត្រចម្រុះ។

- សិស្សមានសុខភាពល្អ មានការលើកទឹកចិត្ត និងមានការប្តេជ្ញាចិត្តសម្រាប់អនាគតរបស់កម្ពុជា។ កម្ពុជានឹងមានសិស្សដែលមានសុខភាពល្អ ត្រៀមខ្លួនបានល្អ និងទទួលបានការលើកទឹកចិត្ត ក៏ដូចជាការ

ប្ដេជ្ញាចិត្តសិក្សារៀនសូត្រ ដោយមិនប្រកាន់ពីសាវតារខ្លួន និងទទួលបានបរិយាកាសសិក្សាដែលមានលក្ខណៈអំណោយផល។ សិស្សនឹងទទួបានការគាំទ្រពីគ្រូបង្រៀនដែលមានសមត្ថភាព និងគុណវុឌ្ឍិវិជ្ជាជីវៈ ក៏ដូចជាពីសំណាក់សមាជិកគ្រួសារ និងសហគមន៍របស់ពួកគេ។ បន្ទាប់ពីបញ្ចប់ការសិក្សា ពួកគេនឹងមានជំនាញទាំងរឹងទាំងទន់ ចេះធ្វើការវិនិច្ឆ័យប្រកបដោយក្រមសីលធម៌បានល្អ មានភាពវៃឆ្លាតខាងអារម្មណ៍ ក៏ដូចជាមានស្មារតីជាតិ និងភាពជាប្រជាពលរដ្ឋសកលក្នុងកម្រិតមួយខ្ពស់ ដែលផ្ដល់លទ្ធភាពឱ្យពួកគេអាចរួមចំណែក និងចូលរួមក្នុងសង្គមយ៉ាងសកម្ម។

អាទិភាពគោលនយោបាយទាំងនេះ នឹងត្រូវអនុវត្តតាមដំណាក់កាលនីមួយៗនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ រហូតដល់ឆ្នាំ២០៣០ ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ស្ដីពីការអប់រំនៅកម្ពុជា ដោយមានកំណត់យន្តការ យុទ្ធសាស្ត្រ និងកម្មវិធី ព្រមទាំងការគាំទ្រហិរញ្ញវត្ថុសម្រាប់ការអនុវត្តផងដែរ។

### ២.៣.៥ ចក្ខុវិស័យ បេសកកម្ម របស់ក្រសួងអប់រំ យុវជន និងកីឡា២០១៦-២០៣០

ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា ២០១៦-២០៣០ គឺកសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយទៅជាសង្គមរីកចម្រើន ផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។

បេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺដឹកនាំគ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា ឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌របស់កម្ពុជា និងការរីកចម្រើននៅក្នុងតំបន់ និងសកលលោក។

វត្ថុបំណងរយៈពេលវែងរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺអភិវឌ្ឍយុវជនកម្ពុជាលើគ្រប់វិស័យ និងបណ្ដុះស្មារតីយុវជន យុវតីកម្ពុជាគ្រប់រូបឱ្យមានមនសិការស្នេហាជាតិ មោទនភាពជាតិ សីលធម៌ល្អ និងគុណធម៌ខ្ពស់ ព្រមទាំងមានសុទិដ្ឋិនិយមចំពោះប្រទេសជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន។

វត្ថុបំណងចំពោះមុខរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺធានាថាយុវជន និងកុមារកម្ពុជាគ្រប់រូបមានឱកាសស្មើគ្នា ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពស្របតាមរដ្ឋធម្មនុញ្ញ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ពោលគឺគោលការណ៍មិនរើស អើងអំពីស្ថានភាពសង្គម ភូមិសាស្ត្រ ជនជាតិ សាសនា ភាសា ភេទ និងកាយសម្បទា។ ក្រសួងសង្ឃឹមទុកថា នៅពេលដែលសិស្ស និស្សិតបានបញ្ចប់ការសិក្សារបស់ខ្លួនពួកគេនឹងមានចំណេះដឹង ជំនាញវិជ្ជាជីវៈ សមត្ថភាព គុណធម៌ និងសីលធម៌ល្អ ស្របតាមស្តង់ដាមួយសមស្រប ព្រមទាំងអាចប្រកួតប្រជែងនៅលើទីផ្សារការងារក្នុងតំបន់ និងលើសកលលោក និងអាចក្លាយជាកម្លាំងស្នូលសម្រាប់ជំរុញការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសជាតិ។

### ២.៣.៦ គោលនយោបាយអប់រំរយៈពេលមធ្យម

ក្នុងគោលបំណងរួមចំណែកសម្រេចយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ក៏ដូចជាយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ នៃរាជរដ្ឋាភិបាលកម្ពុជា និងអាទិភាពគោលនយោបាយនៃផែនទីបង្ហាញផ្លូវសម្រាប់គោលដៅអភិវឌ្ឍន៍ដោយចីរភាព ឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡាបានប្តូរគោលនយោបាយអប់រំបីមកត្រឹមពីរក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ដូចខាងក្រោមៈ

- គោលនយោបាយទី១ៈ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា
- គោលនយោបាយទី២ៈ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

វត្ថុបំណងគោលនយោបាយទី១ៈ កុមារគ្រប់រូបបានទទួលសេវាអប់រំកុមារតូចតាមគ្រប់រូបភាព។ បានចូលរៀននៅបឋមសិក្សា មធ្យមសិក្សា និងមានឱកាសបន្តការសិក្សាទៅមុខទៀត ព្រមទាំងផ្តល់នូវជម្រើស

ផ្សេងៗទៀតដល់កុមារ និងយុវជនដែលពុំមានលទ្ធភាពទទួលបានសេវាអប់រំក្នុងប្រព័ន្ធ។ កុមារ យុវជនគ្រប់រូបទទួលបានលទ្ធផលសិក្សានៅគ្រប់កម្រិតប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ជាពិសេស កុមារមកពីគ្រួសារជួបការលំបាក យុវជនក្រៅសាលា និងទទួលបាននូវចំណេះដឹង ជំនាញបច្ចេកទេស បំណិនគិត និងបំណិនអរូបវន្ត ឆ្លើយតបនឹងបរិបទសង្គមពុទ្ធិ និងវិបុលភាព និងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស។ ក្របខណ្ឌគុណភាពដែលផ្តល់ដល់អ្នកសិក្សាត្រូវមានការគាំទ្រ និងការចូលរួមពីមាតាបិតា សហគមន៍ គ្រូបង្រៀន និងអ្នកគ្រប់គ្រងជាមួយនឹងស្តង់ដានៃផលសម្រេចការពិនិត្យតាមដាន និងរបាយការណ៍។

វត្ថុបំណងគោលនយោបាយទី២៖ ការផ្តល់សេវាអប់រំអនុវត្តប្រកបដោយប្រសិទ្ធភាព និងទន់ភ្លន់។ ការគ្រប់គ្រងប្រកបដោយភាពស័ក្តិសិទ្ធិ ផ្តល់នូវតម្លៃដ៏ល្អបំផុត(ផ្តោតលើលទ្ធផល) ទាន់ពេលវេលា ការ ពិនិត្យតាមដាន និងរបាយការណ៍សមិទ្ធកម្ម និងយោបល់ត្រឡប់ វិធានការប្រកបដោយគណនេយ្យភាព និងយន្តការសម្រាប់កែលម្អគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ។ ការគ្រប់គ្រងគ្រឹះស្ថានសិក្សា ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ត្រូវបង្កើនស្វ័យភាព និងទទួលខុសត្រូវគណនេយ្យភាពចំពោះលទ្ធផលនៃការសិក្សាប្រកបដោយគុណភាពខ្ពស់សម្រាប់ទាំងអស់គ្នា។

## ២.៤ ផែនការអនុវិស័យ ការអប់រំកុមារតូចឆ្នាំ២០១៩-២០២៣

### ២.៤.១ សាវតារ

ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំគោលនយោបាយជាច្រើន ក្នុងគោលបំណងពង្រឹងគុណភាពនៃការអប់រំកុមារតូច និងបានដាក់ចេញនូវអន្តរាគមន៍ជាគោលនយោបាយ នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ដែលជាមូលដ្ឋានគ្រឹះជួយលើកកម្ពស់គុណភាពនៃការអប់រំកុមារតូចចាប់ពីឆ្នាំ២០១៩។ គោលនយោបាយទាំងនោះរួមមាន គោលនយោបាយ និងផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ការធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច ប្រកាសស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ ប្រកាសស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាឯកជន ប្រកាសស្តីពីការទទួល

ស្គាល់គ្រូបង្គោលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គោលការណ៍ប្រតិបត្តិសម្រាប់មត្តេយ្យសិក្សាសហគមន៍ កម្មវិធីអប់រំមាតាបិតារួមមានស្ត្រីមានផ្ទៃពោះ មាតាបិតាមានកូនអាយុក្រោម២ឆ្នាំ និងគោលការណ៍ប្រតិបត្តិសម្រាប់សាលាមត្តេយ្យសិក្សាធនធាន។

ផ្អែកតាមអន្តរាគមន៍ខាងលើ ភាគរយកុមារអាយុ៣-៥ឆ្នាំ ទទួលបានសេវាអប់រំកុមារតូចគ្រប់រូបភាពមានការកើនពីឆ្នាំ២០១៤ ដល់២០១៨។ ទោះយ៉ាងណា លទ្ធភាពទទួលបានសេវាអប់រំកុមារតូចនៅមានកម្រិតទាប ជាពិសេសកុមាររស់នៅតាមតំបន់ជួបការលំបាក ដោយយោងតាមរបាយការណ៍សន្និបាតអប់រំនៅឆ្នាំ២០១៨។ ដូចនេះ ក្រសួងនឹងរៀបចំយុទ្ធសាស្ត្រសមស្រប ដើម្បីបង្កើនការទទួលសេវាអប់រំកុមារតូច ជាពិសេស កុមាររស់ក្នុងតំបន់ដាច់ស្រយាល និងតំបន់ជនបទ ឬកុមារដែលធ្វើចំណាកស្រុក។

ក្រសួងបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រអាទិភាពនានា ក្នុងគោលបំណងពង្រឹងសេវាអប់រំកុមារតូចឱ្យមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់គុណភាពមត្តេយ្យសិក្សាឱ្យស្របតាមស្តង់ដា ព្រមទាំងពង្រឹងសមត្ថភាពអ្នកគ្រប់គ្រងអនុវិស័យអប់រំកុមារតូច។

### ២.៤.២ វត្ថុបំណង

- បង្កើនលទ្ធភាពទទួលបានសេវាអប់រំកុមារតូចប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន
- បន្តអភិវឌ្ឍសាលាមត្តេយ្យសិក្សាស្របតាមស្តង់ដាគុណភាព
- ពង្រឹងសមត្ថភាពអ្នកគ្រប់គ្រងអនុវិស័យអប់រំកុមារតូច និងអនុវត្តការគ្រប់គ្រងតាមសាលារៀន

### ២.៤.៣ សកម្មភាពគោលនយោបាយ

គោលនយោបាយទី១៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

- រៀបចំអនុក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលគាំពារ និងអភិវឌ្ឍន៍កុមារតូចនៅតាមស្ថាប័នរដ្ឋ រោងចក្រសហគ្រាសនៅឆ្នាំ២០២០ (អកត/នក)

- រៀបចំសៀវភៅណែនាំប្រតិបត្តិស្តីពីការអនុវត្តកម្មវិធីអប់រំមាតាបិតានៅឆ្នាំ២០១៩ (អកត)
- រៀបចំប្រកាសស្តីពីការអនុវត្តសាលាមត្តេយ្យសិក្សារដ្ឋនៅឆ្នាំ២០១៩ (អកត/នក)
- រៀបចំសេចក្តីណែនាំស្តីពីការផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់គ្រូមត្តេយ្យសិក្សាបង្រៀនពីរវេននៅឆ្នាំ ២០១៩ (អកត និងបល)
- រៀបចំសេចក្តីណែនាំស្តីពីការបង្កើតថ្នាក់មត្តេយ្យសិក្សាក្នុងសាលាបឋមសិក្សានៅឆ្នាំ២០១៩ (អកត/នក)
- រៀបចំលក្ខខណ្ឌការងារស្តីពីតួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីអប់រំកុមារតូចគ្រប់លំដាប់ថ្នាក់នៅឆ្នាំ២០១៩ (អកត/បល)
- រៀបចំសេចក្តីណែនាំស្តីពីស្តង់ដាអប្បបរមាសាលាមត្តេយ្យសិក្សា និងថ្នាក់មត្តេយ្យសិក្សារដ្ឋ នៅឆ្នាំ២០១៩ (អកត)
- រៀបចំសេចក្តីណែនាំស្តីពីការប្រែក្លាយមត្តេយ្យសិក្សាសហគមន៍ដែលមានស្តង់ដាទៅជាឧបសម្ព័ន្ធនៃគ្រឹះស្ថានសិក្សារដ្ឋនៅឆ្នាំ២០១៩ (អកត/នក)

### ២.៤.៤ យុទ្ធសាស្ត្រ និងសកម្មភាព

#### ២.៤.៤.១ វត្ថុបំណងអនុវិស័យទី១៖ បង្កើនលទ្ធភាពទទួលបានសេវាអប់រំកុមារតូចប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន

យុទ្ធសាស្ត្រ១.១៖ បន្តបង្កើតថ្នាក់មត្តេយ្យសិក្សានៅតាមសាលាបឋមសិក្សា និងអភិវឌ្ឍសាលាមត្តេយ្យសិក្សារដ្ឋ

- សិក្សាពីតម្រូវការសាងសង់រួមទាំងទឹកស្អាត និងសម្ភាររូបវន្តអនាម័យ និងសួនកុមារស្របតាមស្តង់ដាសាលាមត្តេយ្យសិក្សា
- ជំរុញការបង្កើតថ្នាក់មត្តេយ្យសិក្សានៅក្នុងសាលាបឋមសិក្សា

- បង្កើតហេដ្ឋារចនាសម្ព័ន្ធមត្តេយ្យសិក្សានៅតាមតំបន់លិចទឹក និងតំបន់ដាច់ស្រយាលជួបការលំបាក
- សាងសង់ និងកែលម្អសម្ភាររូបវន្ត រួមទាំងទឹកស្អាត និងសម្ភាររូបវន្តអនាម័យ សួនកុមារបំពាក់ឧបករណ៍ការពាររន្ទះ និងឧបករណ៍ស្របតាមស្តង់ដា
- កែលម្អហេដ្ឋារចនាសម្ព័ន្ធនិងសម្ភាររូបវន្តនៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម

យុទ្ធសាស្ត្រ១.២៖ អភិវឌ្ឍមត្តេយ្យសិក្សាសហគមន៍ដែលមានស្តង់ដាទៅជាឧបសម្ព័ន្ធនៃគ្រឹះស្ថានសិក្សារដ្ឋ និងប្រែក្លាយមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដាឱ្យទៅជាមត្តេយ្យសិក្សារដ្ឋ។

- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំស្តីពីការប្រែក្លាយមត្តេយ្យសិក្សាសហគមន៍ទៅជាឧបសម្ព័ន្ធនៃគ្រឹះស្ថានសិក្សារដ្ឋដល់មន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡា
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សង្ហារិម សួនកុមារ និងសម្ភារក្មេងលេង តាមស្តង់ដាមត្តេយ្យសិក្សា
- អភិវឌ្ឍសមត្ថភាពគ្រូមត្តេយ្យសិក្សាលើការបង្រៀន និងរៀនតាមរយៈវិក្រឹតការ
- រៀបចំផែនទីសិក្សាសម្រាប់ពង្រីកកម្មវិធីអប់រំពហុភាសានៅមត្តេយ្យសិក្សាសហគមន៍

យុទ្ធសាស្ត្រ១.៣៖ លើកកម្ពស់កម្មវិធីអប់រំមាតាបិតាតាមគ្រឹះស្ថានសិក្សាសាធារណៈ ជាពិសេសអន្តរាគមន៍ការគាំពារកុមារក្នុងរយៈពេល១០០០ថ្ងៃដំបូងនៃកំណើត (អាយុ ០ ទៅ ៣ឆ្នាំ)

- បង្កើតទារកដ្ឋានសម្រាប់កុមារអាយុពី១ឆ្នាំ ដល់៣ឆ្នាំ និងមណ្ឌលថែទាំកុមារ ព្រមទាំងផ្តល់ការពិគ្រោះយោបល់ដល់ស្ត្រីមានផ្ទៃពោះ
- រៀបចំកម្មវិធីប្រឹក្សាយោបល់ពាក់ព័ន្ធការថែទាំនិងអប់រំកូន ការថែទាំស្ត្រីមានផ្ទៃពោះតាមសាលាមត្តេយ្យសិក្សារដ្ឋ និងមត្តេយ្យសិក្សាសហគមន៍
- ជំរុញការបង្កើតទារកដ្ឋាននៅតាមរោងចក្រ សហគ្រាស និងគ្រឹះស្ថានរដ្ឋ
- រៀបចំកម្មវិធីអប់រំមាតាបិតាឱ្យជួយអប់រំកុមារតូចនៅតំបន់ជនបទ។

យុទ្ធសាស្ត្រ១.៤៖ ពង្រីកកម្មវិធីអប់រំបរិយាបន្នសម្រាប់កុមារមានពិការភាពនៅមត្តេយ្យសិក្សារដ្ឋ និងមត្តេយ្យសិក្សាសហគមន៍

- បំប៉នសមត្ថភាពគ្រូបង្គោល និងគ្រូមត្តេយ្យសិក្សាស្តីពីការអប់រំបរិយាបន្ន
- បង្កើតឧបករណ៍ប្រមូលទិន្នន័យសម្រាប់កម្មវិធីអប់រំបរិយាបន្ននៅតាមសាលាមត្តេយ្យសិក្សា

យុទ្ធសាស្ត្រ១.៥៖ ផ្តល់ទឹកស្អាត អនាម័យ និងអាហារូបត្ថម្ភ ព្រមទាំងលើកកម្ពស់សុខភាពនៅតាមសាលាមត្តេយ្យសិក្សា

- ពង្រីកការអនុវត្តកម្មវិធីទឹកស្អាត និងអនាម័យនៅតាមសាលាមត្តេយ្យសិក្សា
- សម្របសម្រួលសេវាថែទាំសុខភាពជាមូលដ្ឋានដល់កុមារ និងគ្រូបង្រៀន
- អនុវត្តសាកល្បងកម្មវិធីផ្តល់អាហារនៅតាមសាលាមត្តេយ្យសិក្សា
- ផ្សព្វផ្សាយសេចក្តីណែនាំអំពីសុវត្ថិភាពចំណីអាហារ និងអាហារមានគុណភាព
- ពិនិត្យតាមដាន និងចាត់វិធានការការពារជំងឺឆ្លងនានានៅតាមគ្រឹះស្ថានសិក្សា និងជំរុញការថែទាំបង្គន់អនាម័យ។

### ២.៤.៤.២ វត្ថុបំណងអនុវិស័យទី២៖ បន្តអភិវឌ្ឍសាលាមត្តេយ្យសិក្សាឱ្យស្របតាមស្តង់ដាគុណភាព

យុទ្ធសាស្ត្រ២.១៖ ពង្រឹងគុណភាពនៃការបណ្តុះបណ្តាល និងវិក្រឹតការគ្រូមត្តេយ្យសិក្សាឱ្យឆ្លើយតបតាមស្តង់ដា

- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាឱ្យស្របតាមក្របខណ្ឌកម្មវិធីសិក្សា និងប្រព័ន្ធក្រេឌីត
- អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាឱ្យឆ្លើយតបបំណិនសតវត្សរ៍ទី២១ រួមទាំងជំនាញទន់សម្រាប់មត្តេយ្យសិក្សារដ្ឋ និងឯកជន

- អភិវឌ្ឍសមត្ថភាពគ្រូមត្តេយ្យសិក្សារដ្ឋ ស្តីពីមូលដ្ឋានគ្រឹះនៃការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- រៀបចំសៀវភៅណែនាំសម្រាប់ការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា
- ពិនិត្យតាមដាន និងវាយតម្លៃសមត្ថភាពវិជ្ជាជីវៈរបស់គ្រូមត្តេយ្យសិក្សាចេញថ្មី
- បង្កើនការជ្រើសរើសគ្រូមត្តេយ្យសិក្សាសម្រាប់សាលាមត្តេយ្យសិក្សារដ្ឋ
- បន្តសហការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសហគមន៍
- គ្រប់គ្រងទិន្នន័យលើការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា
- ជ្រើសរើសសាលាមត្តេយ្យសិក្សាដែលមានសក្តានុពល និងប្រែក្លាយទៅជាមត្តេយ្យសិក្សាធនធាន
- បណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសម្រាប់សាលាមត្តេយ្យសិក្សាឯកជន និងសហគមន៍។

យុទ្ធសាស្ត្រ២.២៖ ពង្រឹងអធិការកិច្ច និងវាយតម្លៃប្រព័ន្ធសេវាអប់រំកុមារតូច

- អភិវឌ្ឍសមត្ថភាពអធិការស្តីពីអធិការកិច្ចតាមប្រធានបទ និងតាមកាលកំណត់
- អភិវឌ្ឍសមត្ថភាពនាយកសាលាមត្តេយ្យសិក្សាលើស្វ័យវង្វាយតម្លៃសាលារៀន
- អភិវឌ្ឍប្រព័ន្ធធ្វើតេស្តកុមារ (អាយុ៥ឆ្នាំ) ស្របតាមសេចក្តីណែនាំកម្មវិធីសិក្សាថ្មី
- អភិវឌ្ឍប្រព័ន្ធទទួលមតិយោបល់ត្រឡប់ពីរបាយការណ៍អធិការកិច្ច និងវង្វាយតម្លៃកម្មវិធីសិក្សា ការបណ្តុះបណ្តាលគ្រូ និងការបង្រៀននិងការរៀន។

យុទ្ធសាស្ត្រ២.៣៖ ពង្រឹងការអនុវត្តកម្មវិធីសិក្សា ការប្រើប្រាស់សម្ភារបង្រៀន និងរៀនសម្រាប់ការអប់រំកុមារតូច ស្របតាមស្តង់ដា

- អភិវឌ្ឍសមត្ថភាពគ្រូមត្តេយ្យសិក្សាស្តីពីការអនុវត្តកម្មវិធីសិក្សាថ្មី

- កែសម្រួលសៀវភៅសិក្សាគោលស្របតាមកម្មវិធីសិក្សាថ្មី
- ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តម៉ោងសិក្សាគ្រប់មុខវិជ្ជា និងវិធីសាស្ត្របង្រៀន ស្របតាមកម្មវិធីសិក្សាលម្អិត។

**២.៤.៤.៣ វត្ថុបំណងអនុវិស័យទី៣៖ ពង្រឹងសមត្ថភាពអ្នកគ្រប់គ្រងអនុវិស័យអប់រំកុមារតូចនិងអនុវត្តការគ្រប់គ្រងតាមសាលារៀន**

យុទ្ធសាស្ត្រ៣.១៖ អភិវឌ្ឍសមត្ថភាព និងពង្រឹងយន្តការអនុវត្តតួនាទី និងទំនួលខុសត្រូវរបស់មន្ត្រីគ្រប់គ្រងអនុវិស័យអប់រំកុមារតូច

- រៀបចំពិពណ៌អំពីតួនាទី មុខដំណែង និងទំនួលខុសត្រូវឱ្យបានច្បាស់លាស់សម្រាប់មន្ត្រីគ្រប់គ្រង
- រៀបចំផែនការអភិវឌ្ឍសមត្ថភាពសម្រាប់មន្ត្រីគ្រប់គ្រងអនុវិស័យអប់រំកុមារតូច
- រៀបចំប្រព័ន្ធវាយតម្លៃការគ្រប់គ្រងការបំពេញការងារមន្ត្រីអប់រំកុមារតូចគ្រប់លំដាប់ថ្នាក់តាមប្រព័ន្ធព័ត៌មានវិទ្យា
- អភិវឌ្ឍប្រព័ន្ធប្រឹក្សាយោបល់ និងការហ្វឹកហាត់លើការងារគ្រប់គ្រងអប់រំកុមារតូច។

យុទ្ធសាស្ត្រ៣.២៖ ពង្រឹងអភិបាលកិច្ចល្អលើការងារអប់រំកុមារតូច និងការរៀបចំផែនការផ្អែកលើលទ្ធផលការគ្រប់គ្រង និងការពិនិត្យតាមដាន និងវាយតម្លៃតាមរយៈការអនុវត្តការគ្រប់គ្រងតាមសាលារៀន

- ពង្រឹងប្រព័ន្ធរាយការណ៍ការរៀបចំផែនការផ្អែកលើលទ្ធផល ការគ្រប់គ្រង និងការពិនិត្យតាមដាន និងវាយតម្លៃ
- អភិវឌ្ឍសមត្ថភាពក្នុងភាពជាអ្នកដឹកនាំ និងគ្រប់គ្រង ការរៀបចំផែនការ ការពិនិត្យតាមដាន និងវាយតម្លៃផ្តោតលើលទ្ធផលមត្តេយ្យសិក្សារដ្ឋ

• អភិវឌ្ឍសមត្ថភាពមន្ត្រីទទួលបន្ទុកការងារអប់រំកុមារតូច និងនាយក នាយិកាសាលាមត្តេយ្យសិក្សាស្តីពីការអនុវត្តការគ្រប់គ្រងសាលារៀន

• អនុវត្តការគ្រប់គ្រងតាមសាលារៀនមត្តេយ្យសិក្សារដ្ឋ (អ.យ.ក., ២០១៩)។

## ២.៥ ស្តង់ដានាយកសាលារៀន

### ២.៥.១ ស្តង់ដាទី១៖ កម្រិតវប្បធម៌ និងបទពិសោធន៍

នាយកសាលរៀន ត្រូវមាន៖

- កម្រិតវប្បធម៌យ៉ាងទាបបំផុតបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល ឬប្រសិទ្ធផលគ្រប់គ្រាន់ (នាយកល្អប្រចាំឆ្នាំណាមួយ)
- វិញ្ញាបនបត្រវិជ្ជាជីវៈនាយកសាលារៀន
- ចំណេះដឹងមូលដ្ឋាន ចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ និងវប្បធម៌ទូលំទូលាយ
- ចំណេះដឹងជំនាញភាសាបរទេសអាចប្រើប្រាស់បានក្នុងការប្រាស្រ័យទាក់ទង
- បទពិសោធបំពេញការងារជាគ្រូបង្រៀនយ៉ាងតិច ៥ឆ្នាំ។

### ២.៥.២ ស្តង់ដាទី២៖ សមត្ថភាព និងគុណសម្បត្តិរបស់នាយកសាលារៀន

នាយកសាលារៀន ត្រូវមានសមត្ថភាព និងគុណសម្បត្តិដែលបង្ហាញពីភាពខ្លាំង និងប្រសិទ្ធភាពរបស់ខ្លួន ក្នុងការគ្រប់គ្រង និងបំពេញការងារឱ្យអស់ពីសមត្ថភាព និងលទ្ធភាព ដោយយកចិត្តទុកដាក់លើការអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់ខ្លួនជាប្រចាំ។

នាយកដែលមានប្រសិទ្ធភាពក្នុងការគ្រប់គ្រង ត្រូវដឹកនាំដោយធ្វើជាគំរូ បង្ហាញសកម្មភាពល្អៗប្រចាំថ្ងៃ ហ៊ានបង្ហាញពីតម្លាភាព និងគណនេយ្យភាព អ្វីៗដែលបានធ្វើត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ មានមោទកភាពលើវិជ្ជាជីវៈរបស់ខ្លួន ត្រូវបំពេញការងារឱ្យអស់ពីលទ្ធភាព និងសមត្ថភាពចេះជ្រើសរើសចំណុច

ណាជាអាទិភាពមកធ្វើមុន ហ៊ានធ្វើសេចក្តីសម្រេចចិត្តក្នុងការដោះស្រាយបញ្ហាប្រឈម បង្ហាញឥរិយាបថភាពជាសហគ្រិនភាព។ លើសពីនេះ នាយកសាលារៀន ចាំបាច់ត្រូវអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ក្នុងនោះមានស្វ័យសិក្សា ស្រាវជ្រាវ គាំទ្រតម្លៃទស្សនវិស័យរបស់អាស៊ាន។ សូចនាករសំខាន់ៗ៖

២.១ ក្រមសីលធម៌វិជ្ជាជីវៈ

- ការប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈគ្រូបង្រៀន
- ការពង្រឹងសាមគ្គីភាព
- ការគោរពវិន័យការងារ
- ការរក្សាការសម្ងាត់វិជ្ជាជីវៈ ភក្តីភាពចំពោះអង្គភាព ចំណេះដឹងវិជ្ជាជីវៈ ការផ្តល់តម្លៃអ្នកសិក្សា ការមិនរើសអើង ការមិនប្រើអំពើហិង្សា សីលធម៌រស់នៅល្អ ប្រកបដោយគុណធម៌ និងយុត្តិធម៌
- សុភវិនិច្ឆ័យ និងការពិគ្រោះយោបល់ផ្អែកលើភស្តុតាងជាក់ស្តែង។

២.២ ភាពជាអ្នកដឹកនាំ

- ចំណង់ចំណូលចិត្តក្នុងការសិក្សាស្រាវជ្រាវ ការស្វែងយល់អំពីរបកគំហើញថ្មីៗពាក់ព័ន្ធទៅនឹងការដឹកនាំ និងការគ្រប់គ្រងសាលារៀន
- ផ្តល់ឱកាស កិត្តិយស និងតម្លៃ ដល់សហការី
- មានជំនាញដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាពនិងមានការចូលរួម
- ស្វ័យវាយតម្លៃការងារប្រចាំថ្ងៃ ដើម្បីកែលម្អក្រោយពេលបំពេញការងារ (១០-១៥នាទី)
- មានបំណិនប្រសប់ក្នុងការកំណត់សកម្មភាពអាទិភាព ដែលត្រូវអនុវត្ត
- ធ្វើជាគំរូក្នុងការដឹកនាំ និងការប្រតិបត្តិល្អៗសម្រាប់ភាគីពាក់ព័ន្ធទាំងអស់
- មានការសម្រេចចិត្តត្រឹមត្រូវ និងមានប្រសិទ្ធភាពផ្អែកតាមលក្ខខណ្ឌ តម្រូវការតាមមូលដ្ឋាន និងគោលនយោបាយជាតិជំរុញឱ្យមានការយល់ដឹងពីពហុវប្បធម៌ និងគោរពពីភាពដទៃពីគ្នា។

២.៣ ការប្តេជ្ញាចិត្ត

- ឆន្ទៈក្នុងការកសាងជំនឿទុកចិត្តដល់អង្គភាព ហ៊ាននិយាយ ហ៊ានធ្វើ ហ៊ានទទួលខុសត្រូវ
- ការយល់ដឹង ស្រឡាញ់ ថែរក្សា និងការពារបរិស្ថានឱ្យបានស្អាតល្អ
- ការអត់ធ្មត់ និងចេះសម្របខ្លួនក្នុងស្ថានការណ៍លំបាក។

**២.៥.៣ ស្តង់ដាទី៣៖ បំណិនត្រិះរិះពិចារណា និងនវានុវត្តន៍**

ការគិត និងការវិភាគដោយប្រមូលភស្តុតាង ទិន្នន័យ និងស្នើជាសេណារីយ៉ូ ក្នុងការដោះស្រាយបញ្ហា ព្រមទាំងគិតទៅលើគំនិតថ្មីៗ ធ្វើឱ្យប្រសើរឡើងក្នុងការបំពេញការងារ។

នាយកសាលារៀនចាំបាច់ត្រូវស្វែងយល់អំពីក្រខ័ណ្ឌគតិយុត្ត តាមរយៈការអភិវឌ្ឍសមត្ថភាព ការពង្រឹងយន្តការ និងគោលការណ៍ជំរុញប្រសិទ្ធភាពការងារ ដោយមានការចូលរួម ដើម្បីធ្វើការសម្រេចចិត្តបានត្រឹមត្រូវ។ សូចនាករសំខាន់ៗ៖

៣.១ ចក្ខុវិស័យ បេសកកម្ម គោលនយោបាយ និងផែនការយុទ្ធសាស្ត្រ

- យល់ដឹង និងផ្សព្វផ្សាយអំពីគោលនយោបាយ គោលការណ៍ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួង
- យល់ដឹងអំពីទិសដៅរបស់ក្រសួង និងអភិវឌ្ឍចក្ខុវស័យ បេសកកម្ម និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន( ៥ឆ្នាំ ៣ឆ្នាំ ១ឆ្នាំ )
- ផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនដល់អ្នកពាក់ព័ន្ធក្នុងគោលដៅអនុវត្តឱ្យមានប្រសិទ្ធភាព។

៣.២ ការអនុវត្តចក្ខុវិស័យ និងផែនការសកម្មភាព

- ការរៀបចំបែងចែកការងារ ភារកិច្ច និងការទទួលខុសត្រូវទៅតាមសមត្ថភាពបច្ចេកទេស និងរចនាសម្ព័ន្ធ

- ការគ្រប់គ្រង និងបែងចែកធនធានក្នុងអង្គភាព (ថវិកា មនុស្ស សម្ភារៈ និងព័ត៌មាន)។

៣.៣ ការត្រួតពិនិត្យ និងវាយតម្លៃការងារ

- ស្វ័យវាយតម្លៃអំពីការបំពេញការងារ និងការកែលម្អ
- បណ្តុះគំនិត ឆន្ទៈ មនសិការ និងការប្តេជ្ញាចិត្តដល់បុគ្គលិកឱ្យចេះស្រឡាញ់ការងាររបស់ខ្លួន និងរបស់អង្គភាព ឬស្ថាប័ន
- អនុវត្តចក្ខុវិស័យ បេសកកម្ម គោលនយោបាយ គោលការណ៍ និងលិខិតបទដ្ឋានគតិយុត្តនានា
- សហការក្នុងការបំពេញការងារប្រកបដោយភាពរីកចម្រើន និងមានជំនឿជាក់
- តាមដាន ប្រមូល វិភាគទិន្នន័យ និងព័ត៌មាននានាពីប្រភពផ្សេងៗ ដើម្បីប្រសិទ្ធភាពនៃការដឹកនាំ និងគ្រប់គ្រង
- ការដោះស្រាយទាន់ពេលវេលារាល់សំណូមពរ និងបញ្ហានានាក្នុងគោលដៅកែលម្អប្រសិទ្ធភាពការងារ
- ផ្តល់ទិន្នន័យ និងព័ត៌មានដល់ថ្នាក់ដឹកនាំតាមឋានានុក្រម និងតាមតម្រូវការចាំបាច់។

### ២.៥.៤ ស្តង់ដាទី៤៖ ភាពជាអ្នកដឹកនាំគ្រប់គ្រងរដ្ឋបាលសាលារៀន

ការគ្រប់គ្រងរដ្ឋបាលសាលារៀន ជាភារកិច្ចសំខាន់មួយរបស់អ្នកដឹកនាំក្នុងការធ្វើឱ្យប្រសើរឡើងផ្នែកគុណភាព និងប្រសិទ្ធភាពដើម្បីធ្វើការវាស់ស្ទង់ និងដោះស្រាយបញ្ហាចំពោះមុខលើការរៀបចំអង្គភាពមួយដោយផ្អែកលើលិខិតបទដ្ឋានគតិយុត្តនានា សំដៅធ្វើឱ្យមានការអភិវឌ្ឍលើផ្នែកដូចជាបរិស្ថាន ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងហិរញ្ញវត្ថុ និយតភាពការងារ និងត្រួតពិនិត្យវាយតម្លៃ ការផ្តល់សេវា ការគ្រប់គ្រងទិន្នន័យស្ថិតិបុគ្គលិក ថ្នាក់ សិស្ស ការរៀបចំផែនការសកម្មភាព និងថវិកា ដើម្បីបង្ហាញភស្តុតាងជាក់លាក់ក្នុងការអនុវត្តអ្វីដែលថ្មីរបស់នាយកសាលារៀន។

សូចនាករសំខាន់ៗរួមមាន៖

៤.១ ការគ្រប់គ្រងរដ្ឋបាល

- បង្កើតវប្បធម៌ទំនាក់ទំនងរវាងគ្រូបង្រៀន និងថ្នាក់ដឹកនាំ
- ចាត់ចែងការប្រើប្រាស់ធនធាននានាឱ្យមានប្រសិទ្ធភាព និងចំគោលដៅ
- ដឹកនាំ និងសម្របសម្រួលការរៀបចំផែនការ និងថវិកា ដោយធ្វើវិចារណកម្មចំណាយ និងការចាត់អាទិភាពចំណាយ
- រៀបចំប្រព័ន្ធគ្រប់គ្រងគណនេយ្យ និងហិរញ្ញវត្ថុប្រកបដោយតម្លាភាព គណនេយ្យភាព សុវត្ថិភាព និងភាពអាចជឿទុកចិត្តបាន
- រៀបចំរចនាសម្ព័ន្ធបែងចែកតួនាទី និងភារកិច្ចដល់បុគ្គលិកតាមជំនាញប្រកបដោយប្រសិទ្ធភាព
- រៀបចំ និងបង្កើតគណៈកម្មការ និងក្រុមប្រឹក្សានានា
- រៀបចំទុកដាក់លិខិតស្នាមនានា និងឯកសារគណនេយ្យ ស្របតាមគោលការណ៍ណែនាំ
- ធ្វើប្រិតភូកម្មឱ្យមានប្រសិទ្ធភាព ដើម្បីសម្រេចគោលបំណងរបស់ផែនការយុទ្ធសាស្ត្រ
- បង្កើនការគ្រប់គ្រង ការដឹកនាំ និងសមិទ្ធកម្មប្រកបដោយគណនេយ្យភាព
- រៀបចំប្រព័ន្ធទ្រព្យសម្បត្តិរបស់សាលារៀន
- បង្ហាញសមត្ថភាពក្នុងការគិតប្រកបដោយការច្នៃប្រឌិត ការឆ្លុះបញ្ចាំង ការត្រិះរិះពិចារណា និងការដោះស្រាយបញ្ហា
- ដឹកនាំអង្គប្រជុំប្រកបដោយប្រសិទ្ធភាព ដោយប្រើប្រាស់រយៈពេលខ្លី មានចំណុចពិភាក្សាច្បាស់លាស់ និងសម្រេចលទ្ធផលបានតាមការរំពឹងទុកពេលបញ្ចប់ការប្រជុំ
- ប្រើប្រាស់បច្ចេកវិទ្យាសម្រាប់គ្រប់គ្រងសាលារៀន និងបណ្តាញការងារប្រកបដោយប្រសិទ្ធភាព
- ចែករំលែកចំណេះដឹងថ្មីៗដល់សហការីអំពីបទពិសោធន៍ល្អៗរបស់សាលាដទៃ

- ដឹកនាំសិស្សជួយការងារសង្គម និងសហគមន៍ រួមមានការងារបរិស្ថាន អនាម័យ ចរាចរណ៍ ការប្រឆាំងគ្រឿងញៀន កាងារកសិកម្ម ការងារបុណ្យជាតិនិងអន្តរជាតិ ការផ្តល់ឈាម ការងារវប្បធម៌ សិល្បៈ ព័ត៌មាន ទេសចរណ៍ ការងារយុវជន និងកាយរឹទ្ធិជាដើម។

៤.២ ការគ្រប់គ្រងបុគ្គលិក

- ស្វែងយល់ពីសុខទុក្ខរបស់គ្រូ និងបុគ្គលិកក្នុងសាលា ដោយសិក្សាអំពីស្ថានភាពជីវភាពរបស់គ្រូ ព័ត៌មាននានាពាក់ព័ន្ធនឹងគ្រូបង្រៀន(ប្រវត្តិ ទីកន្លែងស្នាក់នៅ ឈ្មោះ លេខទូរសព្ទ ចំណង់ចំណូលចិត្ត និងថ្ងៃខែឆ្នាំចូលនិវត្តន៍)
- លើកទឹកចិត្តអ្នកដែលមានស្នាដៃល្អ ដោយស្នើដំឡើងថ្នាក់ ឋានន្តរស័ក្តិ ផ្តល់ប័ណ្ណសរសើរ
- ណែនាំដល់គ្រូបង្រៀនឱ្យចេះថែទាំសុខភាព អនាម័យ ការស្លៀកពាក់ ឥរិយាបថក្នុងការរស់នៅ និងធ្វើការងារ
- វាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀនប្រកបដោយតម្លាភាព
- បង្កលក្ខណៈងាយស្រួលដល់គ្រូបង្រៀន និងបុគ្គលិកអប់រំទាំងអស់នៅក្នុងសាលាឱ្យទទួលបានការសិក្សាបន្ថែម "ជំរុញឱ្យធ្វើការស្រាវជ្រាវដើម្បីពង្រីកចំណេះដឹងលើមុខវិជ្ជាបង្រៀន និងគរុកោសល្យ"
- លើកទឹកចិត្តឱ្យមានយេនឌ័រក្នុងការចូលរួមគ្រប់សកម្មភាព
- លើកកម្ពស់តម្លៃវិជ្ជាជីវៈគ្រូបង្រៀន និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន។

៤.៣ ការគ្រប់គ្រងហិរញ្ញវត្ថុ

- ពិនិត្យតាមដាន និងវាយតម្លៃលើលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន
- ប្រមូល និងវិភាគទិន្នន័យ ដើម្បីរៀបចំវាយតម្លៃគម្រោងផែនការឱ្យមានប្រសិទ្ធភាព។

**២.៥.៥ ស្តង់ដាទី៥៖ ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា និងការបង្រៀននិងរៀន**

ប្រសិទ្ធភាព នៃការអនុវត្តកម្មវិធីសិក្សា ការបង្រៀន និងរៀន មិនអាចកាត់ផ្តាច់ពីតួនាទីរបស់អ្នកដឹកនាំសាលារៀនដែលជាកត្តាជំរុញដ៏សំខាន់ ជានាដល់គុណភាពក្នុងការអនុវត្តការងាររបស់គ្រូបង្រៀន។ ស្តង់ដានេះជួយនាយកសាលារៀនឱ្យទទួលបានជោគជ័យក្នុងការធ្វើឱ្យសម្រេចចក្ខុវិស័យ គោលបំណង និងគោលដៅ។ នាយកសាលារៀនចាំបាច់ត្រូវដឹកនាំការអនុវត្ត និងការកែលម្អកម្មវិធីសិក្សា ការបង្កើត បរិស្ថាន និងបរិយាកាសសិក្សា ការធ្វើអធិការកិច្ច និងការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន និងការផ្តល់លទ្ធផលសិក្សា។ សូចនាករសំខាន់ៗរួមមាន៖

៥.១ ការគ្រប់គ្រងការរៀន និងបង្រៀន

- ធានាឱ្យមានសម្ភារៈសម្រាប់ដំណើរការបង្រៀននិងរៀន និងផ្តល់ឱកាសដល់គ្រូ សិស្សប្រើប្រាស់សម្ភារៈ និងធនធានសិក្សាទាំងឡាយដោយឈរលើស្មារតីថ្នៃប្រឌិត និងថែរក្សា
- ជំរុញ និងលើកទឹកចិត្តគ្រូប្រើចិត្តគរុកោសល្យច្បាស់លាស់ក្នុងការសម្របសម្រួលឱ្យសិស្សចេះរៀន
- រៀបចំធ្វើគម្រោងផែនការបង្រៀន និងអនុវត្តផែនការនេះឱ្យបានទៀងទាត់
- ជំរុញគ្រូធ្វើផែនការបង្រៀន និងអនុវត្តផែនការនោះបានត្រឹមត្រូវជាប្រចាំ
- សង្កេតការបង្រៀនរបស់គ្រូ និងផ្តល់ព័ត៌មានត្រឡប់ប្រកបដោយការលើកទឹកចិត្ត
- លើកទឹកចិត្តគ្រូឱ្យបង្រៀនដល់សិស្សគ្រប់ប្រភេទដោយមិនរើសអើង
- ជំរុញគ្រូបង្រៀនផ្តល់ការបង្រៀនឱ្យចប់កម្មវិធីសិក្សា និងស្របតាមតម្រូវការរបស់សិស្ស
- ជំរុញគ្រូបង្រៀនឱ្យលើកទឹកចិត្តសិស្សក្នុងការស្វ័យសិក្សាជាប្រចាំ
- បង្កបរិយាកាសរៀនសូត្រល្អប្រសើរ ប្រកបដោយភាពរីករាយ ស្និទ្ធស្នាល និងជំនឿជាក់។

៥.២ ការស្រាវជ្រាវ

- រៀបចំក្រុមបច្ចេកទេស និងប្រជុំបច្ចេកទេសឱ្យបានទៀងទាត់
- ចូលរួម និងជំរុញការសិក្សាស្រាវជ្រាវមេរៀន

- ស្រាវជ្រាវ និងរិះរកវិធីសាស្ត្រល្អៗ ដើម្បីឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព។

៥.៣ ការសហការ និងទំនាក់ទំនង

- រៀបចំប្រជុំបុគ្គលិក និងសហគមន៍ក្នុងការពិនិត្យ កែលម្អ អភិវឌ្ឍ និងអនុវត្តកម្មវិធីសិក្សា
- ផ្សព្វផ្សាយលទ្ធផលនៃការវាយតម្លៃជាផ្លូវការដល់ភាគីពាក់ព័ន្ធ
- រក្សាបាននូវវប្បធម៌សាមគ្គីភាព សន្តិភាព និងការគោរពគ្នាទៅវិញទៅមកតាមឋានានុក្រម។

៥.៤ ការអភិវឌ្ឍសមត្ថភាព

- អភិវឌ្ឍ និងប្រើប្រាស់ធនធានសិក្សាប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ
- លើកទឹកចិត្តដល់គ្រូបង្រៀនដែលបំពេញការងារបានល្អ
- ផ្តល់ឱកាសឱ្យគ្រូបង្រៀនបានទស្សនកិច្ចសិក្សានៅសាលាដែលល្អ
- សម្របសម្រួល និងជំរុញសកម្មភាពចែករំលែកចំណេះដឹង និងបទពិសោធន៍ទៅវិញទៅមក (បង្កើតកម្មវិធីអ្នកមានបទពិសោធន៍ច្រើនឱ្យជួយអ្នកមានបទពិសោធន៍តិច)

៥.៥ ការធ្វើអធិការកិច្ចផ្ទៃក្នុង

- ពិនិត្យតាមដាន និងវាយតម្លៃសកម្មភាព ដើម្បីកែលម្អលទ្ធផលសិក្សា
- វាយតម្លៃលទ្ធផលសិក្សា និងសរសេររបាយការណ៍អំពីវឌ្ឍនភាពនៃការបង្រៀន និងរៀន
- វាយតម្លៃចំណុចខ្លាំង និងចំណុចខ្វះខាត ដើម្បីកែលម្អលើវិធីសាស្ត្របង្រៀន។
- បង្កើតបរិស្ថានសិក្សាល្អ មានអនាម័យ សណ្តាប់ធ្នាប់ របៀបរៀបរយ និងគ្មានគ្រោះថ្នាក់
- វាយតម្លៃលទ្ធផលសិក្សារបស់សិស្សប្រកបដោយតម្លាភាព យុត្តិធម៌ ឱ្យបានទៀងទាត់
- ប្រើប្រាស់លទ្ធផលនៃការវាយតម្លៃ ជាប្រយោជន៍ដល់ការកែលម្អដំណើរការបង្រៀន និងរៀនឱ្យមានប្រសិទ្ធភាព។

### ២.៥.៦ ស្តង់ដាទី៦៖ ការផ្សារភ្ជាប់សាលារៀន និងសហគមន៍

សហគមន៍មានតួនាទីដ៏សំខាន់ក្នុងដំណើរការអភិវឌ្ឍសាលារៀន។ ទំនាក់ទំនងល្អរវាងសាលារៀននិងសហគមន៍ ជាកត្តាចាំបាច់មិនអាចខ្វះបាន។ ប្រការនេះជាកម្លាំងចលករ និងជាប្រភពមិនចេះរីងស្ងួត ក្នុងការលើកកម្ពស់គុណភាពបង្រៀន រៀន និងលទ្ធផលសិក្សារបស់សិស្ស តាមរយៈការចូលរួមរៀបចំផែនការស្វែងរកធនធាន និងការពិនិត្យតាមដានវឌ្ឍនភាព ក្នុងដំណើរការអភិវឌ្ឍវិស័យអប់រំ ឱ្យមានជីវិតស្រស់បំព្រងប្រកបដោយសុខដុមនីយកម្ម។ សូនាករសំខាន់ៗរួមមានៈ

៦.១ អាជ្ញាធរដែនដី

- បង្កើតទំនាក់ទំនងជិតស្និទ្ធ និងយូរអង្វែងជាមួយសហគមន៍ អាជ្ញាធរ មាតាបិតាសិស្ស និងអ្នកពាក់ព័ន្ធនានា ដើម្បីអភិវឌ្ឍន៍សាលារៀន
- ដឹកនាំ និងសម្របសម្រួល ការកៀរគរធនធានពីប្រភពផ្សេងៗ ដើម្បីអភិវឌ្ឍសាលារៀន
- ពង្រឹងការគ្រប់គ្រង និងដឹកនាំ ដោយបង្ហាញឱ្យឃើញច្បាស់អំពីផែនការ ការទទួលខុសត្រូវខ្ពស់តម្លាភាព និងមិនប្រកាន់បក្សពួក
- កសាងទំនុកចិត្ត ដោយខិតខំបង្កើនសមិទ្ធផល លទ្ធផលសិក្សាល្អ គោរពឆន្ទៈរួម មានការលះបង់មានចក្ខុវិស័យ បេសកកម្ម រចនាសម្ព័ន្ធច្បាស់លាស់។

៦.២ មាតាបិតា

- បង្កើតទំនាក់ទំនងល្អ ជាមួយមាតាបិតាសិស្ស ក្នុងការប្រមូលកុមារចូលរៀន និងលទ្ធផលសិក្សា
- ពន្យល់ពីតម្លៃនៃការអប់រំដល់មាតាបិតាសិស្ស
- ផ្សព្វផ្សាយរាល់សមិទ្ធផលការងាររបស់សាលា ដែលសហគមន៍បានចូលរួមអភិវឌ្ឍ។

៦.៣ ភាគីពាក់ព័ន្ធ

- កសាងបណ្ដាញទំនាក់ទំនងជាមួយអ្នកឯកទេស និងអ្នកជំនាញលើគ្រប់វិស័យ ដើម្បីចូលរួមអភិវឌ្ឍការអប់រំ ក្នុងនោះមានវិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ វិស័យសុខាភិបាល វិស័យឧស្សាហកម្ម សិប្បកម្ម សុវត្ថិភាពចរាចរណ៍ វិស័យវប្បធម៌ ទេសចរណ៍ ព័ត៌មាន សាសនា...
- បង្កលក្ខណៈងាយស្រួលដល់អ្នកពាក់ព័ន្ធចូលរួម ដោយផ្ដល់ការគាំទ្រ ការផ្ដល់កិត្តិយស និងការផ្ដល់ឱកាសចូលរួមក្នុងសកម្មភាពនានា
- ស្ដាប់ និងទទួលយកនូវគំនិត ឬយោបល់រិះគន់ ស្ថាបនាពីសហគមន៍ និងភាគីពាក់ព័ន្ធ (អ.យ.ក., ២០១៧)។

## ២.៦ ទម្រង់នៃកំណែទម្រង់សាលារៀន

នៅកម្រិតសាលារៀន ក្រសួងនឹងពង្រឹងការគ្រប់គ្រងតាមសាលារៀនឆ្ពោះទៅលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស និងផ្លាស់ប្ដូរវប្បធម៌សាលារៀន ដោយផ្ដោតលើ៖ ១) វាយតម្លៃសមត្ថភាពរបស់សិស្សតាមរយៈការធ្វើតេស្ដដោយតម្លាភាព គាំទ្រការរៀន និងបង្រៀន និងការរៀបចំថ្នាក់ជួយសិស្សរៀនយឺតផ្ដោតលើសិស្សមិនសូវចេះអាន សរសេរ និងគិតលេខ ២) ការបង្កើនគណនេយ្យភាពរបស់សាលារៀនកម្រិតជាប់ស្ដង់ដារបស់សាលារៀន ៣) ការបង្កើនស្វ័យភាព និងសិទ្ធិអំណាច ក្នុងការសម្រេចចិត្តនៅកម្រិតសាលារៀន តាមរយៈគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន រៀបចំផែនការកែលម្អសាលារៀន និងថ្នាក់រៀន រៀបចំកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំគ្រូបង្រៀន និងគណៈគ្រប់គ្រង ប្រជុំពិនិត្យតាមដានប្រចាំខែ ត្រីមាស ៤) ការបង្កើនការចូលរួមរបស់មាតាបិតា និងភាគីពាក់ព័ន្ធនៅក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍សាលារៀនឱ្យសម្រេចបានជាសាលារៀនគំរូ។

បន្ទាប់ពីបានអនុវត្តសាកល្បងកម្មវិធីកំណែទម្រង់សាលារៀន និងបទពិសោធន៍ពីការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ក្រសួងនឹងបង្កើតគំរូកំណែទម្រង់សាលារៀនចំនួន៣ប្រភេទគឺ៖ សាលារៀនជំនាន់ថ្មី សាលារៀនគំរូ និងសាលារៀនធម្មតា។

### ២.៦.១ សាលារៀនជំនាន់ថ្មី

សាលារៀនជំនាន់ថ្មី ផ្តោតលើការផ្តល់ស្វ័យភាពក្នុងការអនុវត្តកម្មវិធីសិក្សាដើម្បីបណ្តុះធនធានមនុស្សមានបំណិនសតវត្សទី២១ ក្នុងនោះគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនមានៈ ក) សីលធម៌ និងស្តង់ដាវិជ្ជាជីវៈខ្ពស់ ខ) គណនេយ្យភាពនិងនវានុវត្តន៍ គ) ចេះប្រើបច្ចេកវិទ្យាព័ត៌មានក្នុងការរៀនសូត្រ និងបង្រៀន ឃ) ចេះប្រើប្រាស់វិធីសាស្ត្របង្រៀនថ្មី។ សិស្សសាលារៀនជំនាន់ថ្មីមានៈ ក) ការផ្តួចផ្តើមគំនិត និងសហគ្រិនភាព ខ) ចេះទំនាក់ទំនង និងសរសេរយ៉ាងប៉ិនប្រសប់ គ) ចេះវិភាគវាយតម្លៃព័ត៌មាន ឃ) ចង់ឃើញ ចង់ដឹង និងមានការស្រមើលស្រមៃ ច) ចេះគិតបែបវិភាគស៊ីជម្រៅ និងការដោះស្រាយបញ្ហា ឆ) ចេះសហការ ជ) មានភាពរហ័សរហួន និងចេះយកចំណេះដឹងទៅអនុវត្ត។

- ក្រសួងនឹងជ្រើសរើសគ្រឹះស្ថានសិក្សាផ្តោតលើមូលដ្ឋានឱដីថល តាមរយៈបង្កើនចំនួនសាលាជំនាន់ថ្មីពី៧ដល់១០សាលារៀន ដោយផ្តោតទៅលើសាលារៀនគំរូ និងសាលាធម្មតា ដែលមានសក្តានុពល តាមលទ្ធភាពថវិកា និងជ្រើសរើសសិស្សពូកែៗ ឱ្យចូលរៀនលើមុខវិជ្ជាមូលដ្ឋានគ្រឹះឱដីថល។ ចំពោះសិស្សថ្នាក់ទី១០ ក្រសួងនឹងសម្រិតសម្រាំង និងតម្រង់ទិសដល់ ១) ក្រុមសិស្សឆ្នើម សម្រាប់សិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ និបច្ចេកវិទ្យា (STEAM) ២) ក្រុមសិស្សសិក្សាកម្មវិធីធម្មតា ៣) ក្រុមសិស្សសិក្សាតាមកម្មវិធីអប់រំបច្ចេកទេស។
- ក្រសួងនឹងវិនិយោគលើការបំពាក់បន្ទប់ពិសោធន៍ និងបច្ចេកវិទ្យា តាមរយៈការពង្រឹងដំណើរការសាលាមធ្យមសិក្សាធនធាន និងបំពាក់បន្ទប់ពិសោធន៍ សម្ភារឧបទេស និងបំប៉នវិធីសាស្ត្របង្រៀន និងការបណ្តុះបណ្តាលគ្រូសម្រាប់ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។
- ក្រសួងនឹងបង្កើតសាលាបឋមសិក្សាដែលដំណើរការរៀន និងបង្រៀនពេញមួយថ្ងៃ ដោយប្រើប្រាស់មូលនិធិសមធម៌ (ការចូលរួមជាថវិកាបដិភាគរបស់មាតាបិតា) សម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធីសិក្សាទំនើប ដែលរួមមានកុំព្យូទ័រ រ៉ូបូទិក/ឡេហ្គោ ភាសាអង់គ្លេស ភាសាចិន ការអប់រំសិល្បៈ និងការអប់រំកាយ និងកីឡាជាដើម នៅតាមតំបន់ទីក្រុង និងទីប្រជុំជនដែលមានសក្តានុពល។ បន្ទប់រៀននឹងត្រូវជួសជុល និងកែ

លម្អ ដោយបំពាក់ LCD Projector ឬ Smartboard ម៉ាស៊ីនត្រជាក់ តបណ្តាញអគ្គិសនី និង អ៊ិនធើណិត។ បរិស្ថាន អនាម័យ ទីលានកីឡា ការរៀបចំសួនច្បារ ការដាំដើមឈើជាដើម សុទ្ធតែជាផ្នែកមួយនៃការអភិវឌ្ឍ ក្នុងការអនុវត្តកម្មវិធីសិក្សាទំនើប។ ជាមួយគ្នានេះ ការលើកកម្ពស់សុខភាពសិក្សា អនាម័យ និងអាហារូបត្ថម្ភ ក៏ត្រូវបានយកចិត្តទុកដាក់ផងដែរ។

### ២.៦.២ សាលារៀនគំរូ

សាលារៀនគំរូ ផ្តោតលើ ក) សាលារៀនមានគណនេយ្យភាពជាមួយសហគមន៍ និងសម្រេចបានស្តង់ដាសាលារៀនមានប្រសិទ្ធភាព ខ)សាលារៀនមានស្វ័យភាព ក្នុងការងារផែនការកែលម្អសាលារៀន ថ្នាក់រៀន និងផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គណៈគ្រប់គ្រង និងគ្រូបង្រៀន ការជួយសិស្សរៀនយឺត និងផ្តល់ព័ត៌មានដល់មាតាបិតា ឬអ្នកអាណាព្យាបាល និងសហគមន៍ ឃ) គ្រូបង្រៀនប្រើប្រាស់លទ្ធផលតេស្ត ដើម្បីកែលម្អការបង្រៀន និងទទួលបានការអភិវឌ្ឍគុណវុឌ្ឍិជាប្រចាំ ង)មាតាបិតា ឬអ្នកអាណាព្យាបាល និងសហគមន៍ចូលរួមគាំទ្រ និងអភិវឌ្ឍសាលារៀន។

សាលារៀនគំរូ គឺជាសាលារៀន ដែលសម្រេចបាននូវស្តង់ដាទាំង ៥ គឺ៖

#### ២.៦.២.១ ស្តង់ដាទី១ សាលារៀនដំណើរការសម្រេចផលសម្រេចការអប់រំ និងការសិក្សារៀនសូត្ររបស់សិស្ស

ស្តង់ដាសាលារៀន ដែលក្នុងនោះមានទាំងស្តង់ដានាយក ក៏ដូចជាមានទាំងការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន ដែលមានការចូលរួមពីសហគមន៍មូលដ្ឋាន និងពីមាតាបិតា ដើម្បីសម្រេចនូវគណនេយ្យភាព ចំពោះមាតាបិតា ចំពោះក្រសួងអប់រំ យុវជន និងកីឡា និងចំពោះអាជ្ញាធរមូលដ្ឋាន។ ដូចនេះ ស្តង់ដាសាលារៀនគឺ សាលារៀនមានដំណើរការ និងជាទីកន្លែងមួយសម្រាប់លើកកម្ពស់ការសិក្សារៀនសូត្រ ដែលគោលដៅរបស់យើង គឺលទ្ធផលសិក្សារៀនសូត្ររបស់សិស្ស។

### ២.៦.២.២ ស្តង់ដាទី២ សាលារៀនដំណើរការសម្រាប់ការបង្រៀន និងការសិក្សារៀនសូត្ររបស់សិស្សម្នាក់ៗ

ការគ្រប់គ្រងថ្នាក់រៀនដោយមានការចូលរួមពីមាតាបិតាដើម្បីជួយគាំទ្រ។ ឧទាហរណ៍៖ ករណីថ្នាក់រៀនអត់មានអគ្គិសនី ឬអាកាសធាតុក្តៅ ឪពុកម្តាយគួរតែពិនិត្យមើលលទ្ធភាពចូលរួមនៅក្នុងការទិញអំពូល ត ខ្សែភ្លើង កង្ហារ ដើម្បីឱ្យកូនបានរៀនក្នុងបរិស្ថាន ដែលចូលចិត្ត។ បរិស្ថានសាលារៀន គឺសំខាន់ណាស់សម្រាប់ក្មេង ប្រសិនបើចង់កែលម្អ។ ជាពិសេស កម្រិតបឋមសិក្សា ត្រូវចាប់ផ្តើមពីវិធីឱ្យក្មេងស្រឡាញ់សាលារៀន មានឯកសណ្ឋានល្អ ចង់មកសាលារៀន ចេះច្រៀងចម្រៀង និងហាត់កីឡា។ល។ ដូច្នេះ ការរៀបចំបរិស្ថានសិក្សាឱ្យបានល្អ ដើម្បីឱ្យក្មេងចង់មកសាលារៀន។

ថ្នាក់រៀនមានដំណើរការ តម្រូវឱ្យគ្រូបង្រៀនរៀបចំផែនការបង្រៀន៣ឆ្នាំ ផែនការប្រចាំឆ្នាំ តាមមុខវិជ្ជា , ចំនួនថ្នាក់រៀនមានការប្រជុំពិនិត្យតាមដានប្រចាំខែទៀងទាត់លើការរៀនសូត្រ, ចំនួននិងភាគរយសិស្សមានផែនការរៀនសូត្រប្រចាំឆ្នាំនិងបានអនុវត្តការតាមដានផែនការនេះប្រចាំឆ្នាំសិក្សា, ចំនួននិងភាគរយសិស្សរៀនសូត្របំណិតរកចំណូលផ្នែកកសិកម្មនិងបច្ចេកទេស, ចំនួនដងនៃការប្រកួតប្រជែងអំណាន និងគណិតវិទ្យាប្រចាំឆ្នាំសិក្សា, ចំនួននិងភាគរយសិស្សអវត្តមានលើស៤ដងក្នុងមួយឆ្នាំសិក្សា និងចំនួនដងគ្រូអវត្តមានមិនមានគ្រូជំនួសប្រចាំឆ្នាំសិក្សា។ល។

### ២.៦.២.៣ ស្តង់ដាទី៣ គឺការចូលរួមរបស់សហគមន៍និងមាតាបិតា នៅក្នុងការគ្រប់គ្រង និងដំណើរការសាលារៀន

ប្រសិនបើមាតាបិតាមិនជួយគាំទ្រនោះទេ សាលារៀនក៏មិនជោគជ័យដែរ។ កំណែទម្រង់សាលារៀនកន្លងមកបានបង្ហាញថា សាលារៀនជោគជ័យ គឺដោយសារមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន សហគមន៍ មាតាបិតា នៅក្នុងការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន ព្រមទាំងចូលរួមក្នុងការរៀបចំផែនការ ការកែ

លម្អសាលារៀន។ ឧទាហរណ៍៖ តើសាលារៀនមានបញ្ហាអ្វីខ្លះ ត្រូវដោះស្រាយបែបណា? ខ្វះអ្វីខ្លះ? ដែលចំណុចទាំងនេះគឺជាចំណុចគន្លឹះដើម្បីគាំទ្រគ្នាទៅវិញទៅមក។

ការចូលរួមរបស់សហគមន៍ និងមាតាបិតានៅក្នុងការគ្រប់គ្រង និងដំណើរការសាលារៀន តាមរយៈការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន និងមានរបបប្រជុំទៀងទាត់។ នាយក និងនាយករងទទួលការសម្រេចចិត្តពី គ.គ.ស. ឬ ក.ប.ស លើការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ។ មាតាបិតាជួយជំរុញការសិក្សា និងទប់ស្កាត់ការបោះបង់ការសិក្សា និងមករៀនវិញទៀងទាត់។ បរិមាណចំណូលមូលនិធិគាំទ្រពីសហគមន៍ដល់សាលារៀនប្រចាំឆ្នាំ។

**២.៦.២.៤ ស្តង់ដាទី៤ គឺដំណើរការប្រតិបត្តិការ និងរដ្ឋបាលសាលារៀន**

សាលារៀនមានដំណើរការល្អ អាស្រ័យលើការរៀបចំផែនការសកម្មភាពអនុវត្តច្បាស់លាស់ រយៈពេលមធ្យម និងប្រចាំឆ្នាំ ព្រមទាំងផ្តោតលើផលសម្រេចនៃការអប់រំ និងឈរលើមូលដ្ឋាននៃការធ្វើតេស្តស្តង់ដាប្រចាំខែ និងប្រចាំឆ្នាំ។ លទ្ធផលតេស្តស្តង់ដាប្រចាំខែត្រូវបានយកប្រើប្រាស់ ដើម្បីជួយដល់ការសិក្សារៀនសូត្ររបស់សិស្សរៀនយឺត។ សាលារៀនត្រូវធ្វើអធិការកិច្ចផ្ទៃក្នុង និងការប្រជុំបច្ចេកទេសជាទៀងទាត់តាមផែនការ។ គ្រូបង្រៀន និងនាយកសាលាត្រូវបានបញ្ជូនឱ្យរៀនវគ្គអភិវឌ្ឍសមត្ថភាពជាប្រចាំ។

មានន័យថារដ្ឋបាលសាលារៀន ត្រូវយកចិត្តទុកដាក់លើការគ្រប់គ្រងគ្រូ តើមានបញ្ហាអ្វី? ដូចជាខ្វះគ្រូលើសគ្រូ គ្រូបង្រៀនអត់ទៅតាមមុខវិជ្ជា ការរៀបចំផែនការដំណើរការសាលារៀន ការផ្តល់សម្ភារឧបទេស រួមទាំងវិធីសាស្ត្របង្រៀន។ ម្យ៉ាងទៀត គោលដៅរបស់យើងបំណងគឺចង់បណ្តុះបំណិនសតវត្សទី២១ ចង់ឱ្យសិស្សមាន វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទាគឺចាប់ផ្តើមពីការផ្តោតទៅលើវិធីសាស្ត្របង្រៀនទំនើប។ សាលារៀនត្រូវខិតខំរកវិធីសាស្ត្របង្រៀនថ្មីៗ និងអភិវឌ្ឍសមត្ថភាពគ្រូលើផ្នែកឌីជីថល ជាដើម។

**២.៦.២.៥ ស្តង់ដាទី៥ គឺគណនេយ្យភាព**

សាលារៀនត្រូវកំណត់គោលដៅ និងត្រូវតែមានសូចនាករវាស់វែង ប្រសិនបើមិនសម្រេចបានតាមសូចនាករ តើសាលារៀនត្រូវធ្វើយ៉ាងណា។ សាលារៀនត្រូវមានរបាយការណ៍ជាទៀងទាត់ និងផ្សព្វផ្សាយជាសាធារណៈ។ គ្រូបង្រៀនត្រូវគោរពតាមក្រមសីលធម៌វិជ្ជាជីវៈ ដូចជាការបង្រៀនគ្រប់ម៉ោងតាមកម្មវិធីសិក្សាកំណត់។ អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវចុះពិនិត្យសាលារៀន ជួយគាំទ្រ និងផ្តល់ការហ្វឹកហាត់។

ការអនុវត្តកម្មវិធីសិក្សាគឺសំខាន់ណាស់ យ៉ាងហោចណាស់ឱ្យបាន៦ម៉ោងក្នុង១ថ្ងៃ ឬក្នុង១ថ្ងៃ៤ម៉ោងឱ្យពេលម៉ោង ជាពិសេសកាត់បន្ថយអវត្តមានរបស់គ្រូ និងអវត្តមានរបស់សិស្ស។ ប្រព័ន្ធព័ត៌មានសាលារៀនដែលមានភាពច្បាស់លាស់ និងសាលារៀនត្រូវមានSchool Profile ដើម្បីអាចពិនិត្យមើលអំពីបញ្ហាតាមសាលារៀន។

ចំណុចបន្ទាប់ទៀត គឺការធ្វើតេស្តស្តង់ដាដែលមានតម្លាភាព ដើម្បីលើកទឹកចិត្តឱ្យគ្រូខំបង្រៀនឱ្យសិស្សរៀនពិតប្រាកដ។ ការរៀបចំធ្វើតេស្តនេះគឺ ដើម្បីឆ្លើយតបទៅនឹងរង្វាយតម្លៃលទ្ធផលសិក្សាសិស្ស នៅថ្នាក់ទី៣ ទី៦ ទី៨ និងទី១១ និងប្រព័ន្ធរង្វាយតម្លៃអន្តរជាតិ។ មួយទៀតដើម្បីប្រៀបធៀបចំណេះដឹងសិស្សយើងជាមួយអន្តរជាតិ ហើយសាលារៀនដែលទទួលបានក្លាយជាសាលារៀនគំរូ ទាល់តែសិស្សយ៉ាងហោចណាស់រៀនបានពិន្ទុ A B C ជាដើម (អ.យ.ក., ២០២៣)។

# ជំពូក៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូក៣

# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ គម្រោងវិភាគ

ដើម្បីធ្វើការស្រាវជ្រាវទៅលើប្រធានបទខាងលើ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសភាគសំណាក ដោយប្រើវិធីសាស្ត្របរិមាណវិស័យ និងគុណវិស័យ ដើម្បីប្រមូលព័ត៌មានទាក់ទងនឹងប្រធានបទនេះ ដោយមានអ្នកចូលរួមបំពេញកម្រងសំណួរចំនួន៤៤រូប ក្នុងនោះគណៈគ្រប់គ្រងសាលារៀន៦រូប លោកគ្រូ/អ្នកគ្រូ៣២រូប និងគណៈកម្មការគ្រប់គ្រងសាលារៀន៦រូប ពីសាលាមត្តេយ្យសិក្សាធនធានទាំង៦ ក្នុងខេត្តស្វាយរៀង។ បរិមាណវិស័យ ប្រើប្រាស់កម្រងសំណួរទម្រង់បិទ បែបពហុជ្រើសរើស។ ចំពោះគុណវិស័យ ប្រើប្រាស់សំណួរបន្ថែមខាងក្រោមកម្រងសំណួរបិទដែលមានលក្ខណៈជាទម្រង់បើក ផ្តោតលើបញ្ហាប្រឈម និងដំណោះស្រាយនានា ក្នុងការអនុវត្តរបស់សាលារៀន។ កម្រងសំណួរត្រូវបានបង្កើតឡើងជាឧបករណ៍វាយតម្លៃការអនុវត្តស្តង់ដាសាលារៀនគំរូ សម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលមាន៥ស្តង់ដា ស្មើនឹង៦៨សូចនាករ។ មូលហេតុនៃការជ្រើសរើស និងប្រើប្រាស់វិធីសាស្ត្របរិមាណវិស័យ ដើម្បីរកឱ្យឃើញនូវលទ្ធផលជាក់លាក់អាចជាភាគរយនៃក្រុមនីមួយៗ ធៀបនឹងចំនួនកំណត់ជាក់លាក់មួយ (Gray, 2009)។ វិធីសាស្ត្រនេះត្រូវមានសូចនាករជាក់លាក់ និងស្តង់ដាជាក់លាក់ ដោយគោរពនូវដំណើរការជាក់លាក់ក្នុងការប្រមូលទិន្នន័យផងដែរ (Bamberger, 2012)។ បើយោងតាម (Marriam, 1998) ការសិក្សាស្រាវជ្រាវតាមបែបបរិមាណវិស័យ អ្នកសិក្សាតែងចាប់អារម្មណ៍ និងមានការយល់ដឹង និងចេះវិភាគទិន្នន័យ។ ការសិក្សាស្រាវជ្រាវបែបគុណវិស័យធ្វើឡើងក្នុងគោលបំណង យល់ដឹងពីស្ថានភាពមួយដោយផ្តោតការយកចិត្តទុកដាក់លើទិដ្ឋភាពរួមទាំងមូលព្រមទាំងមានលក្ខណៈស៊ីជម្រៅលើការយល់ដឹងជាងការវិភាគលើចំនួន និងស្ថិតិនៃទិន្នន័យទាំងនោះ (Bamberger, 2012 & Ary et Berg, 2009) ។

## ៣.២ ការប្រមូលទិន្នន័យ

យោងតាមលិខិតឧទ្ទេសនាមលេខ៣៤៧២.អយក.ឧទន ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣ និងសេចក្ដីជម្រាបជូនលេខ ៤០៨២.អយក.វជអ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ព្រមទាំងលិខិតអនុញ្ញាតពីប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្វាយរៀង អ្នកសិក្សាស្រាវជ្រាវបានចុះប្រមូលព័ត៌មាននៅតាមសាលាមត្តេយ្យសិក្សាធនធានទាំង៦ ក្នុងខេត្តស្វាយរៀង។ នៅក្នុងដំណើរចុះប្រមូលទិន្នន័យអ្នកសិក្សាស្រាវជ្រាវបានរៀបចំផែនការដោយធ្វើទំនាក់ទំនងទៅតាមការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋ បាលក្រុង/ស្រុកទាំង៦ ដែលមានសាលាមត្តេយ្យសិក្សាធនធាន និងបានទំនាក់ទំនងទៅសាលាគោលដៅ ដើម្បីពិភាក្សាជាមួយគណៈនាយក/នាយិកា ក្នុងគោលបំណងសុំការសហការបំពេញកម្រងសំណួរដែលបានត្រៀមទុក។ ចាប់ពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ អ្នកសិក្សាស្រាវជ្រាវបានចុះទៅតាមសាលារៀនគោលដៅទៅតាមកាលបរិច្ឆេទ ដែលលោកនាយក/នាយិកាបាន អនុញ្ញាត។ លោកនាយក/នាយិកា លោកគ្រូ/អ្នកគ្រូ និងគណៈកម្មការគ្រប់គ្រងសាលារៀន តាមសាលារៀននីមួយៗ យកចិត្តទុកដាក់ សហការ និងជួយសម្របសម្រួលនៅក្នុងដំណើរការចុះប្រមូលទិន្នន័យរបស់អ្នកសិក្សាស្រាវជ្រាវបានដោយរលូន។ អ្នកសិក្សាស្រាវជ្រាវក៏បានពន្យល់យ៉ាងច្បាស់លាស់ ពីគោលបំណង និងរបៀបនៃការបំពេញកម្រងសំណួរ ព្រមទាំងបង្ហាញពីសារៈប្រយោជន៍ដែលទទួលបានពីការចូលរួមរបស់លោកនាយក/នាយិកា លោកគ្រូ/អ្នកគ្រូ និងគណៈកម្មការគ្រប់គ្រងសាលារៀនផងដែរ។

## ៣.៣ ឧបករណ៍ស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវ និងសម្រេចតាមគោលបំណងនៃការសិក្សាស្រាវជ្រាវ អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្រងសំណួរក្នុងការចុះប្រមូលទិន្នន័យពីគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន នៅសាលាមត្តេយ្យសិក្សាធនធាន ក្នុងខេត្តស្វាយរៀង។ ការរៀបចំកម្រងសំណួរផ្ដោតលើស្តង់ដាទាំង៥របស់សាលារៀនគម្រូសម្រាប់មត្តេយ្យសិក្សារដ្ឋ។ ស្តង់ដាទី១ ផលសម្រេចអប់រំ និងការសិក្សារបស់សិស្ស មាន១៦សូចនាករ ស្មើនឹង១៦សំណួរ។ ស្តង់ដាទី២ ថ្នាក់រៀនមាន

ដំណើរការសម្រាប់ការបង្រៀន និងរៀន មាន១០សូចនាករ ស្មើនឹង១០សំណួរ។ ស្តង់ដាទី៣ ភាពជាម្ចាស់នៃសហគមន៍សាលារៀន មាន១០សូចនាករ ស្មើនឹង១០សំណួរ។ ស្តង់ដាទី៤ រដ្ឋបាល និងដំណើរការសាលារៀន មាន២១សូចនាករ ស្មើនឹង២១សំណួរ ស្តង់ដាទី៥ គណនេយ្យភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មាន១១សូចនាករស្មើនឹង១១សំណួរ។ ជារួមកម្រងសំណួរដែលយកទៅប្រើប្រាស់ក្នុងការប្រមូលទិន្នន័យមាន៦៨សំណួរ ដែលតម្រូវឱ្យគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន ជ្រើសរើសកម្រិតលទ្ធផលសម្រេចបានមួយ ដែលសាលារៀនអនុវត្តបានជាក់ស្តែង ក្នុងចំណោមលទ្ធផលសម្រេចបានសរុប៤នៃសូចនាករ ឬសំណួរនីមួយៗ។ ផ្សារភ្ជាប់នឹងកម្រងសំណួរទាំង៦៨សំណួរ អ្នកសិក្សាស្រាវជ្រាវបានបន្ថែមសំណួរទម្រង់បើកចំនួន២សំណួរទៀត ដើម្បីទទួលបានព័ត៌មានពីបញ្ហាប្រឈម និងដំណោះស្រាយនានា ពីគណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ និងគណៈកម្មការគ្រប់គ្រងសាលារៀន។

## ៣.៤ ការជ្រើសរើសគំរូសំណាក

ដើម្បីឱ្យឆ្លើយតបទៅនឹងប្រធានបទក្នុងការស្រាវជ្រាវខាងលើ អ្នកសិក្សាស្រាវជ្រាវយកសាលាមត្តេយ្យសិក្សាធនធានទាំង៦ ក្នុងក្រុង/ស្រុកមកធ្វើជាសំណាកសម្រាប់ការសិក្សាស្រាវជ្រាវ ដែលនៅក្នុងនោះរួមមានគណៈគ្រប់គ្រងសរុប៦នាក់ គ្រូបង្រៀនសរុប៣២នាក់ និងគណៈកម្មការគ្រប់គ្រងសាលារៀន៦នាក់។ **ស្រុកកំពង់រោទិ៍៖** សាលាមត្តេយ្យសិក្សាធនធាន ហ៊ុន សែន កំពង់រោទិ៍ មាន៤ថ្នាក់ សិស្សសរុប១២៥នាក់ ស្រី៧០នាក់ គ្រូ៥នាក់ ស្រី៤នាក់។ **ស្រុកស្វាយជ្រំ៖** សាលាមត្តេយ្យសិក្សាធនធាន ស្វាយជ្រំ មាន៣ថ្នាក់ សិស្សសរុប៨២នាក់ ស្រី៥៣នាក់ គ្រូ៥នាក់ ស្រី៥នាក់។ **ស្រុករមាសហែក៖** សាលាមត្តេយ្យសិក្សាធនធានស្រុករមាសហែក មាន៤ថ្នាក់ សិស្សសរុប១៨៣នាក់ ស្រី៨៤នាក់ គ្រូ៦នាក់ ស្រី៦នាក់។ **ក្រុងបាវិត៖** សាលាមត្តេយ្យសិក្សាធនធានបាវិត មាន៧ថ្នាក់ សិស្សសរុប២៥២នាក់ ស្រី១១៩នាក់ គ្រូសរុប៩នាក់ ស្រី៩នាក់។ **ក្រុងស្វាយរៀង៖** សាលាមត្តេយ្យសិក្សាធនធានកុមារថ្មីមាន៩ថ្នាក់ សិស្សសរុប៣០១នាក់ ស្រី១៣២នាក់ គ្រូ១៦នាក់ ស្រី១៦នាក់។ **ស្រុករំដួល៖** សាលាមត្តេយ្យសិក្សាធនធាន កូវ សាមុតកំពង់ចក មាន៥ថ្នាក់ សិស្សសរុប១៥៧នាក់

ស្រី៧២នាក់ គ្រូ៧នាក់ ស្រី៦នាក់។អ្នកសិក្សាស្រាវជ្រាវជ្រើសរើសសំណាកនេះ ដើម្បីស្វែងរកព័ត៌មានឱ្យបានច្បាស់លាស់សម្រាប់វាយតម្លៃការដឹកនាំ និងគ្រប់គ្រង ក្នុងការចូលរួមអភិវឌ្ឍសាលារៀនដោយផ្តោតសំខាន់ស្តង់ដាទាំង៥ នៃសាលារៀនគំរូ សម្រាប់មត្តេយ្យសិក្សារដ្ឋ៖ **ស្តង់ដាទី១** ផលសម្រេចអប់រំ និងការសិក្សារបស់សិស្ស **ស្តង់ដាទី២** ថ្នាក់រៀនមានដំណើរការសម្រាប់ការបង្រៀន និងរៀន **ស្តង់ដាទី៣** ភាពជាម្ចាស់នៃសហគមន៍សាលារៀន **ស្តង់ដាទី៤** រដ្ឋបាល និងដំណើរការសាលារៀន **ស្តង់ដាទី៥** គណនេយ្យភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធ្វើការវាយតម្លៃបានត្រឹមត្រូវ និងចំគោលដៅបានល្អ។

តារាងទី១៖ ចំនួនសំណាក

| ល.រ | សាលាសំណាក | គណៈគ្រប់គ្រង | លោកគ្រូ អ្នកគ្រូ | គណៈកម្មការគ្រប់គ្រងសាលារៀន | សរុប |
|---|---|---|---|---|---|
| ក្រុងស្វាយរៀង | | | | | |
| ១ | មត្តេយ្យសិក្សាធនជាន កុមារថ្មី | ១ | ៩ | ១ | ១១ |
| ក្រុងបាវិត | | | | | |
| ២ | មត្តេយ្យសិក្សាធនជាន បាវិត | ១ | ៧ | ១ | ៩ |
| ស្រុកកំពង់រោទិ៍ | | | | | |
| ៣ | មត្តេយ្យសិក្សាធនជានហ៊ុនសែនកំពង់រោទិ៍ | ១ | ៤ | ១ | ៦ |
| ស្រុករមាសហែក | | | | | |
| ៤ | មត្តេយ្យសិក្សាធនជាន ស្រុករមាសហែក | ១ | ៤ | ១ | ៦ |
| ស្រុករំដួល | | | | | |
| ៥ | មត្តេយ្យសិក្សាធនជានកូវសាមុតកំពង់ចក | ១ | ៥ | ១ | ៧ |
| ស្រុកស្វាយជ្រំ | | | | | |

| | | | | | |
|---|---|---|---|---|---|
| ៦ | មត្តេយ្យសិក្សាធនជាន ស្វាយជ្រុំ | ១ | ៣ | ១ | ៥ |
| | សរុប | ៦ | ៣២ | ៦ | ៤៤ |

## ៣.៥ ការវិភាគទិន្នន័យ

ទិន្នន័យដែលបានមកពីការបំពេញកម្រងសំណួរ តាមរយៈការបំពេញដោយផ្ទាល់របស់គណៈនាយក លោកគ្រូ/អ្នកគ្រូ និងគណៈកម្មការគ្រប់គ្រងសាលាមត្តេយ្យសិក្សាធនជានទាំង៦ ត្រូវបានអ្នកសិក្សាស្រាវជ្រាវប្រើប្រាស់កម្មវិធី Microsoft Excel សម្រាប់វិភាគទិន្នន័យ បង្កើតជាក្រាហ្វ និងតារាងផងដែរ។ ចំពោះការវិភាគ អ្នកសិក្សាស្រាវជ្រាវវិភាគលើចំណុចសំខាន់ៗមួយចំនួនដូចជា៖ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រង និងបញ្ហាប្រឈមនៃការដឹកនាំ និងគ្រប់គ្រង នៅសាលាមត្តេយ្យសិក្សាធនជាន ព្រមទាំងដំណោះស្រាយនានា។ ការវិភាគនេះផ្អែកទៅលើសូចនាករដែលបានកំណត់ពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន។

រាល់ទិន្នន័យទាំងអស់ដែលបានធ្វើការវិភាគរួច នឹងត្រូវបានទាញចេញមកបង្ហាញទៅតាមគោលបំណងសំខាន់ៗទាំងពីរនៃការសិក្សាស្រាវជ្រាវ ដើម្បីងាយស្រួលក្នុងការបង្ហាញ និងធ្វើសេចក្តីសន្និដ្ឋានពីលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ។ បន្ទាប់ពីទទួលបានលទ្ធផលហើយយើងនឹងទាញសេចក្តីសន្និដ្ឋាន ព្រមទាំងធ្វើការផ្ទៀងផ្ទាត់ជាមួយចំណោទបញ្ហាដែលបានលើកឡើងជាសំណួរស្រាវជ្រាវ និងគោលបំណងនៃការស្រាវជ្រាវនេះ ហើយធ្វើការវាយតម្លៃទៅលើស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជានក្នុងខេត្តស្វាយរៀង។

# ជំពូក៤

# លទ្ធផល និងការពិភាក្សា

# ជំពូក៤

# លទ្ធផល និងការពិភាក្សា

ជំពូកទី៤នេះ នឹងបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យលើប្រធានបទស្តីពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ក្នុងខេត្តស្វាយរៀង។ លទ្ធផលនៃការវិភាគទិន្នន័យត្រូវបានយកមកបកស្រាយដូចខាងក្រោម៖

## ៤.១. ការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន

### ៤.១.១ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានទាំង៥ស្តង់ដា ក្នុងក្របខ័ណ្ឌទូទាំងខេត្ត

យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវ ដែលទទួលបានពីការបំពេញកម្រងសំណួរ និងចម្លើយនៃសំណួរសម្ភាសន៍ ពីភាគសំណាកទាំង៣ប្រភេទ លទ្ធផលបានបង្ហាញដូចក្រាហ្វទី១ខាងក្រោម៖

*ក្រាហ្វទី១៖ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ក្នុងក្របខ័ណ្ឌទូទាំងខេត្ត*



ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានក្នុងខេត្តស្វាយរៀង ក្នុងចំណោមភាគសំណាកចូលរួម ទាំងគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន គឺលទ្ធផលស្ថិតនៅក្រោមស្តង់ដា (តម្លៃមធ្យម Mean=២.៣២, SD=0.0៨)។ ដោយឡែក បើពិនិត្យលម្អិតទៅលើស្តង់ដានីមួយៗឃើញថា ក្នុងចំណោមភាគសំណាកចូលរួមទាំងអស់ ស្តង់ដាទាំង៥គឺសុទ្ធតែស្ថិតនៅក្រោមកម្រិតស្តង់ដាសាលារៀនគំរូ សម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ក្នុងនោះស្តង់ដាទី១ ទទួលបានលទ្ធផលតម្លៃមធ្យមត្រឹមតែ Mean=១.៧៩, SD=0.0៥ ស្តង់ដាទី២ លទ្ធផលតម្លៃមធ្យម Mean=២.៦១, SD=0.២២ ស្តង់ដាទី៣ លទ្ធផលតម្លៃមធ្យម Mean=១.៩៣, SD=0.0៦ ស្តង់ដាទី៤ លទ្ធផលតម្លៃមធ្យម Mean=២.៧៨, SD=0.0៥ និង ស្តង់ដាទី៥ លទ្ធផលតម្លៃមធ្យម Mean=២.៤៩, SD=0.0៧។

### ៤.១.១.១ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី១

*ក្រាហ្វទី២៖ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី១*



ផ្អែកតាមក្រាហ្វទី២ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន លើស្តង់ដាទី១ (ផលសម្រេចអប់រំ និងការសិក្សារបស់សិស្ស) ក្នុងចំណោមភាគសំណាកដែលចូលរួមទាំងអស់ (គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន) បង្ហាញថា លទ្ធផលតម្លៃមធ្យម Mean=១.៧៩, SD=០.០៥ គឺស្ថិតនៅក្រោមស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ។ ដោយឡែក បើពិនិត្យមើលលម្អិតទៅលើសូចនាករនីមួយៗដែលស្ថិតនៅក្នុងស្តង់ដាទី១នេះ ឃើញថា មានតែសូចនាករ១ប៉ុណ្ណោះដែលស្របនឹងកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា គឺសូចនាករទី១៣ (ចំនួនកុមារមត្តេយ្យសិក្សាមានអាហាររូបត្ថម្ភត្រឹមត្រូវ) ដោយទទួលបានតម្លៃមធ្យម Mean=៣.៤៥, SD=០.០៩។ ក្រៅពីនោះគឺស្ថិតក្រោមកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋទាំងអស់ រួមមានសូចនាករទី១ ទទួលបានលទ្ធផលត្រឹមតែតម្លៃមធ្យម Mean=១.៣៦, SD= ០.១៧ សូចនាករទី២ លទ្ធផលតម្លៃមធ្យម Mean=២.១៩, SD=០.៤៣ សូចនាករទី៣ លទ្ធផលតម្លៃមធ្យម Mean=១.៨៥, SD=០.៣៨ សូចនាករទី៤ លទ្ធផលតម្លៃមធ្យម Mean=១.០៦, SD=០.១០ សូចនាករទី៥ លទ្ធផលតម្លៃមធ្យម Mean=១.៦៥, SD=០.៤៩ សូចនាករទី៦ លទ្ធផលម្លៃតមធ្យម Mean=១.០៦, SD= ០.១១ សូចនាករទី៧ លទ្ធផលតម្លៃមធ្យម Mean=១.៣៦, SD=០.១៧ សូចនាករទី៨ លទ្ធផលតម្លៃមធ្យម Mean=២.០៩, SD=០.៣៥ សូចនាករទី៩ លទ្ធផលតម្លៃមធ្យម Mean=១.៥១, SD=០.១៥ សូចនាករទី១០ លទ្ធផលតម្លៃមធ្យម Mean=១.៨២, SD=០.២៨ សូចនាករទី១១ លទ្ធផលតម្លៃមធ្យម Mean=១.៩៧, SD= ០.៣៤ សូចនាករទី១២ លទ្ធផលតម្លៃមធ្យម Mean=១.៤៣, SD=០.២៤ សូចនាករទី១៤ លទ្ធផលតម្លៃមធ្យម Mean=១.៩៩, SD=០.២៣ សូចនាករទី១៥ លទ្ធផលតម្លៃមធ្យម Mean=២.១៩, SD=០.១៧ និងសូចនាករទី១៦ លទ្ធផលតម្លៃមធ្យម Mean=១.៥៨, SD=០.២៣។

## ៤.១.១.២ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី២

*ក្រាហ្វទី៣៖ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី២*



យោងតាមក្រាហ្វទី៣ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន លើស្តង់ដាទី២ (ថ្នាក់រៀនមានដំណើរការសម្រាប់ការបង្រៀន និងរៀន) ក្នុងចំណោមភាគសំណាកចូលរួម ទាំងគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន បង្ហាញថាលទ្ធផលស្ថិតក្រោមស្តង់ដា ដោយតម្លៃមធ្យម Mean=២.៦១, SD=0.២២។ ដោយឡែក បើពិនិត្យលម្អិតទៅលើសូចនាករនីមួយៗក្នុងស្តង់ដាទី២នេះឃើញថា ក្នុងចំណោមភាគសំណាកចូលរួមទាំងអស់ មានសូចនាករតែ៣ប៉ុណ្ណោះដែលស្រប នឹងកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ក្នុងនោះគឺសូចនាករទី១ (ចំនួនថ្នាក់ធ្វើតេស្តសិស្សត្រឹមាសទៀងទាត់) មានតម្លៃមធ្យម Mean=៣.៥៧, SD=0.៣១ សូចនាករទី៥ (ចំនួនម៉ោងបង្រៀនជាក់ស្តែងមួយឆ្នាំសិក្សា) មានតម្លៃមធ្យម Mean=៣.៥៧, SD=0.0៩ និងសូចនាករទី៩ (ចំនួនគ្រូបង្រៀនបានទទួលការសង្កេតថ្នាក់រៀនពីនាយកសាលាចំនួន៣ដងក្នុងមួយឆ្នាំ) មានតម្លៃមធ្យម Mean=៣.២៨, SD=0.១៩។ ផ្ទុយទៅវិញ សូចនាករចំនួន៧ ស្ថិតក្រោមកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ក្នុងនោះសូចនាករទី២ លទ្ធផលតម្លៃមធ្យមMean=១.0៨, SD=0.១៣ សូចនាករទី៣ លទ្ធផលតម្លៃមធ្យម Mean=២.៥៥, SD=0.0៥ សូចនាករទី៤ លទ្ធផលតម្លៃមធ្យម Mean=២.៥0, SD=0.៦៧ សូចនាករទី៦ លទ្ធផលតម្លៃមធ្យម Mean=២.៩៣, SD=0.១៧ សូចនាករទី៧ លទ្ធផលតម្លៃមធ្យម Mean=១.៦៥, SD=0.១៨ សូចនាករទី៨ លទ្ធផលតម្លៃមធ្យម Mean=២.៥៣, SD=0.៦៧ និងសូចនាករទី១០ លទ្ធផលតម្លៃមធ្យម Mean=២.៤៦, SD=0.៤៦។

### ៤.១.១.៣ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៣

*ក្រាហ្វទី៤៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៣*




ក្រាហ្វទី៤ បង្ហាញពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាជនជាន លើស្តង់ដាទី៣ (ភាពជាម្ចាស់នៃសហគមន៍សាលារៀន)។ ក្នុងចំណោមភាគសំណាកចូលរួមទាំងអស់ (គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន) លទ្ធផលបង្ហាញថាស្ថិតនៅក្រោមស្តង់ដា

ដោយតម្លៃមធ្យម Mean=១.៩៣, SD=0.0៦។ បើពិនិត្យលម្អិតទៅលើសូចនាករនីមួយៗឃើញថា ក្នុងចំណោមភាគីសំណាកចូលរួមទាំងអស់ មានតែសូចនាករ១ប៉ុណ្ណោះដែលស្របនឹងកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា នោះគឺសូចនាករទី៥ (ចំនួនកុមារឈឺបានទទួលការព្យាបាល) ដោយតម្លៃមធ្យម Mean=៣.៤៩, SD=0.១៩។ រីឯ សូចនាករ៩ផ្សេងទៀត ស្ថិតនៅក្រោមកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ក្នុងនោះសូចនាករទី១ ទទួលបានលទ្ធផលតម្លៃមធ្យម Mean=១.៨១, SD=0.៤១ សូចនាករទី២ លទ្ធផលតម្លៃមធ្យម Mean=១.0៥, SD=0.0៩ សូចនាករទី៣ លទ្ធផលតម្លៃមធ្យម Mean=២.៣៨, SD=0.១៣ សូចនាករទី៤ លទ្ធផលតម្លៃមធ្យម Mean=២.២0, SD=0.១២ សូចនាករទី៦ លទ្ធផលតម្លៃមធ្យម Mean=១.៧៦, SD=0.0៨ សូចនាករទី៧ លទ្ធផលតម្លៃមធ្យម Mean=១.0៧, SD=0.0១ សូចនាករទី៨ លទ្ធផលតម្លៃមធ្យម Mean=១.៨៥, SD=0.0៣ សូចនាករទី៩ លទ្ធផលតម្លៃមធ្យម Mean=១.២៥, SD=0.0៨ និងសូចនាករទី១0 លទ្ធផលតម្លៃមធ្យម Mean=២.៤៦, SD=0.0៨។

### ៤.១.១.៤ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៤

*ក្រាហ្វទី៥៖ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៤*



ក្រាហ្វទី៥ បង្ហាញឱ្យឃើញថា ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានលើស្តង់ដាទី៤ (រដ្ឋបាល និងដំណើរការសាលារៀន)។ ក្នុងចំណោមភាគសំណាកចូលរួមទាំងគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន បង្ហាញថាលទ្ធផលស្ថិតក្រោមស្តង់ដា ដោយតម្លៃមធ្យម Mean=២.៧៨, SD=0.0៥។ ប៉ុន្តែ បើពិនិត្យលម្អិតទៅលើសូចនាករនីមួយៗឃើញថា មានសូចនាករចំនួន១១ ស្របនឹងកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។ ក្នុងនោះសូចនាករទី១ ទទួលបានលទ្ធផលតម្លៃមធ្យម Mean=៣.៥១, SD=0.0២ សូចនាករទី៣ លទ្ធផលតម្លៃមធ្យម Mean=៣.២៣, SD=0.២0 សូចនាករទី៤ លទ្ធផលតម្លៃមធ្យម Mean=៣.៦៣, SD=0.0៣ សូចនាករទី៥ លទ្ធផលតម្លៃមធ្យម Mean=៣.១៥, SD=0.១៧ សូចនាករទី៦ លទ្ធផលតម្លៃមធ្យម Mean=៣.00, SD=0.៣៤ សូចនាករទី១២ លទ្ធផលតម្លៃមធ្យម Mean=៣.00, SD=0.00 សូចនាករទី១៥ លទ្ធផលតម្លៃមធ្យម Mean=៣.៣៤, SD=0.0១ សូចនាករទី១៦ លទ្ធផលតម្លៃមធ្យម Mean=៣.៧៨, SD=0.0៨ សូចនាករទី១៨ លទ្ធផលតម្លៃមធ្យម Mean=៣.៧៥, SD=0.0៨ សូចនាករទី១៩ លទ្ធផលតម្លៃមធ្យម Mean=៣.៧៨, SD=0.១៩ និងសូចនាករទី២0 លទ្ធផលតម្លៃមធ្យម Mean=៣.២៨, SD=0.១0។ ដោយឡែក មានសូចនាករចំនួន១0 ដែលទទួលបានលទ្ធផលតម្លៃមធ្យមក្រោមស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ រួមមានសូចនាករទី២ ទទួលបានលទ្ធផលតម្លៃមធ្យមត្រឹមតែ Mean=២.៥៧, SD=0.១៥ សូចនាករទី៧ លទ្ធផលតម្លៃមធ្យម Mean=១.៣៣, SD=0.0៨ សូចនាករទី៨ លទ្ធផលតម្លៃមធ្យម Mean=១.៦៧, SD=0.១៤ សូចនាករទី៩ លទ្ធផលតម្លៃមធ្យម Mean=១.៤៣, SD=0.៣៨ សូចនាករទី១0 លទ្ធផលតម្លៃមធ្យម Mean=២.៧៣, SD=0.១៨ សូចនាករទី១១ លទ្ធផលតម្លៃមធ្យម Mean=១.៧៧, SD=0.៤២ សូចនាករទី១៣ លទ្ធផលតម្លៃមធ្យម Mean=១.៨៩, SD=0.0៩ សូចនាករទី១៤ លទ្ធផលតម្លៃមធ្យម Mean=២.៩៥, SD=0.១១ សូចនាករទី១៧ លទ្ធផលតម្លៃមធ្យម Mean=១.៨៥, SD=0.៥៣ និងសូចនាករទី២១ លទ្ធផលតម្លៃមធ្យម Mean=២.៧៣, SD=0.១៨។

### ៤.១.១.៥ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៥

*ក្រាហ្វទី៦៖ ស្ថានភាពនៃការដឹកនាំនិងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៥*



ក្រាហ្វទី៦ បង្ហាញពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានលើស្តង់ដាទី៥ (គណនេយ្យភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ)។ ក្នុងចំណោមភាគសំណាកចូលរួម ទាំងគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀនបង្ហាញថា លទ្ធផលស្ថិតក្រោមស្តង់ដាដោយតម្លៃមធ្យម Mean=២.៤៩, SD=0.0៧។ ដោយឡែក បើពិនិត្យលម្អិតទៅលើសូចនាករនីមួយៗឃើញថា មានតែសូចនាករចំនួន៣ ក្នុងចំណោមសូចនាករទាំង១១ ដែលមានតម្លៃមធ្យមស្របនឹងកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ក្នុងនោះសូចនាករទី៥ (ចំនួននាយក ឬនាយិកាមានការចាត់តាំងផ្លូវការ) តម្លៃមធ្យម Mean=៣.៩៧, SD=0.0៥ សូចនាករទី១0 (ចំនួនថ្នាក់រៀនខ្វះបង្កើនការចូលរៀន) តម្លៃមធ្យម Mean=៣.២៩, SD=0.១៨ និងសូចនាករទី១១ (ចំនួនថ្នាក់រៀនខ្វះបំពេញនិយាមសិស្សថ្នាក់រៀន) តម្លៃមធ្យម Mean=៣.២៨, SD=0.១៩ ។ ផ្ទុយទៅវិញ សូចនាករចំនួន៨ទៀត ស្ថិតក្រោមកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ក្នុងនោះសូចនាករទី១ ទទួលបានលទ្ធផលតម្លៃមធ្យមត្រឹម Mean=២.៦៤, SD=0.៣៤ សូចនាករទី២ លទ្ធផលតម្លៃមធ្យម Mean=១.៧៨, SD=0.៣៨ សូចនាករទី៣ លទ្ធផលតម្លៃមធ្យម Mean=២.៧២, SD=0.១៦ សូចនាករទី៤ លទ្ធផលតម្លៃមធ្យម Mean=២.0៣, SD=0.១៨ សូចនាករទី៦ លទ្ធផលតម្លៃមធ្យម Mean=១.៩៧, SD= 0.0៥ សូចនាករទី៧ លទ្ធផលតម្លៃមធ្យម Mean=២.00, SD=0.១៦ សូចនាករទី៨ លទ្ធផលតម្លៃមធ្យម Mean=២.៤១, SD=0.២១ និងសូចនាករទី៩ លទ្ធផលតម្លៃមធ្យម Mean=១.0៥, SD=0.0៩។

### ៤.១.២ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រង នៅសាលាមត្តេយ្យសិក្សាធនធានទាំង៥ស្តង់ដាផ្អែកលើគណៈគ្រប់គ្រងសាលារៀន

*ក្រាហ្វទី៧៖ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានទាំង៥ស្តង់ដា ផ្អែកលើគណៈគ្រប់គ្រងសាលារៀន*




ក្រាហ្វទី៧ បង្ហាញពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានទាំង៥ស្តង់ដា។ តាមប្រភពទិន្នន័យដែលទទួលបានពីគណៈគ្រប់គ្រងសាលារៀន លទ្ធផលបានបង្ហាញឱ្យឃើញថា ស្ថិតក្រោមស្តង់ដាសាលារៀនគំរូ សម្រាប់មត្តេយ្យសិក្សារដ្ឋ ដោយតម្លៃមធ្យម Mean=២.២៤, SD=0.៤១។ ដោយឡែក បើពិនិត្យលម្អិតទៅលើស្តង់ដានីមួយៗឃើញថា ស្តង់ដាទាំង៥ស្ថិតក្រោមកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ក្នុងនោះស្តង់ដាទី១ ទទួលបានលទ្ធផលតម្លៃមធ្យម Mean=១.៧៣, SD=0.៦៦ ស្តង់ដាទី២តម្លៃមធ្យម Mean=២.៤0, SD=0.៨៩ ស្តង់ដាទី៣ តម្លៃមធ្យម Mean=១.៩0, SD=0.៨៦ ស្តង់ដាទី៤ តម្លៃមធ្យមMean=២.៧២, SD=0.៩0 និងស្តង់ដាទី៥ តម្លៃមធ្យម Mean=២.៤២, SD=0.៩៥។

#### ៤.១.២.១ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី១ ផ្តែកលើគណៈគ្រប់គ្រងសាលារៀន

*ក្រាហ្វទី៨៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី១ ផ្តែកលើគណៈគ្រប់គ្រងសាលារៀន*




ក្រាហ្វទី៨ បង្ហាញពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជានលើស្តង់ដាទី១ (ផលសម្រេចអប់រំ និងការសិក្សារបស់សិស្ស)។ តាមប្រភពទិន្នន័យដែលទទួលបានពីគណៈគ្រប់គ្រង

សាលារៀន លទ្ធផលបង្ហាញឱ្យឃើញថា ស្ថិតនៅក្រោមស្តង់ដា ដោយតម្លៃមធ្យម Mean=១.៧៣, SD= ០.៦៦។ ដោយឡែកបើយើងពិនិត្យមើលលម្អិតទៅលើសូចនាករនីមួយៗឃើញថា មានតែសូចនាករ១ ប៉ុណ្ណោះ ដែលស្របនឹងកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា គឺសូចនាករទី១៣ (ចំនួនកុមារមត្តេយ្យសិក្សាមានអាហាររូបត្ថម្ភត្រឹមត្រូវ) ដោយទទួលបានតម្លៃមធ្យម Mean=៣.៥០, SD=១.១២។ ក្រៅពីនោះគឺស្ថិតក្រោមកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋទាំងអស់ រួមមានសូចនាករទី១ ទទួលបានលទ្ធផលត្រឹមតែតម្លៃមធ្យម Mean=១.៥០, SD= ០.៨៤ សូចនាករទី២ លទ្ធផលតម្លៃមធ្យម Mean=១.៨៣, SD=០.៩៨ សូចនាករទី៣ លទ្ធផលតម្លៃមធ្យម Mean=១.៥០, SD=០.៨៤ សូចនាករទី៤ លទ្ធផលតម្លៃមធ្យម Mean=១.០០, SD=០.០០ សូចនាករទី៥ លទ្ធផលតម្លៃមធ្យម Mean=២.១៧, SD=១.៤៧ សូចនាករទី៦ លទ្ធផលតម្លៃមធ្យម Mean=១.០០, SD= ០.០០ សូចនាករទី៧ លទ្ធផលតម្លៃមធ្យម Mean=១.១៧, SD=០.៤១ សូចនាករទី៨ លទ្ធផលតម្លៃមធ្យម Mean=២.១៧, SD=១.៣៣ សូចនាករទី៩ លទ្ធផលតម្លៃមធ្យម Mean=១.៣៣, SD=០.៨២ សូចនាករទី ១០ លទ្ធផលតម្លៃមធ្យម Mean=១.៥០, SD=០.៨៤ សូចនាករទី១១ លទ្ធផលតម្លៃមធ្យម Mean=២.៣៣, SD=១.៣៧ សូចនាករទី១២ លទ្ធផលតម្លៃមធ្យម Mean=១.១៧, SD=០.៤១ សូចនាករទី១៤ លទ្ធផលតម្លៃមធ្យម Mean=១.៨៣, SD=១.៣៣ សូចនាករទី១៥ លទ្ធផលតម្លៃមធ្យម Mean=២.៣៣, SD=១.៥១ និងសូចនាករទី១៦ លទ្ធផលតម្លៃមធ្យម Mean=១.៣៣, SD=០.៨២។

### ៤.១.២.២ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី២ ផ្អែកលើគណៈគ្រប់គ្រងសាលារៀន

*ក្រាហ្វទី៩៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី២ ផ្អែកលើគណៈគ្រប់គ្រងសាលារៀន*




យោងតាមក្រាហ្វទី៩ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន លើស្តង់ដាទី២ (ថ្នាក់រៀនមានដំណើរការសម្រាប់ការបង្រៀន និងរៀន)។ តាមប្រភពទិន្នន័យដែលទទួលបានពីគណៈគ្រប់គ្រងសាលារៀន លទ្ធផលបង្ហាញឱ្យឃើញថា ស្ថិតនៅក្រោមស្តង់ដា ដោយតម្លៃមធ្យម Mean= ២.៤០, SD=០.៨៩។ ដោយឡែក បើយើងពិនិត្យមើលលម្អិតទៅលើសូចនាករនីមួយៗក្នុងស្តង់ទី២នេះឃើញថា មានសូចនាករចំនួន៣ដែលលទ្ធផលស្របនឹងកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។ ក្នុងនោះគឺសូចនាករទី១ (ចំនួនថ្នាក់ធ្វើតេស្តសិស្សត្រីមាស

ទៀងទាត់) មានតម្លៃមធ្យម Mean=៣.៦៧, SD=0.៨២ សូចនាករទី៥ (ចំនួនម៉ោងបង្រៀនជាក់ស្តែងមួយឆ្នាំសិក្សា) មានតម្លៃមធ្យម Mean=៣.៥0, SD=0.៥៥ និងសូចនាករទី៩ (ចំនួនគ្រូបង្រៀនបានទទួលការសង្កេតថ្នាក់រៀនពីនាយកសាលាចំនួន៣ដងក្នុងមួយឆ្នាំ) មានតម្លៃមធ្យម Mean=៣.១៧, SD=0.៩៨។ ផ្ទុយទៅវិញ សូចនាករចំនួន៧ ស្ថិតក្រោមកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ក្នុងនោះមានសូចនាករទី២ លទ្ធផលតម្លៃមធ្យម Mean=១.00, SD=0.00 សូចនាករទី៣ លទ្ធផលតម្លៃមធ្យម Mean=២.៥0, SD=១.៣៨ សូចនាករទី៤ លទ្ធផលតម្លៃមធ្យម Mean=១.៨៣, SD=0.៧៥ សូចនាករទី៦ លទ្ធផលតម្លៃមធ្យម Mean=២.៨៣, SD=0.៩៨ សូចនាករទី៧ លទ្ធផលតម្លៃមធ្យម Mean=១.៥0, SD=0.៨៤ សូចនាករទី៨ លទ្ធផលតម្លៃមធ្យម Mean=១.៨៣, SD=0.៧៥ និងសូចនាករទី១0 លទ្ធផលតម្លៃមធ្យម Mean=២.១៧, SD=១.៤៧។

#### ៤.១.២.៣ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៣ ផ្អែកលើគណៈគ្រប់គ្រងសាលារៀន

*ក្រាហ្វទី១០៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៣ ផ្អែកលើគណៈគ្រប់គ្រងសាលារៀន*



ក្រាហ្វទី១០ បង្ហាញពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន លើស្តង់ដាទី៣ (ភាពជាម្ចាស់នៃសហគមន៍សាលារៀន)។ តាមប្រភពទិន្នន័យដែលទទួលបានពីគណៈគ្រប់គ្រងសាលារៀន លទ្ធផលបង្ហាញឱ្យឃើញថាស្ថិតនៅក្រោមស្តង់ដា ដោយតម្លៃមធ្យម Mean=១.៩០, SD= ០.៨៦។ បើយើងពិនិត្យមើលលម្អិតទៅលើសូចនាករនីមួយៗពីភាគីសំណាកគណៈគ្រប់គ្រងសាលារៀនឃើញថា មានតែសូចនាករ១ប៉ុណ្ណោះដែលស្របនឹងកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា នោះគឺសូចនាករទី៥ (ចំនួនកុមារឈឺបានទទួលការព្យាបាល) ដោយតម្លៃមធ្យម Mean=៣.៦៧, SD=០.៥២។ រីឯ សូចនាករ៩ទៀតស្ថិតនៅក្រោមកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ក្នុងនោះសូចនាករទី១ ទទួលបានលទ្ធផលត្រឹមតែតម្លៃមធ្យម Mean=១.៣៣, SD=០.៨២ សូចនាករទី២ លទ្ធផលតម្លៃមធ្យម Mean=១.០០, SD=០.០០ សូចនាករទី៣ លទ្ធផលតម្លៃមធ្យម Mean=២.៥០, SD=១.៦៤ សូចនាករទី៤ លទ្ធផលតម្លៃមធ្យម Mean=២.១៧, SD= ១.៣៣ សូចនាករទី៦ លទ្ធផលតម្លៃមធ្យម Mean=១.៦៧, SD=១.៦៧ សូចនាករទី៧ លទ្ធផលតម្លៃមធ្យម Mean=១.០០, SD=០.០០ សូចនាករទី៨ លទ្ធផលតម្លៃមធ្យម Mean=១.៨៣, SD=០.៧៥ សូចនាករទី៩ លទ្ធផលតម្លៃមធ្យម Mean=១.១៧, SD=០.៤១ និងសូចនាករទី១០ លទ្ធផលតម្លៃមធ្យម Mean=១.៩០, SD=០.៨៦។

### ៤.១.២.៤ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៤ ផ្អែកលើគណៈគ្រប់គ្រងសាលារៀន

*ក្រាហ្វទី១១៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៤ ផ្អែកលើគណៈគ្រប់គ្រងសាលារៀន*




ក្រាហ្វទី១១ បង្ហាញឱ្យឃើញថា ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន លើស្តង់ដាទី៤ (រដ្ឋបាល និងដំណើរការសាលារៀន)។ តាមប្រភពទិន្នន័យដែលទទួលបានពីគណៈ

គ្រប់គ្រងសាលារៀន លទ្ធផលបង្ហាញឱ្យឃើញថាស្ថិតនៅក្រោមស្តង់ដា ដោយតម្លៃមធ្យម Mean=២.៧២, SD=០.៩០។ ប៉ុន្តែ បើពិនិត្យមើលលម្អិតទៅលើសូចនាករនីមួយៗពីភាគីសំណាកគណៈគ្រប់គ្រងសាលារៀន ឃើញថា មានសូចនាករចំនួនន១១ ស្របនឹងកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលបាន កំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។ ក្នុងនោះសូចនាករទី១ ទទួលបានលទ្ធផលតម្លៃមធ្យម Mean= ៣.៥០, SD=០.៨៤ សូចនាករទី៣ លទ្ធផលតម្លៃមធ្យម Mean=៣.៣៣, SD=០.៥២ សូចនាករទី៤ លទ្ធផលតម្លៃមធ្យម Mean=៣.៦៧, SD=០.៨២ សូចនាករទី៥ លទ្ធផលតម្លៃមធ្យម Mean=៣.០០, SD= ១.១០ សូចនាករទី៦ លទ្ធផលតម្លៃមធ្យម Mean=៣.៣៣, SD=១.០៣ សូចនាករទី១២ លទ្ធផលតម្លៃមធ្យម Mean=៣.០០, SD=០.៨៩ សូចនាករទី១៥ លទ្ធផលតម្លៃមធ្យម Mean=៣.៣៣, SD=០.៨២ សូចនាករទី១៦ លទ្ធផលតម្លៃមធ្យម Mean=៣.៨៣, SD=០.៤១ សូចនាករទី១៨ លទ្ធផលតម្លៃមធ្យម Mean= ៣.៦៧, SD=០.៥២ សូចនាករទី១៩ លទ្ធផលតម្លៃមធ្យម Mean=៣.៦៧, SD=០.៥២ និងសូចនាករទី២០ លទ្ធផលតម្លៃមធ្យម Mean=៣.១៧, SD=០.៩៨។ ដោយឡែក មានសូចនាករចំនួន១០ ដែលទទួលបាន លទ្ធផលតម្លៃមធ្យមក្រោមស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ រួមមានសូចនាករទី២ ទទួលបាន លទ្ធផលតម្លៃមធ្យមត្រឹមតែ Mean=២.៦៧, SD=១.៣៧ សូចនាករទី៧ លទ្ធផលតម្លៃមធ្យម Mean= ១.៣៣, SD=០.៥២ សូចនាករទី៨ លទ្ធផលតម្លៃមធ្យម Mean=១.៥០, SD=១.២២ សូចនាករទី៩ លទ្ធផលតម្លៃមធ្យម Mean=១.០០, SD=០.០០ សូចនាករទី១០ លទ្ធផលតម្លៃមធ្យម Mean=២.៦៧, SD=០.៨២ សូចនាករទី១១ លទ្ធផលតម្លៃមធ្យម Mean=១.៣៣, SD=០.៨២ សូចនាករទី១៣ លទ្ធផលតម្លៃមធ្យម Mean=២.០០, SD=០.៦៣ សូចនាករទី១៤ លទ្ធផលតម្លៃមធ្យម Mean=២.៨៣, SD=០.៧៥ សូចនាករទី ១៧ លទ្ធផលតម្លៃមធ្យម Mean=១.៥០, SD=១.២២ និងសូចនាករទី២១ លទ្ធផលតម្លៃមធ្យម Mean= ២.៨៣, SD=១.៤៧។

### ៤.១.២.៥ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី៥ ផ្អែកលើគណៈគ្រប់គ្រងសាលារៀន

*ក្រាហ្វទី១២៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី៥ ផ្អែកលើគណៈគ្រប់គ្រងសាលារៀន*



ក្រាហ្វទី១២ បង្ហាញពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន លើស្តង់ដាទី៥ (គណនេយ្យភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ)។ តាមប្រភពទិន្នន័យដែលទទួលបានពីគណៈគ្រប់គ្រងសាលារៀន លទ្ធផលបង្ហាញឱ្យឃើញថាស្ថិតនៅក្រោមស្តង់ដា ដោយតម្លៃមធ្យម Mean=២.៤២, SD=០.៩៥។ ដោយឡែក បើពិនិត្យមើលលម្អិតទៅលើសូចនាករនីមួយៗពីភាគសំណាកគណៈគ្រប់គ្រងសាលារៀន ឃើញថា មានតែសូចនាករ៣ ក្នុងចំណោមសូចនាករទាំង១១ ដែលមានតម្លៃមធ្យមស្របនឹងកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ក្នុងនោះសូចនាករទី៥ (ចំនួននាយកឬនាយិកាមានការចាត់តាំងផ្លូវការ) តម្លៃមធ្យម Mean=៤.០០, SD= ០.០០ សូចនាករទី១០ (ចំនួនថ្នាក់រៀនខ្វះបង្កើនការចូលរៀន) តម្លៃមធ្យម Mean=៣.១៧, SD=១.៣៣ និងសូចនាករទី១១ (ចំនួនថ្នាក់រៀនខ្វះបំពេញនិយាមសិស្សថ្នាក់រៀន) តម្លៃមធ្យម Mean=៣.៨៣, SD= ០.៤១ ។ ផ្ទុយទៅវិញ សូចនាករចំនួន៨ទៀត ស្ថិតក្រោមកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ក្នុងនោះសូចនាករទី១ ទទួលបានលទ្ធផលតម្លៃមធ្យមត្រឹមតែ Mean=២.៣៣, SD=១.៣៧ សូចនាករទី២ លទ្ធផលតម្លៃមធ្យម Mean=១.៣៣, SD=០.៥២ សូចនាករទី៣ លទ្ធផលតម្លៃមធ្យម Mean=២.៨៣, SD=១.១៧ សូចនាករទី៤ លទ្ធផលតម្លៃមធ្យម Mean=១.៨៣, SD=១.១៧ សូចនាករទី៦ លទ្ធផលតម្លៃមធ្យម Mean=២.០០, SD=១.៥៥ សូចនាករទី៧ លទ្ធផលតម្លៃមធ្យម Mean=២.១៧, SD=០.៧៥ សូចនាករទី៨ លទ្ធផលតម្លៃមធ្យម Mean=២.១៧, SD=០.៤១ និងសូចនាករទី៩ លទ្ធផលតម្លៃមធ្យម Mean= ១.០០, SD=០.០០។

### ៤.១.៣ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានទាំង៥ស្តង់ដា ផ្អែកលើគ្រូបង្រៀន

*ក្រាហ្វទី១៣៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានទាំង៥ស្តង់ដា ផ្អែកលើគ្រូបង្រៀន*




ក្រាហ្វទី១៣ បង្ហាញពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាជនជានទាំង៥ស្តង់ដា។ តាមប្រភពទិន្នន័យដែលទទួលបានពីគ្រូបង្រៀន លទ្ធផលបានបង្ហាញឱ្យឃើញថា ស្ថិតក្រោមស្តង់ដាសាលារៀនគំរូ សម្រាប់មត្តេយ្យសិក្សារដ្ឋ ដោយតម្លៃមធ្យម Mean=២.២៩, SD=០.៧៩។ ដោយឡែក បើពិនិត្យលម្អិតទៅលើស្តង់ដានីមួយៗឃើញថា ស្តង់ដាទាំង៥ក៏ស្ថិតក្រោមកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ក្នុងនោះស្តង់ដាទី១ ទទួលបានលទ្ធផលតម្លៃមធ្យម Mean=១.៨១, SD=០.៥២ ស្តង់ដាទី២ លទ្ធផលតម្លៃមធ្យម Mean=២.៦០, SD=០.៧១ ស្តង់

ជាទី៣ លទ្ធផលតម្លៃមធ្យម Mean=១.៨៩, SD=០.៦៦ ស្តង់ដាទី៤ លទ្ធផលតម្លៃមធ្យម Mean=២.៨២, SD=០.៧៥ និងស្តង់ដាទី៥ លទ្ធផលតម្លៃមធ្យម Mean=២.៤៩, SD=០.៧៩។

### ៤.១.៣.១ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី១ ផ្អែកលើគ្រូបង្រៀន

*ក្រាហ្វទី១៤៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានស្តង់ដាទី១ ផ្អែកលើគ្រូបង្រៀន*



ក្រាហ្វទី១៤ បង្ហាញពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន លើស្តង់ដាទី១ (ផលសម្រេចអប់រំ និងការសិក្សារបស់សិស្ស)។ តាមប្រភពទិន្នន័យដែលទទួលបានពីគ្រូបង្រៀន លទ្ធផលបានបង្ហាញឱ្យឃើញថា ស្ថិតក្រោមស្តង់ដាសាលារៀនគំរូ សម្រាប់មត្តេយ្យសិក្សារដ្ឋ ដោយតម្លៃមធ្យម Mean=១.៨១, SD=0.៥២។ ដោយឡែក បើយើងពិនិត្យមើលលម្អិតទៅលើសូចនាករនីមួយៗឃើញថា មានតែសូចនាករ១ប៉ុណ្ណោះ ដែលស្របនឹងកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា គឺសូចនាករងទី១៣ (ចំនួនកុមារមត្តេយ្យសិក្សាមានអាហាររូបត្ថម្ភត្រឹមត្រូវ) ដោយទទួលបានតម្លៃមធ្យម Mean=៣.៣៤, SD=១.១៧។ ក្រៅពីនោះគឺស្ថិតក្រោមកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋទាំងអស់ រួមមានសូចនាករទី១ ទទួលបានលទ្ធផលត្រឹមតែតម្លៃមធ្យម Mean=១.៤0, SD=0.៩៣ សូចនាករទី២ លទ្ធផលតម្លៃមធ្យម Mean=២.0៧, SD=១.២0 សូចនាករទី៣ លទ្ធផលតម្លៃមធ្យម Mean=២.២៦, SD=១.២៩ សូចនាករទី៤ លទ្ធផលតម្លៃមធ្យម Mean=១.១៧, SD= 0.៤៨ សូចនាករទី៥ លទ្ធផលតម្លៃមធ្យម Mean=១.៥៩, SD=0.៨៩ សូចនាករទី៦ លទ្ធផលតម្លៃមធ្យម Mean=១.១៩, SD=0.៥៦ សូចនាករទី៧ លទ្ធផលតម្លៃមធ្យម Mean=១.៥0, SD=0.៧៩ សូចនាករទី៨ លទ្ធផលតម្លៃមធ្យម Mean=១.៧១, SD=0.៩0 សូចនាករទី៩ លទ្ធផលតម្លៃមធ្យម Mean=១.៥៩, SD= 0.៨៧ សូចនាករទី១0 លទ្ធផលតម្លៃមធ្យម Mean=១.៩៧, SD=0.៨២ សូចនាករទី១១ លទ្ធផលតម្លៃមធ្យម Mean=១.៩១, SD=១.0៩ សូចនាករទី១២ លទ្ធផលតម្លៃមធ្យម Mean=១.៦៣, SD=0.៧៥ សូចនាករទី១៤ លទ្ធផលតម្លៃមធ្យម Mean=១.៨៨, SD=១.១៥ សូចនាករទី១៥ លទ្ធផលតម្លៃមធ្យម Mean= ២.២៣, SD=១.២៧ និងសូចនាករទី១៦ លទ្ធផលតម្លៃមធ្យម Mean=១.៦១, SD=0.៩៩។

### ៤.១.៣.២ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី២ ផ្អែកលើគ្រូបង្រៀន

*ក្រាហ្វទី១៥៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី២ ផ្អែកលើគ្រូបង្រៀន*




យោងតាមក្រាហ្វទី១៥ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន លើស្តង់ដាទី២ (ថ្នាក់រៀនមានដំណើរការសម្រាប់ការបង្រៀន និងរៀន)។ តាមប្រភពទិន្នន័យដែលទទួលបានពីគ្រូបង្រៀន លទ្ធផលបានបង្ហាញឱ្យឃើញថា ស្ថិតក្រោមស្តង់ដាសាលារៀនគំរូ សម្រាប់មត្តេយ្យសិក្សារដ្ឋ ដោយតម្លៃមធ្យម Mean=២.៦០, SD=០.៧១។ ដោយឡែក បើយើងពិនិត្យមើលលម្អិតទៅលើសូចនាករនីមួយៗក្នុងស្តង់ដាទី២ឃើញថា មានសូចនាករចំនួន៤ដែលលទ្ធផលស្របនឹងកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។ ក្នុងនោះសូចនាករទី១ (ចំនួនថ្នាក់ធ្វើតេស្តសិស្សត្រឹមសទៀងទាត់) មានតម្លៃមធ្យម Mean=៣.២៣, SD=០.៩៦ សូចនាករទី៥ (ចំនួនម៉ោង

បង្រៀនដាក់ស្តែងមួយឆ្នាំសិក្សា) មានតម្លៃមធ្យម Mean=៣.៥៥, SD=0.៧២ សូចនាករទី៦ (ចំនួនគ្រូបង្រៀនមានបំណែងចែកកម្មវិធីសិក្សាសប្តាហ៍) មានតម្លៃមធ្យម Mean=៣.១៣, SD=១.០៧ និងសូចនាករទី៩ (ចំនួនគ្រូបង្រៀនបានទទួលការសង្កេតថ្នាក់រៀនពីនាយកសាលាចំនួន៣ដងក្នុងមួយឆ្នាំ) មានតម្លៃមធ្យម Mean=៣.១៩, SD=0.៩៧ ។ ផ្ទុយទៅវិញ សូចនាករចំនួន៦ ស្ថិតក្រោមកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ក្នុងនោះមានសូចនាករទី២ លទ្ធផលតម្លៃមធ្យម Mean=១.២៣, SD=0.៥៣ សូចនាករទី៣ លទ្ធផលតម្លៃមធ្យម Mean=២.៥៥, SD=១.១៨ សូចនាករទី៤ លទ្ធផលតម្លៃមធ្យម Mean=២.៥0, SD=១.១៤ សូចនាករទី៧ លទ្ធផលតម្លៃមធ្យម Mean=១.៨៦, SD=0.៩៣ សូចនាករទី៨ លទ្ធផលតម្លៃមធ្យម Mean=២.៥៩, SD=១.១៩ និងសូចនាករទី១0 លទ្ធផលតម្លៃមធ្យម Mean=២.២៣, SD=១.១៨។

### ៤.១.៣.៣ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៣ ផ្អែកលើគ្រូបង្រៀន

*ក្រាហ្វទី១៦៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៣ ផ្អែកលើគ្រូបង្រៀន*



ក្រាហ្វទី១៦ បង្ហាញពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន លើស្តង់ដាទី៣ (ភាពជាម្ចាស់នៃសហគមន៍សាលារៀន)។ តាមប្រភពទិន្នន័យដែលទទួលបានពីគ្រូបង្រៀន លទ្ធផលបានបង្ហាញឱ្យឃើញថា ស្ថិតក្រោមស្តង់ដាសាលារៀនគំរូ សម្រាប់មត្តេយ្យសិក្សារដ្ឋ ដោយតម្លៃមធ្យម Mean=១.៨៩, SD=0.៦៦។ បើយើងពិនិត្យមើលលម្អិតទៅលើសូចនាករនីមួយៗពីភាគីសំណាកគ្រូបង្រៀន ឃើញថា មានតែសូចនាករ១ប៉ុណ្ណោះដែលស្របនឹងកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា នោះគឺសូចនាករទី៥ (ចំនួនកុមារឈឺបានទទួលការព្យាបាល) ដោយតម្លៃមធ្យម Mean=៣.៣0, SD=0.៨៧។ រីឯ សូចនាករ៩ទៀតស្ថិតក្រោមកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ក្នុងនោះសូចនាករទី១ ទទួលបានលទ្ធផលត្រឹមតែតម្លៃមធ្យម Mean=២.0៩, SD=១.២៧ សូចនាករទី២ លទ្ធផលតម្លៃមធ្យម Mean=១.១៦, SD=0.៣៧ សូចនាករទី៣ លទ្ធផលតម្លៃមធ្យម Mean=២.២៤, SD=១.៤៤ សូចនាករទី៤ លទ្ធផលតម្លៃមធ្យម Mean=២.0៩, SD=១.១៥ សូចនាករទី៦ លទ្ធផលតម្លៃមធ្យម Mean=១.៨១, SD=0.៩៨ សូចនាករទី៧ លទ្ធផលតម្លៃមធ្យម Mean=១.0៣, SD=0.១៨ សូចនាករទី៨ លទ្ធផលតម្លៃមធ្យម Mean=១.៨៨, SD=0.៦៦ សូចនាករទី៩ លទ្ធផលតម្លៃមធ្យម Mean=១.២៥, SD=0.៤៤ និងសូចនាករទី១0 លទ្ធផលតម្លៃមធ្យម Mean=២.0៣, SD=0.៥៤។

## ៤.១.៣.៤ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៤ ផ្តែកលើគ្រូបង្រៀន

*ក្រាហ្វទី១៧៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៤ ផ្តែកលើគ្រូបង្រៀន*



ក្រាហ្វទី១៧ បង្ហាញឱ្យឃើញថា ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន លើស្តង់ដាទី៤ (រដ្ឋបាល និងដំណើរការសាលារៀន)។ តាមប្រភពទិន្នន័យដែលទទួលបានពីគ្រូបង្រៀន លទ្ធផលបានបង្ហាញឱ្យឃើញថា ស្ថិតក្រោមស្តង់ដាសាលារៀនគំរូ សម្រាប់មត្តេយ្យសិក្សារដ្ឋ ដោយតម្លៃមធ្យម Mean=២.៨២, SD=0.៧៥។ ប៉ុន្តែ បើពិនិត្យមើលលម្អិតទៅលើសូចនាករនីមួយៗពីភាគីសំណាកគ្រូបង្រៀន ឃើញថា មានសូចនាករចំនួន១១ ស្របនឹងកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។ ក្នុងនោះសូចនាករទី១ ទទួលបានលទ្ធផលតម្លៃមធ្យម Mean=៣.៥៣, SD=0.៨0 សូចនាករទី៣ លទ្ធផលតម្លៃមធ្យម Mean=៣.៣៤, SD=0.៩0 សូចនាករទី៤ លទ្ធផលតម្លៃមធ្យម Mean=៣.៦៣, SD=0.៨៨ សូចនាករទី៥ លទ្ធផលតម្លៃមធ្យម Mean=៣.១៣, SD=១.១៣ សូចនាករទី១២ លទ្ធផលតម្លៃមធ្យម Mean=៣.00, SD=0.៨៨ សូចនាករទី១៤ លទ្ធផលតម្លៃមធ្យម Mean=៣.0៣, SD=0.៩៣ សូចនាករទី១៥ លទ្ធផលតម្លៃមធ្យម Mean=៣.៣៤, SD=0.៧៥ សូចនាករទី១៦ លទ្ធផលតម្លៃមធ្យម Mean=៣.៦៩, SD=0.៥៤ សូចនាករទី១៨ លទ្ធផលតម្លៃមធ្យម Mean=៣.៧៤, SD=0.៦៣ សូចនាករទី១៩ លទ្ធផលតម្លៃមធ្យម Mean=៣.៦៨, SD=0.៧0 និងសូចនាករទី២0 លទ្ធផលតម្លៃមធ្យម Mean=៣.៣៤, SD=១.0៤។ ដោយឡែក មានសូចនាករចំនួន១0 ដែលទទួលបានលទ្ធផលមធ្យមក្រោមស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ រួមមានសូចនាករទី២ ទទួលលទ្ធផលតម្លៃមធ្យមត្រឹមតែ Mean=២.៦៥, SD=១.៣២ សូចនាករទី៦ លទ្ធផលតម្លៃមធ្យម Mean=២.៦៦, SD=១.0៤ សូចនាករទី៧ លទ្ធផលតម្លៃមធ្យម Mean=១.៤0, SD=0.៥0 សូចនាករទី៨ លទ្ធផលតម្លៃមធ្យម Mean=១.៧៥, SD=១.១៤ សូចនាករទី៩ លទ្ធផលតម្លៃមធ្យម Mean=១.៦៩, SD=១.៣២ សូចនាករទី១0 លទ្ធផលតម្លៃមធ្យម Mean=២.៩៤, SD=១.0៣ សូចនាករទី១១ លទ្ធផលតម្លៃមធ្យម Mean=១.៧៩, SD=១.១៨ សូចនាករទី១៣ លទ្ធផលតម្លៃមធ្យម Mean=១.៨៤, SD=0.៥១ សូចនាករទី

១៧ លទ្ធផលតម្លៃមធ្យម Mean=២.៤៦, SD=១.៥០ និងសូចនាករទី២១ លទ្ធផលតម្លៃមធ្យម Mean=២.៥២, SD=១.៤៦។

### ៤.១.៣.៥ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៥ ផ្អែកលើគ្រូបង្រៀន

*ក្រាហ្វទី១៨៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៥ ផ្អែកលើគ្រូបង្រៀន*



ក្រាហ្វទី១៨ បង្ហាញពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន លើស្តង់ដាទី៥ (គណនេយ្យភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ)។ តាមប្រភពទិន្នន័យដែលទទួលបានពីគ្រូបង្រៀន លទ្ធផលបានបង្ហាញឱ្យឃើញថា ស្ថិតក្រោមស្តង់ដាសាលារៀនគំរូ សម្រាប់មត្តេយ្យសិក្សារដ្ឋ ដោយតម្លៃមធ្យម Mean=២.៤៩, SD=0.៧៩។ ដោយឡែក បើយើងពិនិត្យមើលលម្អិតទៅលើសូចនាករនីមួយៗពីភាគីសំណាកគ្រូបង្រៀន ឃើញថា មានតែសូចនាករ៤ក្នុងចំណោមសូចនាករទាំង១១ ដែលមានតម្លៃមធ្យមស្របនឹងកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។ ក្នុងនោះសូចនាករទី១ (ចំនួនដងបេសកកម្មការិយាល័យអប់រំស្រុកជួយសាលារៀន) លទ្ធផលតម្លៃមធ្យម Mean=៣.00, SD=១.២២ សូចនាករទី៥ (ចំនួននាយកឬនាយិកាមានការចាត់តាំងផ្លូវការ) លទ្ធផលតម្លៃមធ្យម Mean=៣.៩១, SD=0.៣៩ សូចនាករទី១0 (ចំនួនថ្នាក់រៀនខ្វះបង្កើនការចូលរៀន) លទ្ធផលតម្លៃមធ្យម Mean=៣.២១, SD=១.១៨ និងសូចនាករទី១១ (ចំនួនថ្នាក់រៀនខ្វះបំពេញនិយាមសិស្សថ្នាក់រៀន) លទ្ធផលតម្លៃមធ្យម Mean=៣.២0, SD=១.0៨ ។ ផ្ទុយទៅវិញ សូចនាករចំនួន៧ទៀត ស្ថិតក្រោមកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ក្នុងនោះសូចនាករទី២ លទ្ធផលតម្លៃមធ្យម Mean=២.00, SD=១.១៥ សូចនាករទី៣ លទ្ធផលតម្លៃមធ្យម Mean=២.៥៤, SD=១.៣0 សូចនាករទី៤ លទ្ធផលតម្លៃមធ្យម Mean=២.0៩, SD=១.២៨ សូចនាករទី៦ លទ្ធផលតម្លៃមធ្យម Mean=១.៩១, SD=១.៣៨ សូចនាករទី៧ លទ្ធផលតម្លៃមធ្យម Mean=១.៨៤, SD=0.៩៣ សូចនាករទី៨ លទ្ធផលតម្លៃមធ្យម Mean=២.៥៦, SD=0.៨៨ និងសូចនាករទី៩ លទ្ធផលតម្លៃមធ្យម Mean=១.១៦, SD=0.៥៧។

### ៤.១.៤ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានទាំង៥ស្តង់ដា ផ្អែកលើគណៈកម្មការគ្រប់គ្រងសាលារៀន

*ក្រាហ្វទី១៩៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានទាំង៥ស្តង់ដា ផ្អែកលើគណៈកម្មការគ្រប់គ្រងសាលារៀន*




ក្រាហ្វទី១៩ បង្ហាញពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានទាំង៥ស្តង់ដា។ តាមប្រភពទិន្នន័យដែលទទួលបានពីគណៈកម្មការគ្រប់គ្រងសាលារៀន លទ្ធផលបានបង្ហាញឱ្យឃើញថា ស្ថិតក្រោមស្តង់ដាសាលារៀនគំរូ សម្រាប់មត្តេយ្យសិក្សារដ្ឋ ដោយតម្លៃមធ្យម Mean=២.៤០, SD=០.៤៧។ ដោយឡែក បើពិនិត្យមើលលម្អិតទៅលើស្តង់ដានីមួយៗ ឃើញថា ស្តង់ដាទាំង៥ក៏ស្ថិតក្រោមកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡាដែរ។ ក្នុងនោះស្តង់ដាទី១ ទទួលបានលទ្ធផលតម្លៃមធ្យម Mean=១.៨១, SD=០.៦៦ ស្តង់ដាទី២ លទ្ធផលតម្លៃមធ្យម Mean=២.៨៤, SD=០.៩០ ស្តង់ដាទី៣ លទ្ធផលតម្លៃមធ្យម Mean=២.០០, SD=០.៧៦ ស្តង់ដាទី

៤ លទ្ធផលតម្លៃមធ្យម Mean=២.៨០, SD=០.៨៣ និងស្តង់ដាទី៥ លទ្ធផលតម្លៃមធ្យម Mean=២.៥៦, SD=០.៨៧។

#### ៤.១.៤.១ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី១ ផ្អែកលើគណៈកម្មការគ្រប់គ្រងសាលារៀន

*ក្រាហ្វទី២០៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី១ ផ្អែកលើគណៈកម្មការគ្រប់គ្រងសាលារៀន*



ក្រាហ្វទី២០ បង្ហាញពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន លើស្តង់ដាទី១ (ផលសម្រេចអប់រំ និងការសិក្សារបស់សិស្ស)។ តាមប្រភពទិន្នន័យដែលទទួលបានពីគណៈកម្មការគ្រប់គ្រងសាលារៀន លទ្ធផលបង្ហាញឱ្យឃើញថា ស្ថិតនៅក្រោមស្តង់ដា ដោយតម្លៃមធ្យម Mean=១.៨១, SD=0.៦៦។ ដោយឡែក បើយើងពិនិត្យមើលលម្អិតទៅលើសូចនាករនីមួយៗ ឃើញថា មានតែសូចនាករ១ប៉ុណ្ណោះ ដែលស្របនឹងកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា គឺសូចនាករទី១៣ (ចំនួនកុមារមត្តេយ្យសិក្សាមានអាហាររូបត្ថម្ភត្រឹមត្រូវ) ដោយទទួលបានតម្លៃមធ្យម Mean=៣.៥0, SD=១.២២។ ក្រៅពីនោះគឺស្ថិតក្រោមកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋទាំងអស់ រួមមានសូចនាករទី១ ទទួលបានលទ្ធផលត្រឹមតែតម្លៃមធ្យម Mean=១.១៧, SD=0.៤១ សូចនាករទី២ លទ្ធផលតម្លៃមធ្យម Mean=២.៦៧, SD=១.0៣ សូចនាករទី៣ លទ្ធផលតម្លៃមធ្យម Mean=១.៨៣, SD=0.៩៨ សូចនាករទី៤ លទ្ធផលតម្លៃមធ្យម Mean=១.00, SD=0.00 សូចនាករទី៥ លទ្ធផលតម្លៃមធ្យម Mean=១.២0, SD=0.៤៥ សូចនាករទី៦ លទ្ធផលតម្លៃមធ្យម Mean=១.00, SD=0.00 សូចនាករទី៧ លទ្ធផលតម្លៃមធ្យម Mean=១.៤0, SD=0.៥៥ សូចនាករទី៨ លទ្ធផលតម្លៃមធ្យម Mean=២.៤0, SD=១.៣៤ សូចនាករទី៩ លទ្ធផលតម្លៃមធ្យម Mean=១.៦0, SD=0.៨៩ សូចនាករទី១0 លទ្ធផលតម្លៃមធ្យម Mean=២.00, SD=១.១0 សូចនាករទី១១ លទ្ធផលតម្លៃមធ្យម Mean=១.៦៧, SD=១.២១ សូចនាករទី១២ លទ្ធផលតម្លៃមធ្យម Mean=១.៥0, SD=0.៨៤ សូចនាករទី១៤ លទ្ធផលតម្លៃមធ្យម Mean=២.២៥, SD=១.៥0 សូចនាករទី១៥ លទ្ធផលតម្លៃមធ្យម Mean=២.00, SD=១.៤១ និងសូចនាករទី១៦ លទ្ធផលតម្លៃមធ្យម Mean=១.៨0, SD=១.១0។

### ៤.១.៤.២ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី២ ផ្អែកលើគណៈកម្មការគ្រប់គ្រងសាលារៀន

*ក្រាហ្វទី២១៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាជនជាន ស្តង់ដាទី២ ផ្តោតលើ គណៈកម្មការគ្រប់គ្រងសាលារៀន*



យោងតាមក្រាហ្វទី២១ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន លើស្តង់ដាទី២ (ថ្នាក់រៀនមានដំណើរការសម្រាប់ការបង្រៀន និងរៀន)។ តាមប្រភពទិន្នន័យដែលទទួលបានពីគណៈកម្មការគ្រប់គ្រងសាលារៀន លទ្ធផលបានបង្ហាញឱ្យឃើញថា ស្ថិតក្រោមស្តង់ដាសាលារៀនគំរូ សម្រាប់មត្តេយ្យសិក្សារដ្ឋ ដោយតម្លៃមធ្យម Mean=២.៨៤, SD=0.៩0។ ដោយឡែក បើយើងពិនិត្យមើលលម្អិតទៅលើសូចនាករនីមួយៗក្នុងស្តង់ដាទី២នេះឃើញថា មានសូចនាករចំនួន៦ដែលស្របនឹងកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។ ក្នុងនោះគឺសូចនាករទី១ (ចំនួនថ្នាក់ធ្វើតេស្តសិស្សត្រីមាសទៀងទាត់) មានតម្លៃមធ្យម Mean=៣.៨៣, SD=0.៤៨ សូចនាករទី៤ (ចំនួនគ្រូបង្រៀនមានកិច្ចតែងការតាមការណែនាំ) មានតម្លៃមធ្យម Mean=៣.១៧, SD=0.៩៨ សូចនាករទី៥ (ចំនួនម៉ោងបង្រៀនជាក់ស្តែងមួយឆ្នាំសិក្សា) មានតម្លៃមធ្យម Mean=៣.៦៧, SD=0.៥២ សូចនាករទី៨ (ចំនួនគ្រូបង្រៀនបានរៀបចំថ្នាក់រៀនតាមស្តង់ដា) មានតម្លៃមធ្យម Mean=៣.១៧, SD=0.៨៩ សូចនាករទី៩ (ចំនួនគ្រូបង្រៀនបានទទួលការសង្កេតថ្នាក់រៀនពីនាយកសាលាចំនួន៣ដងក្នុងមួយឆ្នាំ) មានតម្លៃមធ្យម Mean=៣.៥0, SD=0.៨៤ និងសូចនាករទី១0 (ចំនួនប្រជុំបច្ចេកទេសប្រចាំសប្តាហ៍) មានតម្លៃមធ្យម Mean=៣.00, SD=១.៤១ ។ ផ្ទុយទៅវិញ សូចនាករចំនួន៤ ស្ថិតក្រោមកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ក្នុងនោះមានសូចនាករទី២ លទ្ធផលតម្លៃមធ្យម Mean=១.00, SD=0.00 សូចនាករទី៣ លទ្ធផលតម្លៃមធ្យម Mean=២.៦0, SD=១.១៤ សូចនាករទី៦ លទ្ធផលតម្លៃមធ្យម Mean=២.៨៣, SD=១.១៧ និងសូចនាករទី៧ លទ្ធផលតម្លៃមធ្យម Mean=១.៦0, SD=១.៣៣។

### ៤.១.៤.៣ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី៣ ផ្តែកលើគណៈកម្មការគ្រប់គ្រងសាលារៀន

*ក្រាហ្វទី២២៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ស្តង់ដាទី៣ ផ្អែកលើគណៈកម្មការគ្រប់គ្រងសាលារៀន*




ក្រាហ្វទី២២ បង្ហាញពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន លើស្តង់ដាទី៣ (ភាពជាម្ចាស់នៃសហគមន៍សាលារៀន)។ តាមប្រភពទិន្នន័យដែលទទួលបានពីគណៈកម្មការគ្រប់គ្រងសាលារៀន លទ្ធផលបានបង្ហាញឱ្យឃើញថា ស្ថិតក្រោមស្តង់ដាសាលារៀនគំរូ សម្រាប់មត្តេយ្យសិក្សារដ្ឋ ដោយតម្លៃមធ្យម Mean=២.០០, SD=០.៧៦។ បើយើងពិនិត្យមើលលម្អិតទៅលើសូចនាករនីមួយៗ ពីភាគីសំណាកគណៈកម្មការគ្រប់គ្រងសាលារៀន ឃើញថា មានតែសូចនាករ១ប៉ុណ្ណោះដែលស្របនឹងកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា នោះគឺសូចនាករទី៥ (ចំនួនកុមារឈឺបានទទួលការព្យាបាល) ដោយតម្លៃមធ្យម Mean=៣.៥០, SD=០.៥៨។ រីឯ សូចនាករ៩ទៀតស្ថិតនៅក្រោមកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ក្នុងនោះសូចនាករទី១ ទទួលបានលទ្ធផលត្រឹមតែតម្លៃមធ្យម Mean=២.០០, SD=១.៤១ សូចនាករទី២ លទ្ធផលតម្លៃមធ្យម Mean=១.០០, SD=០.០០ សូចនាករទី៣ លទ្ធផលតម្លៃមធ្យម Mean=២.៤០, SD=១.៥២ សូចនាករទី៤ លទ្ធផលតម្លៃមធ្យម Mean=២.២៣, SD=១.៥១ សូចនាករទី៦ លទ្ធផលតម្លៃមធ្យម Mean=១.៨០, SD=១.១០ សូចនាករទី៧ លទ្ធផលតម្លៃមធ្យម Mean=១.១៧, SD=០.៤១ សូចនាករទី៨ លទ្ធផលតម្លៃមធ្យម Mean=១.៨៣, SD=០.៧៥ សូចនាករទី៩ លទ្ធផលតម្លៃមធ្យម Mean=១.៣៣, SD=០.៥២ និងសូចនាករទី១០ លទ្ធផលតម្លៃមធ្យម Mean=២.៦៧, SD=១.០៣។

### ៤.១.៤.៤ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៤ ផ្អែកលើ គណៈកម្មការគ្រប់គ្រងសាលារៀន

*ក្រាហ្វទី២៣៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៤ ផ្អែកលើ គណៈកម្មការគ្រប់គ្រងសាលារៀន*



ក្រាហ្វទី២៣ បង្ហាញឱ្យឃើញថា ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន លើស្តង់ដាទី៤ (រដ្ឋបាល និងដំណើរការសាលារៀន)។ តាមប្រភពទិន្នន័យដែលទទួលបានពីគណៈកម្មការគ្រប់គ្រងសាលារៀន លទ្ធផលបានបង្ហាញឱ្យឃើញថា ស្ថិតក្រោមស្តង់ដាសាលារៀនគំរូ សម្រាប់មត្តេយ្យសិក្សារដ្ឋ ដោយតម្លៃមធ្យម Mean=២.៨០, SD=០.៨៣។ ប៉ុន្តែ បើពិនិត្យមើលលម្អិតទៅលើសូចនាករនីមួយៗពីភាគីសំណាកគណៈកម្មការគ្រប់គ្រងសាលារៀន ឃើញថា មានសូចនាករចំនួន១២ ស្របនឹងកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។ ក្នុងនោះសូចនាករទី១ ទទួលបានលទ្ធផលតម្លៃមធ្យម Mean=៣.៥០, SD=០.៨៤ សូចនាករទី៣ លទ្ធផលតម្លៃមធ្យម Mean=៣.០០, SD=១.១០ សូចនាករទី៤ លទ្ធផលតម្លៃមធ្យម Mean=៣.៦០, SD=០.៨៩ សូចនាករទី៥ លទ្ធផលតម្លៃមធ្យម Mean=៣.៣៣, SD=១.០៣ សូចនាករទី៦ លទ្ធផលតម្លៃមធ្យម Mean=៣.០០, SD=១.១០ សូចនាករទី១២ លទ្ធផលតម្លៃមធ្យម Mean=៣.០០, SD=០.៨៩ សូចនាករទី១៤ លទ្ធផលតម្លៃមធ្យម Mean=៣.០០, SD=០.៨៩ សូចនាករទី១៥ លទ្ធផលតម្លៃមធ្យម Mean=៣.៣៣, SD=០.៨២ សូចនាករទី១៦ លទ្ធផលតម្លៃមធ្យម Mean=៣.៨៣, SD=០.៤១ សូចនាករទី១៨ លទ្ធផលតម្លៃមធ្យម Mean=៣.៨៣, SD=០.៤១ សូចនាករទី១៩ លទ្ធផលតម្លៃមធ្យម Mean=៤.០០, SD=០.០០ និងសូចនាករទី២០ លទ្ធផលតម្លៃមធ្យម Mean=៣.៣៣, SD=១.០៣។ ដោយឡែកមានសូចនាករចំនួន១០ ដែលទទួលបានលទ្ធផលតម្លៃមធ្យមក្រោមស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ មានសូចនាករទី២ ទទួលបានលទ្ធផលតម្លៃមធ្យមត្រឹមតែ Mean=២.៤០, SD=១.៣៤ សូចនាករទី៧ លទ្ធផលតម្លៃមធ្យម Mean=១.២៥, SD=០.៥០ សូចនាករទី៨ លទ្ធផលតម្លៃមធ្យម Mean=១.៧៥, SD=១.៥០ សូចនាករទី៩ លទ្ធផលតម្លៃមធ្យម Mean=១.៦០, SD=១.៣៤ សូចនាករទី១០ លទ្ធផលតម្លៃមធ្យម Mean=២.៦០, SD=០.៨៩ សូចនាករទី១១ លទ្ធផលតម្លៃមធ្យម Mean=២.១៧, SD=១.៣៣ សូចនាករទី១៣ លទ្ធផលតម្លៃមធ្យម Mean=

១.៨៣, SD=០.៤១ សូចនាករទី១៧ លទ្ធផលតម្លៃមធ្យម Mean=១.៦០, SD=១.៣៤ និងសូចនាករទី២១ លទ្ធផលតម្លៃមធ្យម Mean=២.៨៣, SD=១.៤៧។

### ៤.១.៤.៥ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៥ ផ្អែកលើគណៈកម្មការគ្រប់គ្រងសាលារៀន

*ក្រាហ្វទី២៤៖ ស្ថានភាពនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៥ ផ្អែកលើគណៈកម្មការគ្រប់គ្រងសាលារៀន*




ក្រាហ្វទី២៤ បង្ហាញពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន លើស្តង់ដាទី៥ (គណនេយ្យភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ)។ តាមប្រភពទិន្នន័យដែលទទួលបានពីគណៈកម្មការ

គ្រប់គ្រងសាលារៀន លទ្ធផលបានបង្ហាញឱ្យឃើញថា ស្ថិតក្រោមស្តង់ដាសាលារៀនគំរូ សម្រាប់មត្តេយ្យសិក្សារដ្ឋ ដោយតម្លៃមធ្យម Mean=២.៥៦, SD=០.៨៧។ ដោយឡែក បើយើងពិនិត្យមើលលម្អិតទៅលើសូចនាករនីមួយៗពីភាគសំណាកគណៈកម្មការគ្រប់គ្រងសាលារៀន ឃើញថា មានតែសូចនាករ៣ ក្នុងចំណោមសូចនាករទាំង១១ ដែលមានតម្លៃមធ្យមស្របនឹងកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ក្នុងនោះសូចនាករទី៥ (ចំនួននាយកឬនាយិកាមានការចាត់តាំងផ្លូវការ) មានតម្លៃមធ្យម Mean=៤.០០, SD=០.០០ សូចនាករទី១០ (ចំនួនថ្នាក់រៀនខ្វះបង្កើនការចូលរៀន) មានតម្លៃមធ្យម Mean=៣.៥០, SD=០.៨៤ និងសូចនាករទី១១ (ចំនួនថ្នាក់រៀនខ្វះបំពេញនិយាមសិស្សថ្នាក់រៀន) លទ្ធផលតម្លៃមធ្យម Mean=៣.៦០, SD=០.៥៥ ។ ផ្ទុយទៅវិញ សូចនាករចំនួន៨ទៀតស្ថិតក្រោមកម្រិតស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ក្នុងនោះសូចនាករទី១ ទទួលបានលទ្ធផលតម្លៃមធ្យមត្រឹមតែ Mean=២.៦០, SD=១.៣៤ សូចនាករទី២ លទ្ធផលតម្លៃមធ្យម Mean=២.០០, SD=១.២២ សូចនាករទី៣ លទ្ធផលតម្លៃមធ្យម Mean=២.៨០, SD=១.៣០ សូចនាករទី៤ លទ្ធផលតម្លៃមធ្យម Mean=២.១៧, SD=១.៤៧ សូចនាករទី៦ លទ្ធផលតម្លៃមធ្យម Mean=២.០០, SD=១.៥៥ សូចនាករទី៧ លទ្ធផលតម្លៃមធ្យម Mean=២.០០, SD=០.៨៩ សូចនាករទី៨ លទ្ធផលតម្លៃមធ្យម Mean=២.៥០, SD=០.៨៤ និងសូចនាករទី៩ លទ្ធផលតម្លៃមធ្យម Mean=១.០០, SD=០.០០។

## ៤.២ បញ្ហាប្រឈម និងដំណោះស្រាយ

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវនឹងធ្វើបង្ហាញពីបញ្ហាប្រឈម និងដំណោះស្រាយ ចំពោះស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានដែលបានរកឃើញក្នុងការសិក្សាស្រាវជ្រាវនេះ ជាការលើកឡើងពីភាគីសំណាកគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀនដែលអ្នកសិក្សាស្រាវជ្រាវបានជួបសម្ភាសន៍ក្នុងពេលចុះប្រមូលទិន្នន័យ ដែលមានលក្ខណៈស្របនឹងចម្លើយក្នុងការបំពេញកម្រងសំណួរផងដែរ។

ក្នុងការសិក្សាស្រាវជ្រាវនេះ មានការចូលរួមពីភាគីសំណាកសរុប៤៤នាក់ គណៈគ្រប់គ្រងសាលារៀន ចំនួន៦នាក់ គ្រូបង្រៀនចំនួន៣២នាក់ និងគណៈកម្មការគ្រប់គ្រងសាលារៀនចំនួន៦នាក់ ដែលត្រូវយកមកសិក្សាលើប្រធានបទនេះ។

## ៤.២.១ បញ្ហាប្រឈមនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានទាំង៥ស្តង់ដា

ក្រោយពីការវិភាគអ្នកស្រាវជ្រាវសង្កេតឃើញថា ភាគច្រើននៃសូចនាករទាំងនោះអនុវត្តបានកម្រិតទាបជាងស្តង់ដាសាលារៀនគម្រូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ដោយសារមានបញ្ហាប្រឈមជាច្រើន។ ផ្អែកតាមក្រាហ្វទី២៥ ខាងក្រោមបញ្ជាក់ថាស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅមត្តេយ្យសិក្សាធនធាន បញ្ហាប្រឈមបណ្តាលមកពីកត្តាធំៗ៣គឺ៖ **ទី១ សមត្ថភាព** កត្តានេះមានអ្នកចូលរួម៣១នាក់ស្មើនឹង៧០%បញ្ជាក់ថា គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន មិនទាន់យល់ច្បាស់ពីតួនាទីភារកិច្ចរបស់ខ្លួនក្នុងការអនុវត្តសូចនាករនីមួយៗ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។ លើសពីនេះទៅទៀតគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀនជាង៩០% មិនធ្លាប់បានចូលរួមវគ្គបំប៉នសមត្ថភាពស្តីពីស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលនេះជារឿងថ្មីមួយសម្រាប់សាលាមត្តេយ្យសិក្សា។ **ទី២ ខ្វះការចូលរួមពីភាគីពាក់ព័ន្ធ** មានអ្នកចូលរួម ២៧នាក់ស្មើនឹង៦១% បានលើកហេតុផលមួយចំនួនដូចជាក្រសួង មន្ទីរ មិនបានចូលរួមជួយឱ្យបានជិតស្និត និងទាន់ពេល អាជ្ញាធរមូលដ្ឋាន សហគមន៍មិនសូវខ្វាយខ្វល់ពីការអំពាវនាវ ក៏ដូចជាស្នើសុំការសហការណ៍ផ្សេងៗពីសាលារៀន។ **ទី៣ ធនធាន(មនុស្ស សម្ភារ ថវិកា)** កត្តានេះដែរ មានអ្នកចូលរួម២៩នាក់ស្មើនឹង ៦៦% ផ្អែកលើហេតុផលខ្វះខាតថវិកា សម្ភារសំខាន់ៗដូចជាទូរទស្សន៍ កុំព្យូទ័រ ហើយក្រសួងអប់រំ ឬមន្ទីរមិនបានបណ្តុះបណ្តាល ឬផ្តល់គ្រូឯកទេសភាសាអង់គ្លេស និងICT ដែលជាសមាសភាពសំខាន់មួយក្នុងការអនុវត្តកម្មវិធីថ្មីនេះ។

សរុបមកកត្តាដែលធ្វើឱ្យស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្ថិតនៅទាបជាងស្តង់ដា ដោយសារកត្តាសមត្ថភាព កត្តាខ្វះការចូលរួមពីភាគីពាក់ព័ន្ធ និងកត្តាធនធាន(មនុស្ស សម្ភារ ថវិការ)។




*ក្រាហ្វទី២៥៖ បញ្ហាប្រឈមនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានទាំង៥ស្តង់ដា*

### ៤.២.១.១ បញ្ហាប្រឈមនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី១

ចំណុច៤.២.១ ខាងលើយើងបានវិភាគទៅលើបញ្ហាប្រឈម ក្នុងការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ដែលជាការលើកឡើងពីភាគីសំណាកគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន ដោយផ្តោតទៅលើកត្តា៣គឺ៖ កត្តាសមត្ថភាព ខ្វះការចូលរួមពីភាគីពាក់ព័ន្ធ និងកត្តាធនធាន(មនុស្ស សម្ភារ ថវិកា)។ ផ្នែកនេះអ្នកស្រាវជ្រាវនឹងធ្វើការវិភាគទៅលើបញ្ហាប្រឈមនៃកត្តា

ទាំង៣ ទៅតាមស្តង់ដានីមួយៗវិញម្តង ថាតើមានអ្នកចូលរួមប៉ុន្មានភាគរយកំណត់បញ្ហាប្រឈមលើកត្តាសមត្ថភាព ខ្វះការចូលរួមពីភាគីពាក់ព័ន្ធ និងធនធាន(មនុស្ស សម្ភារ ថវិកា)។

ផ្អែកតាមក្រាហ្វទី២៦ ខាងក្រោមពិនិត្យឃើញថាស្តង់ដាទី១ (ផលសម្រេចអប់រំ និងការសិក្សារបស់សិស្ស) បញ្ហាប្រឈមនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន លើកត្តាសមត្ថភាពមាន ៥០.០០% កត្តាខ្វះការចូលរួមពីភាគីពាក់ព័ន្ធមាន៤៣.១៨% និងកត្តាធនធាន(មនុស្ស សម្ភារ ថវិកា) មាន ៤៧.៧៣%។ សរុបមកបញ្ហាប្រឈមទាក់ទងនឹងកត្តាសមត្ថភាព ខ្វះការចូលរួមពីភាគីពាក់ព័ន្ធ និងកត្តាធនធាន(មនុស្ស សម្ភារ ថវិកា) ក្នុងស្តង់ដាទី១ មានចំនួនប្រហាក់ប្រហែលគ្នា។




*ក្រាហ្វទី២៦៖ បញ្ហាប្រឈមនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី១*

### ៤.២.១.២ បញ្ហាប្រឈមនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី២

យោងតាមក្រាហ្វទី២៧ ខាងក្រោមពិនិត្យឃើញថាស្តង់ដាទី២ (ថ្នាក់រៀនមានដំណើរការសម្រាប់ការបង្រៀន និងរៀន) មានបញ្ហាប្រឈមនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន លើកត្តាសមត្ថភាព៥៦.៨២% កត្តាខ្វះការចូលរួមពីភាគីពាក់ព័ន្ធ៥០.០០% និងកត្តាធនធាន(មនុស្ស សម្ភារ ថវិកា) ៣៨.៦៤%។ សរុបមកក្នុងស្តង់ដាទី២ មានបញ្ហាប្រឈមទាក់ទងនឹងកត្តាសមត្ថភាពមានភាគរយខ្ពស់ជាងគេ និងបញ្ហាប្រឈមទាក់ទងនឹងកត្តាធនធាន(មនុស្ស សម្ភារ ថវិកា)មានភាគរយទាបជាងគេ។




*ក្រាហ្វទី២៧៖ បញ្ហាប្រឈមនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី២*

### ៤.២.១.៣ បញ្ហាប្រឈមនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៣

ផ្អែកតាមក្រាហ្វទី២៨ ខាងក្រោមអ្នកសិក្សាស្រាវជ្រាវពិនិត្យឃើញថាស្តង់ដាទី៣ (ភាពជាម្ចាស់នៃសហគមន៍សាលារៀន) មានបញ្ហាប្រឈមនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន លើកត្តាសមត្ថភាព៦១.៣៦% កត្តាខ្វះការចូលរួមពីភាគីពាក់ព័ន្ធ៤៧.៧៣% និងកត្តាធនធាន(មនុស្ស សម្ភារ ថវិកា)៥៦.៨២%។ សរុបមកក្នុងស្តង់ដាទី៣ មានបញ្ហាប្រឈមទាក់ទងនឹងកត្តាសមត្ថភាពក៏មានភាគរយខ្ពស់ជាងគេ និងបញ្ហាប្រឈមទាក់ទងនឹងកត្តាខ្វះការចូលរួមពីភាគីពាក់ព័ន្ធ មានភាគរយទាបជាងគេ។




*ក្រាហ្វទី២៨៖ បញ្ហាប្រឈមនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៣*

### ៤.២.១.៤ បញ្ហាប្រឈមនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៤

ផ្អែកតាមក្រាហ្វទី២៩ ខាងក្រោមអ្នកសិក្សាស្រាវជ្រាវពិនិត្យឃើញថាស្តង់ដាទី៤ (រដ្ឋបាល និងដំណើរការសាលារៀន) មានបញ្ហាប្រឈមនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន លើកត្តាសមត្ថភាព៥២.២៧% កត្តាខ្វះការចូលរួមពីភាគីពាក់ព័ន្ធ៦៨.១៨% និងកត្តាធនធាន(មនុស្ស សម្ភារ ថវិកា) ៤៥.៤៥%។ សរុបមកក្នុងស្តង់ដាទី៤ មានបញ្ហាប្រឈមទាក់ទងនឹងកត្តាខ្វះការចូលរួមពីភាគីពាក់ព័ន្ធ មានភាគរយខ្ពស់ជាងគេ និងបញ្ហាប្រឈមទាក់ទងនឹងកត្តាធនធាន(មនុស្ស សម្ភារ ថវិកា) មានភាគរយទាបជាងគេ។




*ក្រាហ្វទី២៩៖ បញ្ហាប្រឈមនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៤*

### ៤.២.១.៥ បញ្ហាប្រឈមនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៥

ផ្អែកតាមក្រាហ្វទី៣០ ខាងក្រោមអ្នកសិក្សាស្រាវជ្រាវពិនិត្យឃើញថាស្តង់ដាទី៥ (គណនេយ្យភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) មានបញ្ហាប្រឈមនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានលើកត្តាសមត្ថភាព៦៩.៩១% កត្តាខ្វះការចូលរួមពីភាគីពាក់ព័ន្ធ៧៧.២៧% និងកត្តាធនធាន(មនុស្ស សម្ភារ ថវិកា)៥២.២៧%។ សរុបមកក្នុងស្តង់ដាទី៥ មានបញ្ហាប្រឈមទាក់ទងនឹងកត្តាខ្វះការចូលរួមពីភាគីពាក់ព័ន្ធ នៅតែមានភាគរយខ្ពស់ជាងគេ និងបញ្ហាប្រឈមទាក់ទងនឹងកត្តាធនធាន(មនុស្ស សម្ភារ ថវិកា) ក៏នៅតែមានភាគរយទាបជាងគេដែរ។




*ក្រាហ្វទី៣០៖ បញ្ហាប្រឈមនៃការដឹកនាំគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ស្តង់ដាទី៥*

### ៤.២.២ ដំណោះស្រាយលើការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន

តាមរយៈការបង្ហាញអំពីបញ្ហាប្រឈមក្នុងការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យធនធាន ខាងលើ ដែលជាការលើកឡើងរបស់ភាគីសំណាកទាំង៣ គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន អ្នកសិក្សាស្រាវជ្រាវក៏បានស្រង់ខ្លឹមសារសំខាន់ៗដែលជាដំណោះស្រាយលើបញ្ហាប្រឈមទាំងនោះពីភាគីសំណាកចូលរួមផងដែរ។ លទ្ធផលនេះបង្ហាញថា កត្តាសំខាន់៣គឺសមត្ថភាព ខ្វះការចូលរួមពីភាគីពាក់ព័ន្ធ និងធនធាន(មនុស្ស សម្ភារ ថវិកា) ដែលជាបុព្វហេតុធ្វើឱ្យការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយសិក្សាធនធាន នៅទាបជាងស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។ សរុបមកដើម្បីស្តារស្ថានភាព ក៏ដូចជាលទ្ធផលនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ឱ្យស្របតាមស្តង់ដាសាលារៀនគំរូ សម្រាប់មត្តេយ្យសិក្សារដ្ឋ ភាគសំណាកទាំង ៣ ក៏បានលើជាដំណោះស្រាយមួយចំនួនផងដែរ។

#### ៤.២.២.១ សមត្ថភាព

-គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន ស្វែងយល់ពីតួនាទីភារកិច្ចរបស់ខ្លួនឱ្យបានច្បាស់លាស់ និងសហការគ្នាក្នុងការអនុវត្តការងារទាំងអស់របស់សាលាមត្តេយ្យសិក្សាធនធាន តាមសូចនាករចង្អុលបង្ហាញនៃស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។

-គណៈគ្រប់គ្រងសាលា ជំរុញគាំទ្រ និងលើកទឹកចិត្តគ្រូបង្រៀនភាសាអង់គ្លេស និងបច្ចេកវិទ្យាICT ឱ្យចូលរួមវគ្គបណ្តុះបណ្តាលរបស់ក្រសួងអប់រំ យុវជន និងកីឡា អង្គការ ឬឯកជន ដើម្បីពង្រឹងសមត្ថភាពចំណេះជំនាញ ឱ្យបានស្ទាត់ និងច្បាស់លាស់។

#### ៤.២.២.២ ការចូលរួមពីភាគីពាក់ព័ន្ធ

-គណៈគ្រប់គ្រងសាលារៀន បង្កើត និងបង្កើនទំនាក់ទំនងល្អ ជាមួយមាតាបិតាអាណាព្យាបាលសិស្ស និងសហគមន៍ទាំងមូល ព្រមទាំងភាគីពាក់ទាំងអស់ ដើម្បីទទួលបានការចូលរួមទាំងគំនិតយោបល់ ធនធានសម្ភារ និងធនធានថវិកា ក្នុងការបំពេញតម្រូវ ឬការសាងសង់ផ្សេងៗរបស់សាលារៀន។

-សាលារៀនមានផែនការច្បាស់លាស់ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដើម្បីផ្តល់ជាទំនុកចិត្ត ជៀសវាងការចោទប្រកាន់គ្នាទៅវិញទៅមក រវាងសាលារៀន សហមន៍ និងភាគីពាក់ព័ន្ធផ្សេងៗ និងបង្កើតភាពកក់ក្តៅក្នុងការចូលរួមអភិវឌ្ឍសាលារៀនឱ្យមានការរីកចម្រើន និងស្របតាមស្តង់ដាសាលារៀនគំរូ ដែលជាការកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា។

-ផ្សព្វផ្សាយទៅភាគីពាក់ព័ន្ធ សហគមន៍ ឱ្យបានយល់ច្បាស់លាស់ពីកម្មវិធីរបស់សាលារៀន ជាពិសេសកម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានដាក់ឱ្យអនុវត្តស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ។

#### ៤.២.២.៣ ធនធាន(មនុស្ស សម្ភារ ថវិកា)

-គណៈគ្រប់គ្រង គ្រូបង្រៀន បើកចិត្តទទួលយក និងខិតខំពង្រឹងសមត្ថភាពក្នុងការអនុវត្តការងារឱ្យស្របនឹងសូចនាករ និងស្តង់ដារសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ។

-បន្តស្វែងរកការគាំទ្រពីភាគីពាក់ព័ន្ធ ទាំងធនធានសម្ភារ និងថវិកា តាមរយៈការបង្កើតឱ្យមានផែនការចក្ខុវិស័យ និងបេសកកម្មច្បាស់លាស់ ប្រកបដោយការជឿទុកចិត្តពីមាតាបិតា អាណាព្យាបាល និងសហគមន៍។

-បង្កើតជាកម្មវិធីផ្សេងៗ ដើម្បីទទួលបានថវិកាសម្រាប់កសាង ឬទិញសម្ភារចាំបាច់ៗ ជាអត្ថិភាពក្នុងការអភិវឌ្ឍ និងដំណើរការបង្រៀន និងរៀន ឱ្យទទួលលទ្ធផលប្រកបដោយគុណភាព ដូចជាកម្មវិធីបុណ្យផ្កាសាមគ្គី ឬផ្សព្វផ្សាយពីផែនការអភិវឌ្ឍផ្សេងៗ នៅក្នុងកម្មវិធីនានារបស់សហគមន៍។

### ៤.២.៣ ការពិភាក្សា

ការសិក្សាស្រាវជ្រាវលើស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានក្នុងខេត្តស្វាយរៀង បង្ហាញឱ្យឃើញថាការដឹននាំ និងគ្រប់គ្រងមានកម្រិតទាបជាងស្តង់ដាសាលារៀនគំរូ នៅឡើយ។ ដោយឡែក បើតាមការសិក្សាស្រាវជ្រាវរបស់ Lily Yuntina (2019) ក្នុងប្រទេសឥណ្ឌូនេស៊ី លទ្ធផលបង្ហាញថាការគ្រប់គ្រងរបស់សាលាមត្តេយ្យ Rose Red ក្នុងទីក្រុង Bekasi គឺស្របនឹងចក្ខុវិស័យ និងបេសកកម្មរបស់ស្ថានប័ន ដោយបានអនុវត្តមុខងារគ្រប់គ្រង រួមបញ្ចូលទាំងការធ្វើផែនការ ការរៀបចំ ការធ្វើសកម្មភាព ការគ្រប់គ្រង។ ចំណែកឯការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានក្នុងខេត្តស្វាយរៀងវិញ មានកម្រិតក្រោមស្តង់ដានៅឡើយ ដោយកត្តាខ្វះសមត្ថភាព ខ្វះការចូលរួមពីភាគីពាក់ព័ន្ធ និង កត្តាធនធាន ដែលរួមបញ្ចូលទាំងធនធានមនុស្ស ធនធានសម្ភារ និងធនធានថវិកា។ មួយវិញទៀត លទ្ធផលខុសគ្នារវាងការស្រាវជ្រាវទាំង២ខាងលើនេះ ដោយសារតែ ទីតាំងស្ថានភាពនយោបាយ សេដ្ឋកិច្ចផ្សេងគ្នា ពេលវេលាសិក្សាស្រាវជ្រាវខុសគ្នា

# ជំពូក៥

# សេចក្តីសន្និដ្ឋាន និង សំណូមពរ

# ជំពូក៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១. សេចក្តីសន្និដ្ឋាន

ការដឹកនាំ និងគ្រប់គ្រងនៅកម្រិតមត្តេយ្យសិក្សា ពិតជាមានសារសំខាន់ណាស់ដើម្បីបណ្តុះស្មារតីជាមូលដ្ឋានរបស់កុមារ បង្កើតចរិតលក្ខណៈមនុស្សពេញលេញ បណ្តុះសញ្ញាណបំណិនសិក្សាពេញមួយជីវិត បង្កើតបរិស្ថានសិក្សារួម និងធ្វើឱ្យសម្រេចបាននូវគោលដៅរួមនៃលទ្ធផលសិក្សារបស់កុមារ។ ជាពិសេសកុមារបានត្រៀមខ្លួនរួចជាស្រេច ក្នុងការចូលរៀននៅកម្រិតបឋមសិក្សាផងដែរ។ ដោយឡែកសាលាមត្តេយ្យសិក្សាធនធាន ជាសាលារៀនគំរូ ដូច្នេះទាមទារឱ្យគណៈគ្រប់គ្រងសាលារៀនយកចិត្តទុកដាក់ខ្ពស់ក្នុងការដឹកនាំ និងគ្រប់គ្រង ដើម្បីបង្ហាញលទ្ធផលជាគំរូដល់សាលាមត្តេយ្យសិក្សាដទៃទៀត ឬសាលារៀនដែលថ្នាក់មត្តេយ្យសិក្សា អនុវត្តតាម។ ដើម្បីឱ្យការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ឆ្លើយតបទៅនឹងតម្រូវការសង្គម គោលនយោបាយរបស់រាជរដ្ឋាភិបាល គោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា រួមទាំងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់សាលារៀន ទាមទារឱ្យគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងគ្រប់ភាគីពាក់ព័ន្ធ សហការគ្នាអនុវត្តការងារតាមស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ឱ្យមានប្រសិទ្ធភាពស្របនឹងស្តង់ដា។ ហេតុដូច្នេះហើយបានជាអ្នកស្រាវជ្រាវកំណត់យកប្រធានបទមួយស្តីពី "ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានក្នុងខេត្តស្វាយរៀង" មកធ្វើការសិក្សាស្រាវជ្រាវក្នុងគោលបំណង (១) រកឱ្យឃើញពីស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានក្នុងខេត្តស្វាយរៀង។ និង(២) រកឱ្យឃើញពីបញ្ហាប្រឈមនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានក្នុងខេត្តស្វាយរៀង។

ឆ្លើយតបទៅនឹងសំណួរ និងគោលបំណងនៃការស្រាវជ្រាវដែលទាក់ទងនឹងស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន នៅសាលាមត្តេយ្យសិក្សាធនធានគោលដៅនានាក្នុងខេត្ត

ស្វាយរៀង ដោយផ្អែកទៅតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញឱ្យឃើញថា ការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនជាន ក្នុងក្របខ័ណ្ឌទូទាំងខេត្ត មិនទាន់បានស្របនឹងស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋនៅឡើយទេ លទ្ធផលជារួមតម្លៃមធ្យម Mean=២.៣២, SD=0.0៨។ លទ្ធផលនេះទទួលបានពីភាគីសំណាកគណៈគ្រប់គ្រងសាលារៀនចំនួន៦នាក់ គ្រូបង្រៀនចំនួន៣២នាក់ និងគណៈកម្មការគ្រប់គ្រងសាលារៀនចំនួន៦នាក់។

ចំណែកស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធន លើស្តង់ដាទី១ (ផលសម្រេចអប់រំ និងការសិក្សារបស់សិស្ស) ក៏ពុំទាន់ទទួលបានលទ្ធផលល្អប្រសើរផងដែរ ដោយលទ្ធផលសម្រេចបានទាបជាងស្តង់ដា តម្លៃមធ្យម Mean=១.៧៩, SD=0.0៥ ។ លទ្ធផលនេះបញ្ជាក់ថា ការប្រមូលកុមារចូលរៀន លទ្ធផលសិក្សារបស់កុមារ និងការយល់ដឹងរបស់មាតាបិតាក្នុងការចិញ្ចឹមបីបាច់អប់រំកុមារ មិនទាន់ស្របនឹងស្តង់ដាសាលារៀនគំរូ។

ចំពោះស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធន លើស្តង់ដាទី២ (ថ្នាក់រៀនមានដំណើរការសម្រាប់ការបង្រៀន និងរៀន) លទ្ធផលដែលទទួលបានពីការសិក្សាស្រាវជ្រាវក៏បានបង្ហាញនៅទាបជាងស្តង់ដាដែរ ដោយតម្លៃមធ្យម Mean=២.៦១, SD=0.២២ ។ លទ្ធផលនេះបញ្ជាក់ថា គ្រូមិនបានរៀបចំកម្មវិធីជួយសិស្សរៀនយឺតជាប់ជាប្រចាំ និងគ្រូបង្រៀនខ្វះខាតលើការត្រៀមទុកជាមុននូវឯកសាររដ្ឋបាលគ្រូដូចជាប្លង់មេរៀនលម្អិត កិច្ចតែងការបង្រៀន ផែនការបង្រៀន...។

ដោយឡែកស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធន លើស្តង់ដាទី៣ (ភាពជាម្ចាស់នៃសហគមន៍សាលារៀន) ក៏ពុំទាន់ទទួលបានលទ្ធផលល្អប្រសើរផងដែរ ដោយលទ្ធផលសម្រេចបានទាបជាងស្តង់ដា តម្លៃមធ្យមត្រឹមតែ Mean=១.៩៣, SD=0.0៦ ។ លទ្ធផលនេះបញ្ជាក់ថា ការចូលរួមពីមាតាបិតាអាណាព្យាបាលសិស្ស នៅមិនបានសមស្រប ដែលជាហេតុធ្វើឱ្យកម្មវិធីមួយចំនួនរបស់

សាលារៀនទទួលបានលទ្ធទាប មិនស្របនឹងស្តង់ដាសាលារៀនគំរូ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។

ចំណែកឯស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធន លើស្តង់ដាទី៤ (រដ្ឋបាល និងដំណើរការសាលារៀន) នៅតែទទួលបានលទ្ធផលគាប់ប្រសើរស្របនឹងស្តង់ដាសាលារៀនគំរូដែរ ដោយលទ្ធផលសម្រេចបានតម្លៃមធ្យម Mean=២.៧៨, SD=0.0៥ ។ លទ្ធផលនេះបញ្ជាក់ថា សាលាទាន់មានផែនការវិនិយោគប្រចាំឆ្នាំ សម្ភារល្បែងលេងក្រៅថ្នាក់ ទីធ្លាលេង សមស្រប និងត្រឹមត្រូវតាមស្តង់ដា។ មួយវិញទៀតលទ្ធផលក៏បានបញ្ជាក់ដែរថា សាលារៀនមិនទាន់មានកម្មវិធីជួយសាលាមត្តេយ្យសិក្សាក្នុងខេត្ត ការប្រជុំត្រីមាសដឹកនាំដោយគណៈកម្មការគ្រប់គ្រងសាលារៀនដែរ។

ចំពោះស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធន លើស្តង់ដាទី៥ (គណនេយ្យភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) លទ្ធផលដែលទទួលបានពីការសិក្សាស្រាវជ្រាវក៏បានបង្ហាញនៅទាបជាងស្តង់ដាដែរ ដោយតម្លៃមធ្យម Mean=២.៤៩, SD=0.0៧ ។ លទ្ធផលនេះបញ្ជាក់ថា ការចូលរួមពីភាគីពាក់ព័ន្ធជាពិសេសក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង/ស្រុក នៅមិនទាន់បានសមស្រប និងទាន់ពេលវេលា ដែលជាហេតុធ្វើឱ្យស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន លទ្ធផលទទួលបានទាបជាងស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយសិក្សារដ្ឋ។

ទោះបីជាស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន លទ្ធផលជារួម និងលទ្ធផលតាមស្តង់ដានីមួយៗ បង្ហាញថាទាបជាងស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ តែក៏មានសូចនាករមួយចំនួនដែលសាលារៀនអនុវត្តទៅបានស្របនឹងស្តង់ដាផងដែរ ក្នុងនោះរួមមាន ស្តង់ដាទី១ សូចនាករទី១៣ (ចំនួនកុមារមត្តេយ្យសិក្សាមានអាហារូបត្ថម្ភត្រឹមត្រូវ) លទ្ធផលតម្លៃមធ្យម Mean=៣.៤៥, SD=0.0៩ ស្តង់ដាទី២ សូចនាករទី១ (ចំនួនថ្នាក់ធ្វើតេស្តសិស្សត្រីមាសទៀងទាត់) លទ្ធផលតម្លៃមធ្យម Mean=

៣.៥៧, SD=0.៣១ សូចនាករទី៥ (ចំនួនម៉ោងបង្រៀនជាក់ស្តែងមួយឆ្នាំសិក្សា) លទ្ធផលតម្លៃមធ្យម Mean=៣.៥៧, SD=0.0៩ និងសូចនាករទី៩ (ចំនួនគ្រូបង្រៀនបានទទួលការសង្កេតថ្នាក់រៀនពីនាយកសាលាចំនួន៣ដងក្នុង១ឆ្នាំ) លទ្ធផលតម្លៃមធ្យម Mean=៣.២៨, SD=0.១៩ ស្ថិតជាទី៣ សូចនាករទី៥ (ចំនួនកុមារឈឺបានទទួលការព្យាបាល) លទ្ធផលតម្លៃមធ្យម Mean=៣.៤៩, SD=0.១៩ ស្ថិតជាទី៤ សូចនាករទី១ (មានផែនការកែលម្អសាលារៀនប្រចាំឆ្នាំ) លទ្ធផលតម្លៃមធ្យម Mean=៣.៥១, SD=0.0២ សូចនាករទី៣ (មានរបាយការណ៍ប្រចាំឆ្នាំត្រឹមត្រូវ) លទ្ធផលតម្លៃមធ្យម Mean=៣.២៣, SD=0.២0 សូចនាករទី៤ (មានស្ថិតិនិងទិន្នន័យត្រឹមត្រូវ) លទ្ធផលតម្លៃមធ្យម Mean=៣.៦៣, SD=0.0៣ សូចនាករទី៥ (មានទីចាត់ការរៀបចំបានត្រឹមត្រូវ) លទ្ធផលតម្លៃមធ្យម Mean=៣.១៥, SD=0.១៧ សូចនាករទី៦ (មានការប្រជុំខែទៀងទាត់ដឹកនាំដោយនាយកសាលា) លទ្ធផលតម្លៃមធ្យម Mean=៣.00, SD=0.៣៤ សូចនាករទី១២ (មានទីធ្លាលេងសមស្រប) លទ្ធផលតម្លៃមធ្យម Mean=៣.00, SD=0.00 សូចនាករទី១៥ (មានចំនួនបង្គន់សមស្របនិងកំពុងប្រើ) លទ្ធផលតម្លៃមធ្យម Mean=៣.៣៤, SD=0.0១ សូចនាករទី១៦ (មានអគ្គិសនីប្រើប្រាស់) លទ្ធផលតម្លៃមធ្យម Mean=៣.៧៨, SD=0.0៨ សូចនាករទី១៨ (មានទិន្នន័យលទ្ធផលសិក្សាសិស្សផ្សព្វផ្សាយ) លទ្ធផលតម្លៃមធ្យម Mean=៣.៧៨, SD=0.១៩ សូចនាករទី១៩ (មានទិន្នន័យចំណូលចំណាយផ្សព្វផ្សាយ) លទ្ធផលតម្លៃមធ្យម Mean=៣.៧៨, SD=0.១៩ សូចនាករទី២0 (មានរបាយការណ៍ឆ្នាំផ្សព្វផ្សាយ) លទ្ធផលតម្លៃមធ្យម Mean=៣.២៨, SD=0.១0 និងស្ថិតជាទី៥ សូចនាករទី៥ (ចំនួននាយកឬនាយិកាមានការចាត់តាំងផ្លូវការ) លទ្ធផលតម្លៃមធ្យម Mean=៣.៩៧, SD=0.0៥ សូចនាករទី១0 (ចំនួនថ្នាក់រៀនខ្វះបង្កើនការចូលរៀន) លទ្ធផលតម្លៃមធ្យម Mean=៣.២៩, SD=0.១៨ និងសូចនាករទី១១ (ចំនួនថ្នាក់រៀនខ្វះបំពេញនិយាមសិស្សថ្នាក់រៀន) លទ្ធផលតម្លៃមធ្យម Mean=៣.៥៤, SD=0.៣២។

សរុបមកការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន មិនទាន់បានល្អស្របនឹងស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋនៅឡើយទេ។ លទ្ធផលនេះដោយសារមានបញ្ហាប្រឈមធំៗចំនួន៣ ទី១ កត្តាសមត្ថភាព គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន មិនទាន់យល់ដឹងបានទូលំទូលាយ និងច្បាស់លាស់ក្នុងការអនុវត្តសូចនាករនីមួយៗ នៃស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។ ទី២ កត្តាខ្វះការចូលរួមពីភាគីពាក់ព័ន្ធ នាយកដ្ឋានអប់រំកុមារតូច មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង/ស្រុក អាជ្ញាធរមូលដ្ឋាន និងសហគន៍ ក៏ជាផ្នែកមួយសំខាន់ដែលនាំឱ្យស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ទទួលបានលទ្ធផលមិនស្របនឹងស្តង់ដាសាលារៀនគំរូ។ ទី៣ កត្តាធនធាន(មនុស្ស សម្ភារ ថវិកា) ក៏ជាមូលហេតុមួយដ៏សំខាន់ផងដែរ ដែលនាំឱ្យរាំងស្ទះ ក៏ដូចជាអូសទាញឱ្យលទ្ធផលនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន មិនជាប់ស្តង់ដាសាលារៀនគំរូ។

អ្នកស្រាវជ្រាវមានជំនឿជាក់យ៉ាងមុតមាំថាតាមរយៈការសិក្សាស្រាវជ្រាវមួយនេះ អាចជំរុញ និងលើកទឹកចិត្តដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ឱ្យចូលរួមយ៉ាងសកម្មជាមួយនឹងគណៈគ្រប់គ្រងសាលារៀនដើម្បីជំរុញឱ្យស្ថានភាពការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន ទទួលបានលទ្ធផលល្អស្របតាមស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ព្រមទាំងឆ្លើយតបទៅនឹងបញ្ហាប្រឈម តម្រូវការចាំបាច់របស់សាលារៀន និងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាគោលនយោបាយរបស់រាជរដ្ឋាភិបាល។

## ៥.២ សំណូមពរ

តាមរយៈការស្រាវជ្រាវនេះ ខ្ញុំយល់ឃើញថាស្ថានភាពនៃដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធាន កំពុងជួបប្រទះនូវបញ្ហាប្រឈមជាច្រើន ដែលត្រូវយកចិត្តទុកដាក់បន្ថែមក្នុងការកែលម្អ។ ម្យ៉ាងវិញទៀតការសិក្សាស្រាវជ្រាវលើប្រធានបទ ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងសាលាមត្តេយ្យសិក្សាធនធានក្នុង

ខេត្តស្វាយរៀង យើងខ្ញុំសង្កេតឃើញថា លទ្ធផលនៅទាបជាងស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។ អាស្រ័យហេតុនេះ យើងខ្ញុំដែលជាអ្នកសិក្សាស្រាវជ្រាវមានសំណូមពរមួយចំនួនដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់រួមមាន៖ នាយកដ្ឋានអប់រំកុមារតូច មន្ទីរអប់រំ យុវជន និងកីឡារាជធានី/ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង/ស្រុក សាលារៀន និងសហគមន៍ មេត្តាចូលរួមឱ្យបានសកម្មដើម្បីគាំទ្រដល់ការអនុវត្តការងារដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានឱ្យបានល្អប្រសើរស្របនឹងស្តង់ដាសាលារៀនគំរូ។

### ៥.២.១ នាយកដ្ឋានអប់រំកុមារតូច

- បើកវគ្គបណ្តុះបណ្តាលបំប៉នសមត្ថភាព ដល់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន អំពីខ្លឹមសារ និងវិធីសាស្ត្រក្នុងការអនុវត្តការងារលើសូចនាករនីមួយៗឱ្យបានច្បាស់លាស់ និងប្រាកដថាភាគីពាក់ព័ន្ធ។
- បង្កើតកញ្ចប់ថវិកាទម្លាក់ដល់មត្តេយ្យសិក្សាធនធានបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង និងបង្កើតយន្តការត្រួតពិនិត្យ និងតាមដានឱ្យបានហ្មត់ចត់ និងច្បាស់លាស់ទៅលើការប្រើប្រាស់ថវិការបស់សាលារៀន
- ទម្លាក់ថវិកាឱ្យបានទាន់ពេលវេលា ដើម្បីឱ្យសាលារៀន អនុវត្តសកម្មភាពនានាបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

### ៥.២.២ មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត

- មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តគួរផ្តល់វគ្គបណ្តុះបណ្តាលបំប៉នសមត្ថភាពជាប្រចាំទាក់ទងទៅការនុវត្តការងាររបស់ភាគីពាក់ព័ន្ធទាំងអស់ លើសូចនាករនីមួយៗឱ្យបានត្រឹមត្រូវ និងច្បាស់លាស់

- ជួយសម្របសម្រួលឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធរួមទាំងថ្នាក់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំយុវជន និងកីឡានៃរដ្ឋបាលស្រុក/ក្រុង អាជ្ញាធរដែនដី និងមាតាបិតា អាណាព្យាបាលសិស្ស ក្នុងការអនុវត្តពាក់ព័ន្ធនានាឱ្យបានជាប់ជាប្រចាំ និងទាន់ពេលវេលា

### ៥.២.៣ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង-ស្រុក-ខណ្ឌ

- ការិយាល័យអប់រំ(បុគ្គលិកការិយាល័យ និងក្រុម DTMT) គួរតែជួយបង្ហាត់បង្រៀន និងបំប៉នទាក់ទងទៅនឹងការអនុវត្តការងារនៃស្តង់ដាសាលារៀនគំរូ រួមទាំងការលើកសកម្មភាពនានាឱ្យឆ្លើយតបទៅនឹងគោលនយោបាយអប់រំដល់គណៈគ្រប់គ្រងសាលា
- ចុះត្រួតពិនិត្យ តាមដាន និងវាយតម្លៃទៅលើដំណើរការអនុវត្តការងាររបស់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងភាគីពាក់ព័ន្ធនានា
- ចូលរួមផ្តល់ព័ត៌មានត្រឡប់ និងអនុសាសន៍កែលម្អទៅលើចំណុចខ្វះខាត និងបញ្ហាប្រឈមនានាដែលសាលាបាន និងកំពុងជួបប្រទះ។

### ៥.២.៤ សាលារៀន

- គណៈគ្រប់គ្រងសាលារៀនគួរតែសិក្សាស្រាវជ្រាវបន្ថែម ទៅលើការអនុវត្តការងារតាមស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សារដ្ឋ ទាំង៦៨សូចនាករ
- រៀបចំរចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រងសាលា ឱ្យបានច្បាស់លាស់ ដោយមានសមាសភាពចូលរួមពីបុគ្គលិកក្នុងអង្គភាព អាជ្ញាធរមូលដ្ឋាន តំណាងសហគមន៍
- ពង្រឹងសាមគ្គីភាពផ្ទៃក្នុង ពង្រីកទំនាក់ទំនងទៅគ្រប់ភាគីពាក់ព័ន្ធ។

### ៥.២.៥ សហគមន៍

- មាតាបិតា អាណាព្យាបាលសិស្ស រួមទាំងអាជ្ញាធរមូលដ្ឋានគួរតែចូលរួមយ៉ាងសកម្ម និងគាំទ្រគ្រប់សកម្មភាពរបស់សាលារៀន

- រក្សាទំនាក់ទំនងល្អជាមួយលោកគ្រូ-អ្នកគ្រូ និងគណៈគ្រប់គ្រងសាលា ងាយស្រួលក្នុងការផ្តល់ព័ត៌មានត្រឡប់ទៅវិញទៅមក ពីសកម្មភាពផ្សេងៗ និងលទ្ធផលសិក្សារបស់កូន
- ចូលរួមត្រួតពិនិត្យ តាមដាន និងវាយតម្លៃពីការរៀបចំ និងការអនុវត្តសកម្មភាពនានា រួមទាំងការប្រើប្រាស់ថវិការបស់សាលារៀន
- ជួយបំផុសបំផុលពីសកម្មភាពផ្សេងៗរបស់សាលារៀន និងស្វែងរកសប្បុរសជននានា ដើម្បីជួយអភិវឌ្ឍសាលារៀន។

## ឯកសារយោង


រាជរដ្ឋាភិបាលកម្ពុជា. (២០១៣) «*យុទ្ធសាស្ត្រចតុកោណ*» ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា

រាជរដ្ឋាភិបាលកម្ពុជា. (២០១៤) *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨*

រាជរដ្ឋាភិបាលកម្ពុជា. (២០១៨) «*យុទ្ធសាស្ត្រចតុកោណ*» ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា

ក្រសួងអប់រំ យុវជន និងកីឡា. (២០០៦) *ការងារគ្រប់គ្រង រដ្ឋបាល* ឯកសារបំប៉ននាយកសាលារៀនបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៤) *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៤-២០១៨*

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៥) *គោលនយោបាយស្តីពីបង្រៀន* ផែនការសកម្មភាព

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៧) *ស្តង់ដានាយកសាលារៀន*

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៨) *កម្មវិធីសិក្សាលម្អិត* សម្រាប់មត្តេយ្យសិក្សារដ្ឋ

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៩) *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣*

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៩) *សៀវភៅណែនាំអនុវត្តទី១ ស្តីពី ការគ្រប់គ្រងសាលារៀនសម្រាប់មត្តេយ្យសិក្សាសាធារណៈ*

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៩) *ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ឆ្នាំ២០៣០* គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤

ក្រសួងអប់រំ យុវជន និងកីឡា. (២០២២) *ផែនការលទ្ធផលឆ្នាំសិក្សា ២០២៣-២០២៣* អនុវិស័យអប់រំកុមារតូច

ក្រសួងអប់រំ យុវជន និងកីឡា. (២០២៣) *សន្និបាត បូកសរុបលទ្ធផលការងារ អប់រំ យុវជន និងកីឡា* ឆ្នាំសិក្សា២០២១-២០២២ និងទិសដៅឆ្នាំសិក្សា២០២២-២០២៣

នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ. (២០០៨) *កម្មវិធីសិក្សាគោលសម្រាប់មធ្យមសិក្សាទុតិយភូមិ*

នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ. (២០១៦) *ការងារគ្រប់គ្រង និងភាពជាអ្នកដឹកនាំ*

នាយកដ្ឋានអប់រំកុមារតូច. (២០២២) *សន្ទរកថាស្វាគមន៍ និងរបាយការណ៍* ក្នុងពិធីប្រកាស និងផ្សព្វផ្សាយដាក់ឱ្យអនុវត្តសៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា

បណ្ឌិត នី វឌ្ឍា. (២០២២) *តួនាទី ភារកិច្ចរបស់នាយកសាលា*

វិទ្យាស្ថានស្រាវជ្រាវ. (១៩៩៦) *កម្មវិធីសិក្សាគោលសម្រាប់មធ្យមសិក្សាទុតិយភូមិ*

Brain, T., & Peter, C. (2013). *12 Disciplines of Leadership Excellence: How Leaders Achieve Sustainable High Performance.* New York.

Chao, L. (2011). *Good Governance in Education.* Phnom Penh.

Engle, P.L., L.C.H. Fernald, H. Alderman, J. Behrman, C. O'Gara, A. Yousafzai, M. Cabral de Mello, M. Hidrobo, N. Ulkuer, I. Ertem, S. Iltus and the Global Child Development Steering Group (2011). *Strategies for reducing inequalities and improving developmental outcomes for young children in low-income and middle-income countries.* The Lancet 378(9799): 1339-1353.

Kim, K. (2012). *Leadership.* Phnom Penh.

Heng, M. (1995). *Preahbat Dhammik. (2, Ed).* Phnom Penh: Buddhism for Development.

Ourn, S. (2016). *Good Leader.* Phnom Penh.

World Bank (2010). *Stepping up Skills: For more jobs and higher productivity.* Washington D.C.: World Bank.

World Bank (2011). *No Small Matter: The impact of poverty, Shock, and human capital investments in Early Childhood Development.* Washington D.C.: World Bank.

# ឧបសម្ព័ន្ធ ទី១៖ លិខិតបង្គាប់ការរបស់គណៈកម្មការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ :២៨០.....វជអ.លក

## លិខិតបង្គាប់ការ

យោង៖ - លិខិតឧទ្ទេសនាមលេខ៨៤៧៣ អយក.ឧទន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីគណៈកម្មការមេប្រយោគ សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។

- លិខិតឧទ្ទេសនាមលេខ៨៥០១ អយក. ឧទន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីគណៈកម្មការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។
- លិខិតឧទ្ទេសនាមលេខ៨៤៧៤ អយក. ឧទន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពី គណៈកម្មការរៀបចំ សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។
- លិខិតឧទ្ទេសនាមលេខ៨៤៧៦ អយក. ឧទន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពី គណៈកម្មការគណនេយ្យ និងសម្ភារៈ សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។
- លិខិតឧទ្ទេសនាមលេខ៨៤៧៥ អយក. ឧទន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពី គណៈកម្មការកណ្តាល សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។

បុគ្គលិកអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៨-៩ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង ០៨:០០នាទីព្រឹក នៅវិទ្យាស្ថានជាតិអប់រំ៖

I. **គណៈកម្មការការពារនិក្ខេបបទ**

**ក្រុមទី១ នៅអគារ** B07 **បន្ទប់** 101

| **គោត្តនាម និងនាម** | | **អង្គភាព** | **តួនាទី** |
|---|---|---|---|
| ១- ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- លោកស្រីបណ្ឌិត | បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | សមាជិកា |
| ៣- លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤- លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

| | | | |
|---|---|---|---|
| ៥- លោកស្រី | នូ ចន្នី | វិទ្យាស្ថានជាតិអប់រំ | សមាជិកា |
| ៦- លោកបណ្ឌិត | ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | លន លីណា | វិទ្យាស្ថានជាតិអប់រំ | លេខា |

**ក្រុមទី២ នៅអគារ** B07 **បន្ទប់** 105

| | | | |
|---|---|---|---|
| ១- ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- ឯកឧត្តមបណ្ឌិត | ប៊ិច សៀង | វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល | សមាជិក |
| ៣- លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤- លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥- លោកបណ្ឌិត | គួយ សុគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦- លោកបណ្ឌិត | ទៀង សោភទ្រា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧- កញ្ញា | យុន គីមរៀង | វិទ្យាស្ថានជាតិអប់រំ | លេខា |

**ក្រុមទី៣ នៅអគារ** B07 **បន្ទប់** 107

| | | | |
|---|---|---|---|
| ១- លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- លោកបណ្ឌិត | អែ សុងហ៊ាង | មជ្ឈមណ្ឌល SEAMEO TED | សមាជិក |
| ៣- លោកបណ្ឌិត | កាន់ ពុទ្ធី | នាយកដ្ឋានបឋមសិក្សា | សមាជិក |
| ៤- លោកស្រី | សាំង សុចិន្តា | វិទ្យាស្ថានជាតិអប់រំ | សមាជិកា |
| ៥- លោកស្រីបណ្ឌិត | ឡឹយ សុគា | វិទ្យាស្ថានជាតិអប់រំ | សមាជិកា |
| ៦- លោកបណ្ឌិត | អាន រ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧- កញ្ញា | យុន ស៊ីណូត | វិទ្យាស្ថានជាតិអប់រំ | លេខា |

**ក្រុមទី៤ នៅអគារ** B07 **បន្ទប់** 109

| | | | |
|---|---|---|---|
| ១- លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- លោកបណ្ឌិត | លី គីមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៣- លោកបណ្ឌិត | មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ៤- លោកបណ្ឌិត | សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥- លោកបណ្ឌិត | ទី សុផល | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦- លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧- កញ្ញា | ណុច ស្រីនាង | វិទ្យាស្ថានជាតិអប់រំ | លេខា |

**ក្រុមទី៥ នៅអគារ** B07 **បន្ទប់** 110

| | | | |
|---|---|---|---|
| ១- ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២- លោកបណ្ឌិត | ឈូក ច័ន្ទធាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣- លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិកា |
| ៤- លោកបណ្ឌិត | នី វដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥- លោកបណ្ឌិត | សឿង សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

| | | | |
|---|---|---|---|
| ៦- លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧- លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨- កញ្ញា | ភាព សុខនី | វិទ្យាស្ថានជាតិអប់រំ | លេខា |

**ក្រុមទី៦ នៅ** B07 **បន្ទប់** 111

| | | | |
|---|---|---|---|
| ១- លោកបណ្ឌិត | នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ៣- លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤- លោកបណ្ឌិត | អ៊ឹម គឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥- លោក | ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦- លោកស្រី | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | លេខា |

II. **គណៈកម្មការកណ្តាល** B07 **បន្ទប់** 103

| | | | |
|---|---|---|---|
| ១- លោកស្រី | ធុក ផល្លីនី | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- លោក | ប៉ូ ប៊ុន្នួន | វិទ្យាស្ថានជាតិអប់រំ | ធ្វើកំណត់ហេតុ |
| ៣- លោកស្រី | ទៀប ច័ន្ទវត្តី | វិទ្យាស្ថានជាតិអប់រំ | រៀបចំដាប់/ធ្លាក់ |
| ៤- កញ្ញា | ឈឺន លីន | វិទ្យាស្ថានជាតិអប់រំ | យកវត្តមាន |
| ៥- លោកស្រី | ម៉ម ចំប៉ី | វិទ្យាស្ថានជាតិអប់រំ | បូកពិន្ទុ/ផ្ទៀងផ្ទាត់ |

III. **គណៈកម្មការរដ្ឋបាល និងគណនេយ្យ**

| | | | |
|---|---|---|---|
| ១- លោក | គិន កោសល្ល | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- លោក | ឡេង បូរី | វិទ្យាស្ថានជាតិអប់រំ | រៀបចំបន្ទប់/សម្ភារៈ |
| ៣- លោកស្រី | អ៊ុំ សុចិន្តា | វិទ្យាស្ថានជាតិអប់រំ | រៀបចំហិរញ្ញវត្ថុ |
| ៤- លោក | អ៊ុច ផលរដ្ឋ | វិទ្យាស្ថានជាតិអប់រំ | យកវត្តមាន |

ថ្ងៃ ព្រហស្បតិ៍ ១៤រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ២០២៣

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សឿង សុវណ្ណា

**បានឃើញ និងឯកភាព**

**ប្រធានគណៈកម្មាធិការកំណែទម្រង់**

បណ្ឌិត ឌី_ខាំបូលី

**កន្លែងទទួល៖**

- ការិយាល័យ/ដេប៉ាតឺម៉ង់នៃ វជអ ដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ.វជអ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ: ៤៧១ វជអ.

## ប្រធានបទនិក្ខេបបទស្រាវជ្រាវ

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។

និស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ដែលបានទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ៖

| ល.រ | ប្រធានបទនិក្ខេបបទស្រាវជ្រាវ | គោត្តនាម-នាមនិស្សិត |
|---|---|---|
| ១ | ទស្សនសហគមន៍ចំពោះកំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិពីឆ្នាំ២០២១ ដល់ឆ្នាំ២០២២ ករណីសិក្សាខេត្តកំពង់ចាម | កន កុល |
| ២ | កត្តាជះឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀង | គង់ បូរ៉ា |
| ៣ | អាកប្បកិរិយា និងសមត្ថភាពគ្រូបង្រៀនចំពោះការប្រើប្រាស់ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍(ICT) នៅសាលាមធ្យមសិក្សាធនធានក្នុងខេត្តតាកែវ | គុយ វដ្ឋា |
| ៤ | គោលការណ៍ណែនាំអំពីការគ្រប់គ្រងការអនុវត្តអធិការកិច្ចនៅកម្រិតបឋមសិក្សាក្នុងក្រុងស្ទឹងសែន ខេត្តកំពង់ធំ | គៅ លឹមហ៊ាត់ |
| ៥ | ស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញក្នុងខេត្តរតនគិរី | ឈឹម ឌីនគោ |
| ៦ | ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានក្នុងខេត្តស្វាយរៀង | ញ៉ឹក កិត្យា |
| ៧ | ការសិក្សាប្រៀបធៀបនៃការអនុវត្តគោលការណ៍គណនេយ្យភាពសាលារៀនជំនាន់ថ្មីក្នុងរាជធានីភ្នំពេញ | ទឿន រតនៈ |
| ៨ | តម្រូវការអន្តរកម្មឌីជីថលលើការបំពេញការងាររបស់គ្រូបង្រៀនក្នុងខេត្តកំពង់ស្ពឺ | ធឿន វដ្ឋា |
| ៩ | ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង | ពៅ ស្រីម៉ៅ |
| ១០ | ស្ថានភាពនៃការអនុវត្តស្តង់ដាសាលាមធ្យមសិក្សាធនធាននៅក្នុងខេត្តកំពង់ឆ្នាំង | ព្រុំ ណារិន |
| ១១ | ស្ថានភាពនៃការអនុវត្តក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រីនៅកម្រិតបឋមសិក្សាក្នុងខេត្តត្បូងឃ្មុំ | ម៉ុល មួយគា |

| | | |
|---|---|---|
| ១២ | ស្ថានភាពនៃការគ្រប់គ្រងការអនុវត្តដឹកនាំដំណើរការសាលារៀននៅតាមអនុវិទ្យាល័យក្នុងតំបន់លិចទឹកកណើសិក្សាខេត្តកំពង់ឆ្នាំង | ម៉ោញ សុជាវត្ថ |
| ១៣ | ស្ថានភាពនៃការបង្រៀន និងរៀនស្ទែម(STEM) នៅសាលាមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកណ្តាល | មឿន ផល្លា |
| ១៤ | ស្ថានភាពនៃការគ្រប់គ្រងធនធានរូបវន្តនៅសាលាមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពង់ចាម | យឹម ធារ៉ា |
| ១៥ | គណនេយ្យភាពអ្នកដឹកនាំះឧត្តមានុវត្ត និងបញ្ហាប្រឈមរបស់នាយកសាលាបឋមសិក្សានៅខេត្តត្បូងឃ្មុំ។ | លី សុផា |
| ១៦ | ការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យក្នុងខេត្តកំពង់ស្ពឺ | សឹម ភក្តី |
| ១៧ | ស្ថានភាពនៃការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត | សួង គីមសាន |
| ១៨ | ស្ថានភាពនៃការគ្រប់គ្រងនិងប្រើប្រាស់បណ្ណាល័យនៅបឋមសិក្សាក្នុងខេត្តកំពត | សេន ម៉ៅ |
| ១៩ | ទស្សនៈរបស់នាយកសាលាលើកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជាករណីសិក្សាខេត្តតាកែវ | សែម ជ្រាន |
| ២០ | ស្ថានភាពនៃការរៀបចំ និងអនុវត្តតេស្តស្តង់ដាកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង | ហ៊ីង សុវណ្ណា |
| ២១ | កត្តាជះឥទ្ធិពលលើជម្រើសអាជីពនាពេលអនាគតរបស់សិស្សមធ្យមសិក្សាបច្ចេកទេស នៅខេត្តកំពង់ឆ្នាំង កំពង់ធំ និងកំពង់ស្ពឺ | ហឿន សារ៉ុត |
| ២២ | ការយល់ឃើញរបស់សិស្សក្នុងការរៀន និងបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញ | អិន ផល្លាក់ |
| ២៣ | ប្រសិទ្ធភាពនៃការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបដំណោះស្រាយបញ្ហា ដោយបញ្ចូល GeoGebra ក្នុងការបង្រៀននិងរៀនធរណីមាត្រនៅវិទ្យាល័យក្នុងរាជធានីភ្នំពេញ | អ៊ាង ប៊ុនរឿង |
| ២៤ | ឥទ្ធិពលនៃភាពជាអ្នកដឹកនាំបែបស្វ័យភាពរបស់នាយកសាលារៀនទៅលើការចង់ចេះចង់ដឹងនិងការពេញចិត្តបំពេញការងាររបស់គ្រូបង្រៀន | អូន ពិសី |
| ២៥ | ស្ថានភាពនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យនៅក្នុងខេត្តតាកែវ | អៀក ចន្នី |
| ២៦ | ស្ថានភាពការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សានៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង | វ៉ា សុភ័ក្រ្តា |

និស្សិត ដូចមានរាយនាមខាងលើ ត្រូវទទួលភារកិច្ចអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៣

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**បានឃើញ និងឯកភាព**

**ប្រធានគណៈកម្មាធិការកំណែទម្រង់**

បណ្ឌិត ឌី_ខាំបូលី

**កន្លែងទទួល៖**

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ -ឯកសារ រដអ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខៈ ៤៧៦ ខជអ.

## ប្រធានបទនិក្ខេបបទស្រាវជ្រាវ

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។

និស្សិតបង់ថ្លៃសេវាសិក្សា ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ដែលបានទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ៖

| ល.រ | ប្រធានបទនិក្ខេបបទស្រាវជ្រាវ | គោត្តនាម-នាមនិស្សិត |
|---|---|---|
| ១ | ស្ថានភាពនៃការអនុវត្តគោលការណ៍អភិបាលកិច្ចនៅសាលារៀនជំនាន់ថ្មី នៅរាជធានីភ្នំពេញ | គៀត គឹក |
| ២ | ឧត្តមានុវត្តន៍នៃការដឹកនាំគ្រប់គ្រងរបស់នាយកសាលាវេស្ទើនអន្តរជាតិ ករណីសិក្សាសាលាវេស្ទើនអន្តរជាតិសាខាStadium | ឌី ការុន |
| ៣ | ស្ថានភាពនៃការអនុវត្តស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀង | ប៉ែន បារាំង |
| ៤ | ស្ថានភាពនៃការអនុវត្តគោលនយោបាយអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យាវិស្វកម្ម និងគណិតវិទ្យានៅសាលារៀនជំនាន់ថ្មីក្នុងប្រទេសកម្ពុជា | រស់ វដ្ឋា |
| ៥ | ទស្សនៈរបស់នាយក គ្រូ សិស្ស និងសហគមន៍ចំពោះការរៀបចំបរិស្ថានសិក្សានៅកម្រិតបឋមសិក្សាក្នុងខេត្តតាកែវ | លឿង កុសល |
| ៦ | ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងក្រុមបច្ចេកទេសមុខវិជ្ជានៅវិទ្យាល័យក្នុងខេត្តពោធិ៍សាត់ | វ៉ាន់ ចាន់រ៉ាត |
| ៧ | ឥទ្ធិពលនៃការប្រើប្រាស់ស្មាតហ្វូនលើការសិក្សារបស់សិស្សវិទ្យាល័យក្នុងខេត្តរតនគិរី | សន សុភាព |
| ៨ | ការអភិវឌ្ឍធនធានមនុស្សក្នុងបរិវត្តកម្មឌីជីថលនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈក្នុងរាជធានីភ្នំពេញ | ហុង លក្ខិណា |

និស្សិត ដូចមានរាយនាមខាងលើ ត្រូវទទួលភារកិច្ចអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៣

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**បានឃើញ និងឯកភាព**

**ប្រធានគណៈកម្មាធិការកំណែទម្រង់**

បណ្ឌិត ឌី_ខាំបូលី

**កន្លែងទទួល៖**

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ -ឯកសារ វជអ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
វិទ្យាស្ថានជាតិអប់រំ

គោរពជូន
ឯកឧត្តមបណ្ឌិតនាយក វិទ្យាស្ថានជាតិអប់រំ

| | | |
|---|---|---|
| អនុញ្ញាតឲ្យនិស្សិតឈ្មោះ | ៖ | ញ៉ឹក កិត្យា |
| ប្រធានបទស្រាវជ្រាវ | ៖ | **ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានក្នុងខេត្តស្វាយរៀង** |
| ដើម្បីចូលរួម | ៖ | ការពារនិក្ខេបបទបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី ១០ |
| កាលបរិច្ឆេទការពារបញ្ចប់ | ៖ | ថ្ងៃទី០៩-១០ ខែធ្នូ ឆ្នាំ២០២៣ ម៉ោង០៧:០០នាទីព្រឹក |
| ទីកន្លែង | ៖ | វិទ្យាស្ថានជាតិអប់រំ |

យើងខ្ញុំជាគ្រូណែនាំបង្គោល និងគ្រូណែនាំរង ពិតជាបានអនុញ្ញាតឱ្យនិស្សិតមានឈ្មោះខាងលើចូលរួមការពារនិក្ខេបបទដើម្បីបំពេញក្របខ័ណ្ឌការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ តាមការកំណត់របស់ វិទ្យាស្ថានជាតិអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា។

ថ្ងៃព្រហស្បតិ៍ ១១កើតខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០២៣

**គ្រូណែនាំបង្គោល**

បណ្ឌិត.សៀង សុវណ្ណា

**គ្រូណែនាំរង**

បណ្ឌិត ឡេង-សុផន

## ឧបសម្ព័ន្ធ ទី២៖ លិខិតចាត់តាំងគ្រូណែនាំគោល និងគ្រូណែនាំរង សម្រាប់ការសរសេរនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៣៤៣៧២ អយក.ខ៩ន

### លិខិតឧទ្ទេសនាម

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា ២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជាគ្រូណែនាំគោល និងគ្រូណែនាំរង សម្រាប់ការសរសេរនិក្ខេបបទរបស់និស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ដែលបានទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ៖

| ល.រ | គោត្តនាម-នាម គ្រូណែនាំគោល | គោត្តនាម-នាម គ្រូណែនាំរង | គោត្តនាម-នាម និស្សិត |
|---|---|---|---|
| ១ | បណ្ឌិត នៀ សុផន | បណ្ឌិត សៀង សុវណ្ណា | កង សុផាវ៉ាមី |
| ២ | បណ្ឌិត នី វឌ្ឍា | បណ្ឌិត ទី សុផល | កន កុល |
| ៣ | បណ្ឌិត អាន វ៉ូប្រាវ | បណ្ឌិត ទី សុផល | គង់ បូរ៉ា |
| ៤ | បណ្ឌិត ឌី ខាំបូលី | បណ្ឌិត កាន់ ពុទ្ធី | គុយ វឌ្ឍា |
| ៥ | បណ្ឌិត ម៉ម ចាន់សៀន | បណ្ឌិត ប៉ិច សៀង | គៅ លីមហ៊ាត់ |
| ៦ | បណ្ឌិត ឡឹយ សុខគា | បណ្ឌិត គួយ សូគាន | ជុំ ជឿន |
| ៧ | លោក លឹម វ៉ាន់ | បណ្ឌិត គួយ សូគាន | ឈីម ឌីនគោ |
| ៨ | បណ្ឌិត សៀង សុវណ្ណា | បណ្ឌិត នៀ សុផន | ញ៉ឹក កិត្យា |
| ៩ | លោកស្រី នូ ចន្ធី | បណ្ឌិត ឈាង សង្វាត | ទៀន រតនៈ |
| ១០ | បណ្ឌិត ឈាង សង្វាត | លោក ម៉ន មុនិន្ទ | ជឿន វឌ្ឍា |
| ១១ | បណ្ឌិត នៀ សុផន | បណ្ឌិត សៀង សុវណ្ណា | ពុំ សុធីតាមុនី |
| ១២ | បណ្ឌិត អ៊ឹម គឿន | បណ្ឌិត សោម វណ្ណៈ | ពៅ ស្រីម៉ៅ |
| ១៣ | បណ្ឌិត នូវ វីរ៉ា | បណ្ឌិត នៀ សុផន | ព្រុំ ណារិន |
| ១៤ | បណ្ឌិត អ៊ឹម គឿន | បណ្ឌិត នី វឌ្ឍា | ម៉ុល មួយគា |
| ១៥ | បណ្ឌិត នូវ វីរ៉ា | លោក ចាប រតនា | ម៉ោញ សុធារ័ត្ន |
| ១៦ | លោកស្រី ប៊ុន សុផានី | លោក ថៃ ហេង | មឿន ផល្លា |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | | |
|---|---|---|---|
| ១៧ | បណ្ឌិត លី គិមឡុង | លោក ចាន់ រ៉ាដា | **យ៉ម វុទ្ធី** |
| ១៨ | លោក ឡុច ចាន់ថន | បណ្ឌិត បូ ច័ន្ទគុលិកា | **យឹម ធារ៉ា** |
| ១៩ | បណ្ឌិត សិត សេង | បណ្ឌិត អាន វ៉ូប្រាវ | លី សុផា |
| ២០ | បណ្ឌិត គួយ សុគាន | បណ្ឌិត នី រដ្ឋា | សឹម ភក្តី |
| ២១ | លោក ចាន់ ធឿន | បណ្ឌិត ឈន ថន | សួង គឹមសាន |
| ២២ | បណ្ឌិត ឈន ថន | បណ្ឌិត សោន វណ្ណៈ | សេន ម៉ៅ |
| ២៣ | បណ្ឌិត សិត សេង | បណ្ឌិត នូវ វីរ៉ា | សែម ជ្រាន |
| ២៤ | បណ្ឌិត លី គិមឡុង | បណ្ឌិត នី ខាំបូលី | សោ សុផាត |
| ២៥ | បណ្ឌិត អាន វ៉ូប្រាវ | លោក ឡុច ចាន់ថន | ហ៊ីង សុវណ្ណា |
| ២៦ | លោក ចាប រតនា | បណ្ឌិត ម៉ម ចាន់សៀន | ហឿន សារ៉ែត |
| ២៧ | បណ្ឌិត សោន វណ្ណៈ | លោក ប៉ុ ប៊ុន្នន | អិន ផល្លាក់ |
| ២៨ | លោក ចាន់ រ៉ាដា | បណ្ឌិត សិត សេង | អ៊ាង ប៊ុនរឿង |
| ២៩ | បណ្ឌិត មាឃ ចាន់ថេង | បណ្ឌិត លី គិមឡុង | អ៊ុន ពិសី |
| ៣០ | បណ្ឌិត ឡឹយ សុខគា | បណ្ឌិត ឈន ថន | អៀក ចន្ធី |
| ៣១ | បណ្ឌិត ម៉ម ចាន់សៀន | លោក ចាប រតនា | វ៉ា សុភ័ក្ត្រា |
| ៣២ | បណ្ឌិត ជ័យ សារិន | បណ្ឌិត ឡឹយ សុខគា | មៀច បូរ៉ា |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវទទួលភារកិច្ចអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ [illegible] ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរតនាគារ និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ ដែអ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៣៤៧៣ អយក.ឧទក

# លិខិតឧទ្ទេសនាម

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា ២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជាគ្រូណែនាំគោល និងគ្រូណែនាំរង សម្រាប់ការសរសេរនិក្ខេបបទរបស់និស្សិតបង់ថ្លៃសេវាសិក្សា ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ដែលបានទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ៖

| ល.រ | គោត្តនាម-នាម គ្រូណែនាំគោល | គោត្តនាម-នាម គ្រូណែនាំរង | គោត្តនាម-នាម និស្សិត |
|---|---|---|---|
| ១ | លោក ម៉ៅ សារឿន | បណ្ឌិត អាន វ៉ូប្រាវ | គៀត គីក |
| ២ | បណ្ឌិត សៀង សុវណ្ណា | លោក ម៉ៅ សារឿន | ឌី ភារុន |
| ៣ | បណ្ឌិត គួយ សូគាន | បណ្ឌិត ទៀង សោភទ្រា | ប៉ែន បារាំង |
| ៤ | លោក ម៉ន មុនិន្ទ | បណ្ឌិត ឈាង សង្វាត | រស់ រដ្ឋា |
| ៥ | បណ្ឌិត នី រដ្ឋា | បណ្ឌិត សិត សេង | លឿង កុសល |
| ៦ | បណ្ឌិត ឈន ថន | លោក ចាន់ ធឿន | វ៉ាន់ ចាន់វ៉ាត |
| ៧ | បណ្ឌិត សោន វណ្ណៈ | លោកស្រី សាំង សុចិន្តា | សន សុភាព៍ |
| ៨ | បណ្ឌិត មាឃ ចាន់ថេង | បណ្ឌិត អែ សុងហ៊ាង | សុខ កែវរតនា |
| ៩ | លោក ថៃ ហេង | បណ្ឌិត នូវ វីរ៉ា | សេង សាជាត់ |
| ១០ | បណ្ឌិត ឈាង សង្វាត | លោកស្រី នូ ចន្ទី | ហុង លក្ខិណា |
| ១១ | បណ្ឌិត សឿង សុផា | បណ្ឌិត ម៉ម ចាន់សៀន | អ៊ុក រតនា |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវទទួលភារកិច្ចអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៥កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
  "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ -ឯកសារ រដែអ

# ឧបសម្ព័ន្ធ ទី៣៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៤០៨/២៧ អយក.វិសអ

ថ្ងៃ ច័ន្ទ ៨ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣

**ជម្រាបជូន**

- **ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានអង្គភាពក្រោមឱវាទនិងស្ដីការក្រសួងអប់រំ យុវជន និងកីឡា**
- **លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត**

កម្មវត្ថុ៖ ការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។

